# ការរីកចម្រើននៃដំណើររបស់ពួកបរិសុទ្ធ

*ពីពិភពលោកនេះទៅកាន់ការដែលនឹងត្រូវមក*

**ផ្នែកទី១ [Volume I - 1]**



ត្រូវបានសរសេរមកនៅក្រោមភាពស្រដៀងគ្នាទៅនឹងការយល់សប្តិដោយ

លោក John Bunyan

Recommend White Young Jeon

Translator Sreyleak Kohn

CRFI

អារម្ភកថា

គោលបំណងដែលខ្ញុំបានអធិស្ឋានសុំអោយព័ន្ធកិច្ចសម្រាប់ការសរសេរនេះនឹងត្រូវបានបង្កើតឡើងនៅក្នុងក្រុមជំនុំក្នុងប្រទេសកម្ពុជាជាយូរយារណាស់មកហើយ ហើយវាត្រូវបានជោគជ័យដោយផែនការណ៍របស់ព្រះ។ ខ្ញុំមានអារម្មណ៍រីករាយដែលបានបោះពុម្ពសៀវភៅចំនួន ៣ ក្បាលក្នុងប្រភេទកំរិតខ្ពស់ ហើយជាផលដំបូងសម្រាប់ការសេរនៃព័ន្ធកិច្ចរបស់ CEMFយើង។ ជាបឋម ខ្ញុំសូមសរសើរតម្កើងដល់ព្រះអម្ចាស់ដោយអស់ពីចិត្តចំពោះការបោះពុម្ពផ្សាយទាំងនេះដែលនិពន្ធដោយ John Bunyan ដែលបានបម្រើព្រះអម្ចាស់ជាគ្រូអធិប្បាយដ៏បរិសុទ្ធនៅឆ្នាំ ១៦៧៨ ទៅជាភាសាខ្មែរសំរាប់បេសកកម្មនៅប្រទេសកម្ពុជា។ នៅក្នុងប្រវត្តិសាស្រ្តពួកជំនុំ សៀវភៅនេះត្រូវបានអានជាសៀវភៅបន្ទាប់ពីបទគម្ពីរ។

ដោយសារភាសាខ្មែរពិបាកខ្លាំងពេក ខ្ញុំមិនហ៊ានធ្វើទេ ប៉ុន្តែព្រះបានរៀបចំក្រុមបកប្រែ CEMF សម្រាប់បេសកកម្មនេះ ហើយទីបំផុតតាមរយៈការលះបង់របស់គេ សៀវភៅនេះត្រូវបានបោះពុម្ពក្នុងឆ្នាំនេះ ក្នុងការរំលឹកខួប ១០០ ឆ្នាំចាប់តាំងពីក្រុមជំនុំកម្ពុជាបានទទួលដំណឹងល្អ ( ១៩២៣) ជាពិសេស កញ្ញា ស្រីល័ក្ខ ខន ដែលបម្រើការងារជាគ្រូបង្រៀនភាសាអង់គ្លេសនៃអនុវិទ្យាល័យ និងជាបុគ្គលិក CEMF ហើយនាងបានបញ្ចប់ការបកប្រែសៀវភៅដោយស៊ូទ្រាំទោះបីគាត់កំពុងសំរាកព្យាបាលរបួសដោយគ្រោះថ្នាក់របស់គាត់ក៏ដោយ។ ខ្ញុំកោតសរសើរនាងចំពោះទឹកចិត្តស្មោះត្រង់របស់នាងដែលស្រឡាញ់ព្រះអម្ចាស់និងដំណឹងល្អ។

ជាទូទៅផ្នែកមួយមានចំនួនច្រើន (៣៦៣ ទំព័រ); ខ្ញុំចែកវាជាបីភាគសម្រាប់ជួយអ្នកអានខ្មែរយើង។ សូមឱ្យព្រះគុណរបស់ព្រះនៅជាមួយពួកគេរហូតទៅ។

នៅក្នុងព្រះគ្រីស្ទ

ថ្ងៃទី ២២ ខែតុលាឆ្នាំ ២០២១

ដោយ: លោកគ្រូបណ្ឌិត វ៉ាយ យ៉ុងចុន  ( ប្រធាន CRFI & CEMF)

Sequence

អារម្ភកថា/ 3

សេចក្តីបញ្ជាក់ការពាររបស់អ្នកនិពន្ធសម្រាប់សៀវភៅនេះ/ 5

សេចក្តីផ្តើម /6

អ្នកផ្សាយដំណឹងល្អផ្តល់នូវទិសដៅ /16

អ្នកជិតខាង៖ លោកមានៈ និងលោកងាយបត់បែន/ 19

អ្វីដែលត្រូវសម្លឹងមើល / 22

លោកអ្នកប្រាជ្ញខាងលោកិយ / 30

ផ្លូវតែមួយ /38

បំណងល្អ៖ អ្នកយាមឃ្លោងទ្វារទុច្ចរិត / 46

អ្នកបកស្រាយ /57

ឈើឆ្កាង /64

អ្នកផ្លូវការ និង សេចក្តីកំពុត /88

ភ័យខ្លាច និង មិនទុកចិត្ត /94

ដេកនៅពេលថ្ងៃ /100

ការចូលទៅកាន់វិមាន "ស្រស់ស្អាត" /103

ភាពកម្រនៃ "ស្រស់ស្អាត" /107

ចាកចេញពីភ្នំ/119

អាប៉ូឡេអុង/121

## សេចក្តីបញ្ជាក់ការពាររបស់អ្នកនិពន្ធសម្រាប់សៀវភៅនេះ

នៅគ្រាដំបូងដែលខ្ញុំបានយកប៊ិចមកកាន់នៅក្នុងដៃរបស់ខ្ញុំមកសម្រាប់សរសេរ ខ្ញុំមិនបានយល់ទាល់តែសោះថាខ្ញុំគួរតែសរសេរសៀវភៅតូចមួយបែបនេះ។ ហើយខ្ញុំក៏មិនបានចាប់យកអ្វីមួយក្រៅពីនោះផងដែរ ជាជាងអ្វីដែលខ្ញុំបានចាប់ផ្តើមហើយស្ទើរតែចប់សព្វគ្រប់អស់ហើយ។

ហើយសៀវភៅនេះត្រូវបានសរសេរឡើងអំពីផ្លូវនៃការរត់ប្រណាំងរបស់ពួកបរិសុទ្ធ នៅក្នុងគ្រានៃដំណឹងល្អរបស់យើង ដែលត្រូវបានធ្លាក់ចូលនៅក្នុងបែបបទដូចជាកំណាព្យពីដំណើររបស់ពួកគេ និងពីផ្លូវទៅកាន់សិរីរុងរឿងដែលមានច្រើនជាងម្ភៃបែបដែលខ្ញុំបានលើកយកមក។ ខ្ញុំបានបញ្ចប់ដោយមានម្ភៃបែបនៅក្នុងមកុដរបស់ខ្ញុំ។ ហើយការនោះក៏បានកើនឡើងប្រៀបបីដូចជាកំទេចភ្លើងនៃធ្យូងដែលហោះឡើងដែរ។ ខ្ញុំមិនបានគិតថាប្រសិនបើអ្នកបង្កាត់យ៉ាងរហ័ស នោះខ្ញុំនឹងទុកអ្នកចោលតែឯង បើពុំនោះអ្នកនឹងធ្វើឲ្យឃើញថានៅតែដដែលៗ ហើយនឹងស៊ីសៀវភៅដែលខ្ញុំសរសេរ។

ដូច្នេះខ្ញុំក៏បានសរសេរសៀវភៅនេះឡើងមក។ ប៉ុន្តែខ្ញុំមិនទាន់បានគិតថានឹងបង្ហាញទៅកាន់ពិភពលោកនូវប៊ិចនិងសៀវភៅរបស់ខ្ញុំបែបនោះទេ។ ខ្ញុំគ្រាន់តែគិតថាខ្ញុំមិនបានដឹងអ្វីទាំងអស់។ ហើយខ្ញុំក៏មិនបានស្រវ៉ាចាប់ដើម្បីនឹងផ្គាប់ចិត្តអ្នកជិតខាងរបស់ខ្ញុំនោះដែរ។ ទេ មិនមែនខ្ញុំទេ។ ខ្ញុំធ្វើវាឡើងដោយខ្លួនខ្ញុំដើម្បីនឹងគាប់ដល់ចិត្ត។

ខ្ញុំគ្រាន់តែចំណាយពេលមួយរដូវកាលនៅក្នុងការសរសេរនូវសៀវភៅយ៉ាងរហ័សនេះ ហើយខ្ញុំមានបំណងនឹងជម្រុញខ្លួនឯងឱ្យធ្វើបែបនេះ ដោយចេញពីគំនិតដែលមិនល្អ ដែលធ្វើឲ្យខ្ញុំមានអារម្មណ៍ថាមិនត្រូវ។

ដូច្នេះខ្ញុំក៏បានដាក់ប៊ិចមកលើស្លឹកសៀវភៅដោយអំណរ ហើយភ្លាមនោះខ្ញុំមានគំនិតទាំងសទាំងខ្មៅ ដោយទីបំផុតខ្ញុំមានវិធីធ្វើរបស់ខ្ញុំ។ នៅពេលដែលខ្ញុំទាញវាមក នោះវាក៏ចេញមក ហើយខ្ញុំក៏សរសេរវាចុះ ហើយរហូតទាល់តែវាចេញមកនៅពេលចុងក្រោយ ដែលមានបណ្ដោយមានទទឹងនិងទំហំដែលអ្នកបានឃើញនេះឯង។

មែនហើយ ពេលដែលខ្ញុំផ្គុំវាជាមួយនឹងសេចក្ដីបញ្ចប់ ខ្ញុំបានបង្ហាញវាទៅកាន់អ្នកផ្សេងទៀត ដើម្បីឱ្យខ្ញុំដឹងថាអ្នកណានឹងកាត់ទោសវា ហើយអ្នកណាដែលយល់ស្រប។ ហើយអ្នកខ្លះនិយាយថា "យ៉ូហាន ចូរព្រីនវាចេញមក" ហើយអ្នកខ្លះទៀតក៏និយាយថា "កុំព្រីនវាធ្វើអី" អ្នកខ្លះនិយាយថា "វានឹងជួយបានជាច្រើន" ហើយអ្នកខ្លះទៀតនិយាយថា "មិនល្អទេ"។

ឥលូវតើខ្ញុំមានភាពស្រពិចស្រពិល ដោយមិនដឹងថាអ្វីជាអ្វីដែលខ្ញុំសម្រេចបានតើមែនទេ? ជាចុងក្រោយខ្ញុំបានគិតថា ក្នុងកាលដែលអ្នកតែងតែបែងចែកគ្នា នោះខ្ញុំនឹងព្រីនវាចេញមក។ ហើយវាជាសេចក្ដីដែលខ្ញុំបានសម្រេចចិត្ត ដោយខ្ញុំបានឃើញថាមនុស្សមួយចំនួនចង់ឱ្យខ្ញុំព្រីនវាចេញមក បើទោះជាអ្នកផ្សេងទៀតដែលនៅក្នុងចរន្តនោះមិនព្រមធ្វើក៏ដោយ។ ដើម្បីបញ្ជាក់ថាអ្នកណាដែលបានផ្ដល់យោបល់ដ៏ល្អ នោះខ្ញុំក៏បានដាក់ធ្វើការសាកល្បងមើល។

ខ្ញុំក៏បានគិតបន្ថែមទៀតថា ប្រសិនបើពេលនេះខ្ញុំបានបដិសេធអ្នកដែលចង់ធ្វើវាឱ្យបានគាប់ចិត្ត ខ្ញុំមិនដឹងថាខ្ញុំបែរជាអាចរារាំងពួកគពីអ្វីដែលនឹងធ្វើឲ្យពួកគេកាន់តែអំណរនោះដែរទេ។

សម្រាប់អ្នកដែលមិនចង់ឃើញវាព្រីនចេញមក នោះខ្ញុំនិយាយទៅកាន់ពួកគេថា "ខ្ញុំមិនចង់ធ្វើឲ្យអ្នកមានចិត្តរកាំរកុះនោះទេ តែក្នុងកាលដែលបងប្អូនប្រុសស្រីរបស់អ្នកចូលចិត្តវា នោះសូមអ្នកស៊ូទ្រាំទ្រសិនទម្រាំទាល់តែអ្នកអាចមើលឃើញលើសពីនេះ"

ប្រសិនបើអ្នកមិនព្រមអានទេ នោះក៏ទុកវាចោលទៅ។ អ្នកខ្លះចូលចិត្តញ៉ាំសាច់ ហើយខ្លះទៀតក៏ជ្រើសយកឆ្អឹង។ បាទ ខ្ញុំគួរតែធ្វើវាឱ្យបានសមរម្យដោយខ្ញុំបានសរសេរដោយមានទាំងការបកស្រាយផង។

ខ្ញុំអាចនឹងមិនសរសេរនៅក្នុងទម្រង់ និងវិធីសាស្ត្រនេះ តែខ្ញុំមិនខាននឹងធ្វើអ្វីដែលល្អសម្រាប់អ្នកនោះទេ។ ហេតុអ្វីដែលការសរសេរនេះមិនគួរសម្រេចចេញមក? ពពកខ្មៅនាំភ្លៀងមក តែពពកភ្លឺថ្លាគ្មានភ្លៀងសោះ។ ពិតណាស់ទោះងងឹតឬភ្លឺ ប្រសិនបើពួកគេធ្វើឲ្យប្រាក់របស់គេធ្លាក់ចុះមក ដោយមានបង្កើតផលផ្លែ នោះចូរសរសើរដល់ទាំងពីរនោះ ហើយក៏មិនបានត្រីពីខាងណានោះទេ តែបានផ្ទុកនូវកំណាប់ដែលជាផលផ្លែដែលពួកគេបង្កើតមកជាមួយគ្នានោះ។ ដូច្នេះក៏បញ្ចូលទាំងពីរចូលគ្នា ដើម្បីឲ្យផលផ្លែរបស់នាងមិនអាចនឹងកាត់ផ្ដាច់ចេញពីគ្នាបាន ហើយវានឹងល្អបំផុតនៅពេលដែលអ្នកឃ្លាន។ ប៉ុន្តែប្រសិនបើនាងឆ្អែតហើយ នាងនឹងខ្ពាក់ចេញទាំងពីរ ហើយធ្វើឲ្យព្រះពររបស់វាទៅជាឥតប្រយោជន៍។

អ្នកបានដឹងពីរបៀបដែលអ្នកនេសាទធ្វើដើម្បីនឹងបានត្រីហើយ តើពួកគេបានប្រើឧបករណ៍អ្វីខ្លះ។ មើលពីរបៀបដែលគាត់ប្រើនូវភាពវ័យឆ្លាតរបស់គាត់ទាំងប៉ុន្មាន រួមទាំងអន្ទាក់របស់គាត់ ខ្សែសៃ ជ្រុង សន្ទូច និងមងរបស់គាត់។ តែគាត់មិនបានស្ទូចឬដាក់វាយនៅទីនោះ មិនមានអន្ទាក់ មិនមានមង មិនមានឧបករណ៍អ្វីដែលអ្នកធ្វើ។ ត្រូវតែស្វាស់ស្វែងរករបស់ទាំងនោះ ហើយចាក់រកផងដែរ មិនដូច្នោះទេអ្នកនឹងមិនចាប់បានអ្វីទាំងអស់ មិនថាអ្នកធ្វើយ៉ាងណានោះទេ។

ព្រានព្រៃនឹងចាប់បានសត្វព្រៃបាន ដោយវិធីសាស្ត្រផ្សេងៗ ដែលរាប់ឈ្មោះមិនអស់។ មានទាំងកាំភ្លើង សំណាញ់ មែកក្រូច ភ្លើង និងកណ្ដឹង។ គាត់ដើរលបៗ គាត់ដើរទៅ គាត់ឈរ។ ហើយតើអ្នកណាអាចនឹងរៀបរាប់ពីសភាពរបស់គាត់បាន? ប៉ុន្តែមិនមានរបស់ណាមួយដែលអាចនឹងធ្វើឲ្យគាត់ក្លាយជាម្ចាស់លើសត្វណាដែលគាត់ចូលចិត្តនោះទេ។ គាត់ត្រូវតែផ្លុំសម្លេង ហើយហួចដើម្បីនឹងចាប់វាបាន តែប្រសិនបើគាត់ធ្វើអីចឹង គាត់នឹងមិនចាប់បានសត្វស្លាបនោះទេ។

ប្រសិនបើគុជនៅក្នុងក្បាលគីង្គក់ ហើយក៏មាននៅក្នុងស្នូករបស់សត្វអយស្ទ័រ។ ប្រសិនបើការណាដែលមិនប្រាកដប្រជាថានឹងបានមាសទេ តើអ្នកណានឹងមិនសួរអើពើនឹងមើលថាអាចនឹងមានវានៅទីនោះ ដែលគេនឹងរកឃើញមែន? ឥលូវនេះសៀវភៅតូចរបស់ខ្ញុំនេះ (បើទោះជាមិនមានការផាត់ពណ៌ទាំងនោះដែលនឹងធ្វើឡើងដោយនេះ ឬអ្នកផ្សេងទៀតយក) ក៏វាមិនខ្លះនូវការដែលលេចធ្លោរជាងអ្វីដែលគ្រាន់តែក្លាហានហើយមិនមានទំនោរនោះទេ។ ពិតណាស់ ខ្ញុំមិនទាន់ស្អប់ចិត្តពេញលេញនោះទេនៅពេលដែល

សៀវភៅនេះនឹងឈរនៅពេលដែលត្រូវបានសាកល្បងយ៉ាងត្រឹមត្រូវ "ហេតុអ្វី តើជាបញ្ហាអ្វីទៅ?" "វាងងឹត" "តើវាជាអ្វីទៅអីចឹង?" "ប៉ុន្តែវាធ្វើពុតដូចជាឈើ" "ហើយវាយ៉ាងម៉េចចោះ?" ខ្ញុំtrow មនុស្សមួយចំនួនដោយពាក្យពុតដូចពាក្យរបស់ខ្ញុំដែរ ដែលធ្វើឲ្យសេចក្តីពិតបានតុបតែងស្រស់ស្អាត ហើយឲ្យពន្លឺរបស់វាបានចែងចាំងមក។ "ប៉ុន្តែពួកគេត្រូវការភាពរឹងមាំ" "ចូរអ្នកនិយាយអ្វីដែលចេញពីគំនិតមក" "នោះពួកគេនឹងចុះខ្សោយ ពាក្យប្រៀបប្រដូចធ្វើឲ្យយើងខ្វាក់"

ភាពរឹងមាំពិតណាស់ក្លាយជាប៊ិចរបស់អ្នកដែលសរសេរការអំពីព្រះទៅកាន់មនុស្ស ប៉ុន្តែតើខ្ញុំត្រូវការភាពរឹងមាំដែរទេ ដោយសារខ្ញុំនិយាយពាក្យប្រៀបប្រដូច? តើក្រឹត្យវិន័យរបស់ព្រះមិនមែនជាច្បាប់នៃដំណឹងល្អ ដែលនៅក្នុងគ្រាពីដើមដែលមានទម្រង់ជាប្រភេទផ្សេងៗ ជាស្រមោល និងជាការប្រៀបប្រដូចទេឬយ៉ាងណា? តែមិនមានមនុស្សណាដែលអាចរកកំហុសពីការទាំងនោះបានឡើយ មិនដូច្នោះគាត់នឹងត្រូវរកឃើញថាបានប្រមាថដល់ប្រាជ្ញាដ៏ខ្ពស់បំផុតហើយ។ ទេ គាត់គួរតែបង្អង់មើល ហើយស្វែងរកនូវអ្វីដែលភ្ជាប់និងថ្កក់ដែលភ្ជាប់ទៅ ដោយការកូនគោនិងចៀម ដោយគោញី និងដោយចៀមឈ្មោល ដោយបក្សីនិងរុក្ខជាតិ ហើយដោយឈាមរបស់ចៀមឈ្មោលនោះព្រះមានបន្ទូលទៅគាត់។ ហើយគាត់សប្បាយចិត្តដែលបានរកឃើញពន្លឺនិងព្រះគុណនៅក្នុងរបស់ទាំងនោះ។

ដូចនេះសូមកុំសរុបសេចក្តីត្រង់ពេកថាខ្ញុំចង់បានភាពរឹងមាំ ដែលថាខ្ញុំឈ្លើយ។ គ្រប់ការទាំងអស់ដែលបង្ហាញមកមិនរឹងមាំនោះទេ។ គ្រប់ការទាំងអស់

ជាប្រស្នាដែលយើងមិនមើលស្រាល បើមិនដូច្នោះយើងនឹងទទួលបានការដែលអាក្រក់វិញ ហើយនឹងការដែលធ្វើឱ្យព្រលឹងរបស់យើងខាតបង់វិញ។

ពាក្យដែលងងឹតនិងពេញដោយពពករបស់ខ្ញុំ ជាពាក្យដែលកាន់ជាប់សេចក្តីពិតប្រៀបបីដូចជាទូរដែលស្រោបដោយមាសផងដែរ។

ហោរាបានប្រើប្រាស់ការប្រៀបប្រដូចជាច្រើន ដើម្បីបង្ហាញប្រាប់ពីសេចក្តីពិត។ ជាការដែលទាក់ទងនឹងព្រះគ្រីស្ទ សាវករបស់ទ្រង់ផងដែរ នឹងមើលឃើញយ៉ាងច្បាស់ថាសេចក្តីពិតមកសព្វថ្ងៃនេះជាការចម្បង។

តើខ្ញុំក្លាចនឹងនិយាយថាព្រះគម្ពីរបរិសុទ្ធដែលមានបែបបទនិងឃ្លោងឃ្លារបស់ខ្លួន ត្រូវបានសរសេរចុះដោយច្បាស់លាស់ តើគ្រប់ទីកន្លែងសុទ្ធតែពេញទៅដោយការទាំងនេះឬ ដែលជារូបភាពងងឹត ជាអត្ថប្បដិរូប (ដូចជាកំណាព្យ ឬរូបភាពដែលមានបង្កប់ន័យ) តែវាបានរីកសាយចេញពីសៀវភៅតែមួយ ដែលនៅជាប់ ហើយរស្មីនៃពន្លឺទាំងនោះដែលបានប្រែយប់ដ៏ងងឹតនៅថ្ងៃនេះផងឬ?

ចូរមកហើយមើលមកកាន់ការលាតត្រដាងរបស់ខ្ញុំទៅនឹងជីវិតរបស់គាត់ ហើយស្វែងរកបន្ទាត់ដែលងងឹតជាងអ្វីដែលនៅក្នុងសៀវភៅរបស់ខ្ញុំនៅទីនោះ។ គាត់នឹងរកឃើញអ្វីមួយចំនួន ហើយគាត់នឹងដឹងថាទោះជានៅក្នុងការដ៏ល្អបំផុតរបស់គាត់ ក៏នៅតែមានបន្ទាត់ដែលអាក្រក់ផងដែរ។ សូមឲ្យយើងអាចឈរនៅចំពោះមនុស្សដែលមិនលំអៀង ទៅកាន់អ្នកដែលក្រ ខ្ញុំហ៊ានផ្សងព្រេងដប់ ថាពួកគេនឹងយល់អត្ថន័យនៅក្នុងល្បះនេះ ប្រសើរជាងការកុហករបស់គាត់នៅក្នុងអាស្រមប្រាក់ទៅទៀត។ ចូរមក សេចក្តីពិត បើ

ទោះជានៅក្នុងសំបករុំដ៏រឹងក៏ដោយ ខ្ញុំនៅតែរកឃើញវាប្រាប់ថាមានការកាត់ទោស វាកែតម្រូវការគិត វាគាប់ចិត្តនឹងចំណេះដឹង វាធ្វើឲ្យមានចិត្តចុះចូល ការចង់ចាំក៏ពេញដោយអ្វីដែលការស្រមើស្រម៉ៃពេញចិត្តដែរ។ ដូច្នេះវានឹងធ្វើឲ្យបញ្ហារបស់យើងបានរសាយទៅ។

ពាក្យដែលត្រឹមត្រូវដែលខ្ញុំដឹងថាធីម៉ូថេត្រូវតែប្រើ និងរឿងព្រេងរបស់ប្រពន្ធចាស់ៗដែលគាត់ត្រូវបដិសេធ។ ប៉ុន្តែលោកប៉ុលមិនបានថែងថាមិនឲ្យប្រើប្រាស់ប្រស្នា ដែលស្រោបទុកនូវមាស គុជ និងថ្មដែលមានតម្លៃទាំងនោះ ដែលសាកសមនឹងការជីកស្វែងរក ទាំងមានការប្រុងប្រយត្នដ៏ខ្ពស់ផងដែរ។

សូមឲ្យខ្ញុំបានបន្ថែមពាក្យមួយថែមទៀតថា ឱមនុស្សរបស់ព្រះអម្ចាស់អើយ តើអ្នករកាំចិត្តមែនទេ? តើអ្នកសង្ឃឹមថាខ្ញុំនឹងទាញបញ្ហារបស់ខ្ញុំមកនៅក្នុងសំលៀកបំពាក់ផ្សេងឬយ៉ាងណា? ឬក៏ថាខ្ញុំមានអ្វីលើសពីនោះដែលត្រូវពន្យល់បង្ហាញ? មានការបីយ៉ាងដែលខ្ញុំចង់ពន្យល់បកស្រាយ បន្ទាប់មកខ្ញុំនឹងផ្តល់ដល់អ្នកទាំងនោះដែលប្រសើរជាងខ្ញុំបើសមរម្យ។

1. ខ្ញុំរកឃើញថាខ្ញុំត្រូវបានបដិសេធនូវការប្រើប្រាស់វិធីសាស្រ្តរបស់ខ្ញុំ ដូច្នេះខ្ញុំមិនបានបំភ្លៃ តែបានសរសេរជាពាក្យពេចន៍ រឿងរ៉ាវ អ្នកអាន ហើយខ្ញុំមិនបានឈ្លើយនៅក្នុងការទប់ទល់រូបភាពនិងភាពដែលស្រដៀងនោះ នៅក្នុងការដាក់អនុវត្តនោះទេ។ ប៉ុន្តែគ្រប់ទាំងអ្វីដែលខ្ញុំនឹងស្វែងរកនោះគឺជាសេចក្តីពិតដែលជ្រៅថែមទៀតដោយវិធីនេះឬវិធីនោះ។ តើខ្ញុំបាននិយាយបដិសេធដែរទេ? ទេ ខ្ញុំបានទុកចោល (ឧទាហរណ៍ផងដែរ ហើយអ្វីចេញពីនោះដែលព្រះសព្វព្រះទ័យជាង

ដោយពាក្យសំដី និងរបៀបរបស់ពួកគេជាងអ្នកណាទាំងអស់ដែល ដកដង្ហើមសព្វថ្ងៃនេះ) ដូច្នេះគឺដើម្បីនឹងបង្ហាញគំនិតរបស់ខ្ញុំ ដែលប្រកាសការទាំងនោះទៅកាន់អ្នកដោយឥតខ្ចោះបំផុត។

2. ខ្ញុំរកឃើញថាមនុស្ស (ដែលខ្ពស់ដូចជាដើមឈើ) នឹងសរសេរការសន្ទនា តែគ្មានអ្នកណានឹងធ្វើបន្តិចបន្តួចដើម្បីនឹងសរសេរបែបនោះបាននោះទេ។ ពិតណាស់ ប្រសិនបើពួកគេបំភ្លៃសេចក្តីពិត នោះពួកគេនិងរបស់ប្រើប្រើរបស់ពួកគេនឹងត្រូវបណ្តាសា តែចូរឲ្យសេចក្តីពិតមានសេរីភាពនៅក្នុងការធ្វើឲ្យឱជារសរបស់នាងបានមកកាន់អ្នក និងខ្ញុំនៅក្នុងបែបបទដែលព្រះសព្វព្រះហឫទ័យ ដោយសារតើមានអ្នកណាទៀតដែលដឹងប្រសើរជាងទ្រង់ ដែលអ្នកដែលបង្រៀនការទាំងនោះឲ្យចេះភ្ជួរដី ដែលបានដឹកនាំគំនិតរបស់យើងនិងប៊ិចសម្រាប់ការឆ្លើយប៉ាន់របស់ទ្រង់ ហើយទ្រង់បានធ្វើឲ្យការដែលជាគ្រឹះសម្រាប់ជំនួយដល់ការរបស់ព្រះ។
3. ខ្ញុំរកឃើញថាព្រះគម្ពីរនៅក្នុងកន្លែងជាច្រើនមានលក្ខណៈស្រដៀងទៅនឹងវិធីសាស្ត្រនេះ ដែលមានការមួយចំនួនប្រាប់ពីការមួយដើម្បីនឹងបង្ហាញបីការមួយទៀត។ ខ្ញុំបានប្រើប្រាស់វា តែមិនមានអ្វីដែលធ្វើឲ្យគែមពីមាសរបស់សេចក្តីពិតត្រូវរង្គើរនោះទេ។ ដោយសារវិធីសាស្ត្រនេះបានធ្វើឲ្យរស្មីរបស់សេចក្តីពិតបានចែងចាំងមកភ្លឺដូចជាថ្ងៃ។

ហើយពេលនេះមុនពេលខ្ញុំដាក់ប៊ិចរបស់ខ្ញុំ ខ្ញុំនឹងបង្ហាញពីផលប្រយោជន៍នៃសៀវភៅរបស់ខ្ញុំ ហើយបន្ទាប់មកនឹងដាក់ទាំងអ្នកនិងវាទៅក្នុងដៃដែលអ្នកដែលខ្លាំងចុះ ហើយនឹងធ្វើឲ្យអ្នកដែលទន់ខ្សោយបានឈរឡើង។

សៀវភៅនេះសរសេរចេញនៅចំពោះភ្នែករបស់អ្នក ជាអ្នកដែលស្វែងរករង្វាន់ដែលនៅអស់កល្ប។ វាបង្ហាញអ្នកពីពេលដែលគេមក ទីកន្លែងដែលគេទៅ អ្វីដែលគេធ្វើមិនទាន់រួច អ្វីដែលគេធ្វើ វាក៏បង្ហាញអ្នកពីរបៀបដែលគេរត់ ហើយរត់រហូតដល់គេបានទៅដល់ឃ្លោងទ្វារនៃសិរីល្អបានមកដល់។ វាបង្ហាញផងដែរនរណាដែលចេញទៅរកជីវិតជាចម្បង ដែលហាក់ដូចជាមកុដដែលនៅអស់កល្បដែលគេនឹងទទួលបាន។ នៅទីនេះអ្នកនឹងឃើញផងដែរនូវហេតុផលថាហេតុអ្វី ដែលពួកគេបាត់បង់ការខំប្រឹងប្រែងដូចជាមនុស្សល្ងង់ដែលត្រូវស្លាប់។

សៀវភៅនេះនឹងធ្វើឲ្យការធ្វើដំណើររបស់អ្នក ប្រសិនបើអ្នកត្រូវបានគ្រប់គ្រង់ដោយយោបល់របស់វា វានឹងចង្អុលបង្ហាញអ្នកទៅកាន់ទឹកដីបរិសុទ្ធ។ ប្រសិនបើអ្នកអ្នកយល់ពីការដឹកនាំរបស់វា នោះវានឹងធ្វើឲ្យអ្នកខ្ជិលទៅជាសកម្មវិញ ហើយអ្នកខ្វាក់នឹងមើលឃើញការដែលពេញដោយអំណរផង។

តើអ្នកទន្ទឹងចង់បានការដែលកម្រនិងមានប្រយោជន៍មែនទេ? តើអ្នកមើលឃើញសេចក្តីពិតនៅក្នុងរឿងព្រេងឬយ៉ាងណា? អ្នកពូកែភ្លេចមែនទេ? តើអ្នកអាចចង់ចាំពីថ្ងៃចូលឆ្នាំថ្មីរហូតដល់ថ្ងៃចុងក្រោយនៃខែធ្នូដែរទេ? ដូច្នេះចូរអានការសរសេររបស់ខ្ញុំ នោះវានឹងនៅជាប់ដូចជាជ័រការដូចជាអ្នកជួយរំលែកទុក្ខដល់អ្នកដែលខ្វះជំនួយផង។

សៀវភៅនេះត្រូវបានសរសេរឡើងនៅក្នុងភាសាបែបនេះ ដែលមានឥទ្ធិពលដល់គំនិតរបស់មនុស្សរាប់មិនអស់។ វាប្រៀបបីដូចជារឿងប្រលោមលោក តែវាមិនផ្ទុកអ្វីក្រៅពីដំណឹងល្អដ៏ត្រឹមត្រូវនិងស្មោះត្រង់តែប៉ុណ្ណោះ។

តើអ្នកនឹងបង្វែរខ្លួនរបស់អ្នកចេញពីភាពស្រងេះស្រងោចទេ តើអ្នកនឹងពេញចិត្តនៅឆ្ងាយពីភាពល្ងង់ខ្លៅដែរទេ? តើអ្នកនឹងអានប្រស្នា និងសេចក្តីពន្យល់របស់វា ហើយបើមិនពុំនោះទេនឹងត្រូវលង់នៅក្នុងការសញ្ជឹងគិតរបស់អ្នកឬ? តើអ្នកចូលចិត្តរើសយកសាច់ឬ? ឬអ្នកចង់មើលទៅកាន់បុរសម្នាក់នៅក្នុងពពក ហើយស្តាប់សម្លេងរបស់ទ្រង់និយាយមកកាន់អ្នក? តើអ្នកចង់នៅក្នុងការយល់សប្តិ តែមិនបានដេកលក់ដែរទេ? ឬអ្នកចង់នៅក្នុងពេលមួយដែលមានការយំសោកផងនិងសើចផងឬ? តើអ្នកចង់បាត់បង់ខ្លួនអ្នកហើយមិនមានគ្រោះថ្នាក់អ្វីទាំងអស់ដែរទេ? ហើយរកឃើញខ្លួនឯងម្តងទៀតដែលមិនមានមន្តស្នេហ៍សោះដែរទេ? ដែលស្គាល់ខ្លួនឯងនិងអានហើយមិនដឹងអ្វីសោះ តែដឹងថាអ្នកមានពរឬអត់ ដោយអាននៅជួរតែមួយ? អូរួចមក ចូរមកនេះហើយដាក់សៀវភៅរបស់ខ្ញុំនៅក្នុងចិត្តនិងក្បាលផង។
***JOHN BUNYAN.***

## សេចក្តីផ្តើម

នៅពេលដែលខ្ញុំដើរកាត់វាលរហោស្ថាននៃពិភពលោកនេះ ខ្ញុំបានដុតបំភ្លឺទៅកន្លែងមួយដែលមានរូងសត្វ (ជាគុក) ហើយខ្ញុំបានផ្តេកខ្លួនខ្ញុំដេកនៅទីនោះ។ ហើយនៅពេលដែលខ្ញុំដេក ខ្ញុំបានយល់សុបិន្តមួយ។ ខ្ញុំសុបិន្តឃើញខ្ញុំសម្លឹងមើលទៅឃើញបុរសម្នាក់ស្លៀកពាក់កន្ទបឈរនៅកន្លែងមួយ ដោយមុខរបស់គាត់បែរទៅកាន់ផ្ទះរបស់គាត់ ដៃគាត់មានសៀវភៅមួយ ហើយមានបន្ទុកមួយយ៉ាងធំនៅលើខ្នងរបស់គាត់។ ខ្ញុំបានមើលទៅ ហើយឃើញគាត់បើកសៀវភៅ ហើយក៏អាន។ ហើយនៅពេលដែលគាត់អាន គាត់យំទួញ ហើយភ័យញ័រ។

"ដ្បិតអំពើទុច្ចរិតរបស់ទូលបង្គំ បានឡើងលិចក្បាលទូលបង្គំហើយ ក៏ដូចជាបន្ទុកយ៉ាងធ្ងន់ ដែលទូលបង្គំទ្រាំមិនបាន។" ទំនុកដំកើង 38:4

"ដ្បិតយើងទាំងអស់គ្នាបានត្រឡប់ទៅដូចជាមនុស្ស ដែលមិនស្អាត ហើយអស់ទាំងអំពើសុចរិតរបស់យើងខ្ញុំ ក៏ដូចជាអាវកខ្វក់ហើយ យើងខ្ញុំរាល់គ្នាស្វិតក្រៀមទៅដូចជាស្លឹកឈើ ហើយអំពើទុច្ចរិតរបស់យើងខ្ញុំ ក៏ផាត់យកយើងទៅដូចជាខ្យល់។" អេសាយ 64:6

"ដូច្នេះ អស់អ្នកណាក្នុងពួកអ្នករាល់គ្នាដែលមិនលះអាល័យពីរបស់ទ្រព្យខ្លួនទាំងអស់ នោះធ្វើជាសិស្សខ្ញុំមិនបានទេ។" លូកា 14:33

"ដ្បិតបើសិនជាគ្រប់ទាំងព្រះបន្ទូលដែលពួកទេវតាបានពោលនោះ បានឃើញថាពិតមែន ហើយគ្រប់ទាំងអំពើរំលង និងសេចក្តីរឹងចចេសក៏ត្រូវទោសចំពោះ នោះធ្វើដូចម្តេចឱ្យយើងរួចបាន បើយើងធ្វេសនឹងសេចក្តីសង្គ្រោះដ៏ធំ

ម្ល៉េះ ដែលព្រះអម្ចាស់បានចាប់ផ្តើមផ្សាយមក រួចពួកអ្នកដែលឮ ក៏បានបញ្ជាក់មកយើងរាល់គ្នាដែរ។" ហេព្រើរ 2:2, 3

ហើយរហូតទាល់តែគាត់ទ្រាំលែងបាន គាត់ក៏ស្រែកទ្រហោរយំហើយនិយាយថា "តើខ្ញុំត្រូវធ្វើយ៉ាងណា?"

"កាលគេបានឮ នោះគេមានសេចក្តីចាក់ចុចក្នុងចិត្ត ក៏សួរពេត្រុស និងពួកសាវកឯទៀតថា បងប្អូនអើយ តើយើងត្រូវធ្វើដូចម្តេច" កិច្ចការ 2:37

ដូច្នេះនៅក្នុងសភាពដ៏សោកសៅនេះ គាត់បានត្រឡប់ទៅផ្ទះ ហើយគាត់បញ្ឈប់ខ្លួនគាត់ដោយមិនបង្ហាញដល់គេតាមដែលគាត់អាចធ្វើបាន ដើម្បីកុំឲ្យប្រពន្ធនិងកូនៗរបស់គាត់ដឹងពីទុក្ខលំបាករបស់គាត់ ប៉ុន្តែគាត់មិនអាចនៅស្ងៀមយូរនោះទេ ដោយសារទុក្ខលំបាករបស់គាត់កាន់តែកើនឡើង។ ដូច្នេះគាត់បានបង្ហាញគំនិតរបស់គាត់ទៅកាន់ប្រពន្ធកូន។ ដូច្នេះគាត់ក៏ចាប់ផ្តើមនិយាយជាមួយពួកគេ "ឱប្រពន្ធសំឡាញ់បងអើយ" "ហើយកូនៗនៃពោះវៀនពោះតាំងរបស់អញអើយ ខ្ញុំនេះដែលជាសំឡាញ់របស់អ្នកនឹងត្រូវវិនាសហើយ ដោយហេតុថាមានបន្ទុកដែលធ្លាក់មកលើខ្ញុំ។ លើសពីនោះទៀត ខ្ញុំបានឮថា ទីក្រុងរបស់យើងនឹងត្រូវដុតបំផ្លាញដោយភ្លើងមកពីស្ថានសួគ៌ ដែលទាំងខ្ញុំផ្ទាល់និងអ្នកទាំងអស់គ្នាដែលជាប្រពន្ធនិងកូនត្រូវបោះទំលាក់ទៅ ហើយនឹងត្រូវវិនាសយ៉ាងវេទនា។ លើកលែងតែ (ការដែលខ្ញុំមិនបានឃើញ) ផ្លូវមួយចំនួនសម្រាប់នឹងគេចខ្លួនត្រូវបានរកឃើញ នោះទើបយើងនឹងត្រូវបានរំដោះឲ្យរួច។" ដោយការនោះទំនាក់ទំនងរបស់គាត់ត្រូវបានមានការភ្ញាក់ផ្អើលយ៉ាងខ្លាំង ពួកគេបានជឿថាអ្វីដែលកាត់បាននិយាយ

ថាជាការពិតមិនមែនដោយការនោះនោះទេ ប៉ុន្តែដោយសារពួកគេបានគិតថាគាត់មានជំងឺវក់នៅក្នុងក្បាលរបស់គាត់។ ដូច្នេះ យប់ក៏ជិតមកដល់ ហើយពួកគេសង្ឃឹមថាការដេកនឹងជួយឲ្យខួរក្បាលរបស់គាត់បានសំរាក ពួកគេក៏ប្រញាប់នឹងនាំគាត់ទៅដេកសម្រាក ប៉ុន្តែពេលយប់នៅតែធ្វើឲ្យមានបញ្ហាដល់គាត់ដូចជាពេលថ្ងៃដែរ។ ដូច្នេះជំនួសឲ្យការដេក គាត់បានចំណាយពេលនឹងដកដង្ហើមធំលាយនឹងទឹកភ្នែក។ ដូច្នេះ នៅពេលព្រឹកមកដល់ ពួកគេបានដឹងនូវអ្វីដែលគាត់បានធ្វើ។ គាត់បានប្រាប់ពួកគេថា "កាន់តែអាក្រក់ឡើងៗ" គាត់បានព្យាយាមនិយាយទៅកាន់ពួកគេម្តងទៀត ហើយពួកគេក៏កាន់តែចចេសឡើង។ ពួកគេក៏បានគិតថានិងបណ្តេញនូវជំងឺពីគាត់ចេញ ដោយប្រើពាក្យអាក្រក់ៗនិងកាយវិការគំរោះគំរើយទៅកាន់គាត់។ ជួនកាលពួកគេមើលងាយ ជួនកាលស្តីបន្ទោស ហើយពេលខ្លះទៀតពួកគេធ្វើមិនដឹងមិនឮពីគាត់។ ដូច្នេះគាត់ក៏ចាប់ផ្តើមសម្រាកនៅក្នុងបន្ទប់របស់គាត់ ដើម្បីនឹងអធិស្ឋាននិងអាណិតអាសូរដល់ពួកគេ ហើយដើម្បីនឹងបានរំសាយខ្លួនគាត់ពីទុក្ខលំបាក់របស់គាត់។ គាត់ក៏បានដើរតែឯងនៅឯវាល ជួនកាលអាន ជួនកាលអធិស្ឋាន ហើយគាត់បានចំណាយពេលជាច្រើនថ្ងៃធ្វើការបែបនោះ។

## អ្នកផ្សាយដំណឹងល្អផ្តល់នូវទិសដៅ

ពេលនេះខ្ញុំបានឃើញ ពេលមួយដែលគាត់កំពុងដើរនៅទីវាល ដែលកាត់កំពុងអានសៀវភៅរបស់គាត់ ហើយដែលមានពេញដោយទុក្ខលំបាកនៅក្នុងគំនិតរបស់គាត់ផង។ ហើយនៅពេលដែលគាត់អាន គាត់ក៏បានស្រែករហោរយំឡើងដូចសព្វដង ដោយនិយាយថា "តើខ្ញុំត្រូវធ្វើដូចម្តេចដើម្បីបានសង្គ្រោះ?"

**"គាត់បាននាំគេចេញទៅក្រៅសួរថា លោកម្ចាស់អើយ តើត្រូវឱ្យខ្ញុំធ្វើដូចម្តេចឱ្យបានសង្គ្រោះផង។ គេក៏ប្រាប់គាត់ថា ចូរជឿដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទទៅ នោះនឹងបានសង្គ្រោះហើយ ព្រមទាំងគ្រួសារលោកផង។" កិច្ចការ 16:30,**

ខ្ញុំក៏បានឃើញថាគាត់បានសម្លឹងទៅផ្លូវនេះផ្លូវនោះ ដូចគាត់បម្រុងនឹងរត់អីចឹង។ តែគាត់បានឈរនៅស្ងៀម ដោយសារ (តាមដែលខ្ញុំយល់ឃើញ) គាត់មិនដឹងថានឹងត្រូវទៅផ្លូវណានោះទេ។ ខ្ញុំក៏មើលទៅមើលឃើញបុរសម្នាក់ឈ្មោះ អ្នកផ្សាយដំណឹងល្អដើរមកកាន់គាត់ ហើយសួរថា "តើអ្នកយំធ្វើអ្វី?" គាត់បានឆ្លើយថា "លោកអើយ ខ្ញុំបានដឹងតាមរយៈសៀវភៅនៅក្នុងដៃរបស់ខ្ញុំថា ខ្ញុំនឹងត្រូវទទួលការដាក់ទោសឱ្យត្រូវស្លាប់ ហើយបន្ទាប់មកទទួលការជំនុំជំរះ"

**"ហើយដោយព្រោះបានដំរូវ ត្រូវឱ្យមនុស្សទាំងអស់ស្លាប់មួយដង រួចសឹមជាប់សេចក្តីជំនុំជំរះ" ហេព្រើរ 9:27**

ហើយខ្ញុំបានយល់ឃើញថាខ្ញុំមិនស្ម័គ្រចិត្តនឹងធ្វើការទីមួយនោះទេ

**"កូនចៅរបស់គេមានកិត្តិយសឡើង តែគេមិនដឹងទេ វាត្រូវបន្ទាបចុះ តែគេមិនសំគាល់ដឹងអ្វីសោះ។ គេដឹងឈឺតែចំពោះខ្លួនគេ ហើយមានសេចក្ដីទុកព្រួយតែចំពោះចិត្តខ្លួនប៉ុណ្ណោះ។" យ៉ូប 14:21, 22**

ហើយក៏មិនអាចនឹងធ្វើការទីពីរបានដែរ។"

**"តើចិត្តឯងនឹងធន់នៅបាន ហើយដៃឯងនឹងមានកំលាំង នៅថ្ងៃដែលអញធ្វើទោសដល់ឯងបានឬ អញគឺព្រះយេហូវ៉ានេះ អញបានចេញវាចាហើយ ក៏នឹងសម្រេចតាមផង។" អេសេគាល 22:14**

អ្នកផ្សាយដំណឹងល្អ៖ អ្នកផ្សាយដំណឹងល្អក៏និយាយថា "ហេតុអ្វីបានជាមិនស្ម័គ្រចិត្តស្លាប់ ក្នុងកាលដែលជីវិតនេះពោរពេញទៅដោយការអាក្រក់ជាច្រើន?" បុរសនោះក៏ឆ្លើយថា "ពីព្រោះខ្ញុំក្លាចថាបន្ទុកមួយនេះដែលនៅលើខ្នងរបស់ខ្ញុំនឹងធ្វើឲ្យខ្ញុំលង់កាន់តែជ្រៅជាងផ្នូរខ្មោច ហើយខ្ញុំនឹងធ្លាក់ទៅក្នុងស្ថាននរក។"

**"ដ្បិតទីដុតខ្មោចត្រៀមទុកតាំងពីបុរាណមក អើ ទីនោះបានរៀបចំសម្រាប់ស្ដេចនោះឯង ជាទីយ៉ាងជ្រៅ ហើយធំទូលាយ មានឧសគរឡើងជាច្រើនពេញ ហើយដោយភ្លើង គឺជាអស្សាសៈនៃព្រះយេហូវ៉ា ដែលដូចជាជ្រោះស្ពាន់ធ័រហូរមកបង្កាត់ភ្លើងនោះ។" អេសាយ 30:33**

ហើយលោកប្រុសអើយ ប្រសិនបើខ្ញុំមិនសាកសមនឹងទៅក្នុងគុក នោះខ្ញុំនឹងមិនសមទេ ខ្ញុំដឹងប្រាកដណាស់ថានឹងត្រូវទទួលការជំនុំជំរះ ហើយចេញពីនោះមកនឹងមានការធ្វើទោស ហើយគ្រាន់តែគិតពីការនេះធ្វើឱ្យខ្ញុំយំ។"

បន្ទាប់មកអ្នកផ្សាយដំណឹងល្អបាននិយាយថា "ប្រសិនបើនេះជាសភាពរបស់អ្នក ហេតុអ្វីបានជានៅឈរស្ងៀម?" គាត់ក៏ឆ្លើយថា "ពីព្រោះខ្ញុំមិនដឹងថានឹងត្រូវទៅណា" បន្ទាប់មកគាត់បានឱ្យក្រាំងស្បែកដែលមូរទៅគាត់ ហើយនៅក្នុងនោះមានសរសេរថា "ចូរគេចចេញពីសេចក្ដីក្រោធដែលនឹងត្រូវមកដល់!"

**"តែកាលគាត់ឃើញពួកផារីស៊ី និងពួកសាឌូសី មកទទួលបុណ្យជ្រមុជពីគាត់ជាច្រើនដែរ នោះក៏សួរគេថា ឱពូជពស់វែកអើយ តើអ្នកណាបានប្រាប់ឱ្យអ្នករត់ចេញពីសេចក្ដីក្រោធដែលត្រូវមកដូច្នេះ?" ម៉ាថាយ 3:7**

ដូច្នេះបុរសនោះបានអានសៀវភៅនោះ ហើយបានមើលទៅកាន់គ្រប់យ៉ាងដែលអ្នកផ្សាយដំណឹងល្អបាននិយាយដោយប្រុងប្រយត្ន ហើយនិយាយថា "តើខ្ញុំត្រូវហោះទៅទីណា?" បន្ទាប់មកអ្នកផ្សាយដំណឹងល្អបាននិយាយ ហើយចង្អុលទៅកាន់ទីវាលដ៏ធំល្វឹងល្វើយថា "តើអ្នកមើលឃើញឃ្លោងទ្វារទុច្ចរិតដែរទេ?"

**"តែឯទ្វារដែលនាំទៅឯជីវិត នោះតូច ហើយចង្អៀតវិញ ក៏មានមនុស្សតិចណាស់ដែលរកផ្លូវនោះឃើញ។" ម៉ាថាយ 7:14**

បុរសនោះក៏និយាយថា "អត់ទេ" បន្ទាប់មកម្នាក់ទៀតនិយាយទៀតថា "តើអ្នកមើលឃើញពន្លឺដែលចាំងចែងនោះទេ?"

**"ព្រះបន្ទូលនៃទ្រង់ ជាចង្កៀងដល់ជើងទូលបង្គំ ហើយជាពន្លឺបំភ្លឺផ្លូវរបស់ទូលបង្គំ។" ទំនុកដំកើង 119:105**

**"ហើយយើងខ្ញុំមានពាក្យទំនាយដំពិតជាង ដែលគួរឱ្យអ្នករាល់គ្នាយកចិត្តទុកដាក់តាម ដូចជាតាមចង្កៀង ដែលភ្លឺក្នុងទីងងឹត ទាល់តែថ្ងៃភ្លឺឡើង ហើយផ្កាយព្រឹករះឡើងក្នុងចិត្តអ្នករាល់គ្នា។" ពេត្រុស ទី២ 1:19**

គាត់បាននិយាយថា "ខ្ញុំគិតថាខ្ញុំមើលឃើញ។" បន្ទាប់មកអ្នកផ្សាយដំណឹងល្អបាននិយាយថា "ចូររក្សាពន្លឺនោះនៅក្នុងភ្នែករបស់អ្នក ហើយដើរត្រង់ទៅមុខ។ ដូច្នេះអ្នកនឹងឃើញឃ្លោងទ្វារ ជាទ្វារដែលអ្នកនឹងគោះ ហើយវានឹងប្រាប់អ្នកនូវអ្វីដែលអ្នកត្រូវធ្វើ។"

ដូច្នេះខ្ញុំបានឃើញនៅក្នុងសុបិន្តថាបុរសនោះចាប់ផ្តើមរត់ទៅ។ ពេលនេះគាត់មិនទាន់បានរត់ឆ្ងាយចេញពីទ្វាររបស់គាត់នូវឡើយ តែប្រពន្ធនិងកូនៗរបស់គាត់បានដឹងពីការនោះ ពួកគេក៏យំស្រែកហៅគាត់ឱ្យត្រឡប់មកវិញ។

**"បើអ្នកណាមកឯខ្ញុំ ដោយមិនបានលះអាល័យពីឪពុកម្តាយ ប្រពន្ធកូន បងប្អូនប្រុសស្រី និងជីវិតខ្លួនឯងផង អ្នកនោះនឹងធ្វើជាសិស្សខ្ញុំមិនបានទេ។" លូកា 14:26**

ប៉ុន្តែបុរសនោះបានយកម្រាមដៃបិទត្រចៀករបស់គាត់ ហើយបន្តរត់ទៅទៀត ទាំងស្រែកឡើងថា "ជីវិត! ជីវិត! ជីវិតអស់កល្បជានិច្ច!" ដូចនេះគាត់មិនបានមើលមកក្រោយទេ តែគាត់បានរត់គេចទៅត្រង់រហូតដល់ពាក់កណ្ដាលនៃទីវាល។

**"កាលបាននាំចេញផុតទៅក្រៅហើយ នោះទេវតាប្រាប់ថា ចូររត់ទៅឱ្យបានរួចជីវិតចុះ កុំឱ្យមើលមកក្រោយឡើយ ក៏កុំឱ្យឈប់នៅស្រុកវាលឯណានីមួយផង ចូររត់ទៅឯភ្នំវិញ ក្រែងឯត្រូវវិនាសដែរ។" លោកុប្បត្តិ 19:17**

## អ្នកជិតខាង៖ លោកមានៈ និងលោកងាយបត់បែន

អ្នកជិតខាងក៏បានចេញមកក្រៅមកមើលគាត់រត់ទៅ ហើយនៅពេលដែលគាត់រត់នោះ មានអ្នកខ្លះសើចចំអកឱ្យ

**"ដ្បិតទូលបង្គំបានឮពាក្យបង្កាច់របស់មនុស្សជាច្រើនរបស់មនុស្សជាច្រើន ហើយមានសេចក្តីស្ញែងខ្លាចនៅព័ទ្ធជុំវិញ អស់ទាំងសំឡាញ់ស្និទ្ធស្នាលរបស់ទូលបង្គំ គេជាពួកអ្នកដែលចាំមើលតែទូលបង្គំដួលដែរ គេថា ចូរសប្រាប់ចុះ នោះយើងនឹងសប្រាប់ដូចគ្នា ប្រហែលជាយើងនឹងបញ្ចុះបញ្ចូលវាបានទេដឹង ដូច្នេះយើងនឹងឈ្នះវាបាន នោះយើងនឹងសងសឹកនឹងវា។" យេរេមា 20:10**

មានអ្នកផ្សេងទៀតបានគំរាមកំហែង ហើយខ្លះទៀតបានយំស្រែកហៅគាត់ឱ្យត្រលប់។ ហើយនៅក្នុងចំណោមអ្នកទាំងនោះ មានពីរនាក់ដែលបានសម្រេចថានឹងដេញតាមគាត់ដោយប្រើកម្លាំងបាយ។ ម្នាក់មានឈ្មោះថា លោកមានៈ ហើយម្នាក់ទៀតឈ្មោះថា លោកងាយបត់បែន។ ពេលនេះ បុរសនោះបាននៅចម្ងាយឆ្ងាយគ្រាន់បើដែរពីពួកគេ តែយ៉ាងណាក៏ដោយ ពួកគេបានសម្រេចថានឹងដេញតាមគាត់ហើយ ហើយពួកគេបានដេញតាមគាត់មែន មិនយូរប៉ុន្មាននោះពួកគេក៏ទាន់គាត់។ បន្ទាប់មកបុរសនោះបាននិយាយថា "ឱអ្នកជិតខាងអើយ តើហេតុអ្វីបានជាអ្នកមកនេះ?" ពួកគេនិយាយថា "មកដើម្បីនឹងបបួលអ្នកឱ្យត្រឡប់ទៅជាមួយយើងវិញ" ប៉ុន្តែគាត់បាននិយាយថា "ការនោះមិនអាចកើតឡើងបានទេ។ អ្នករស់នៅក្នុងទីក្រុងដែលនឹងត្រូវវិនាសអន្តរាយជាទីដែលខ្ញុំបានកើតនៅទីនោះ។ ខ្ញុំឃើញថាវានឹងត្រូវវិនាសមែន ហើយនឹងត្រូវស្លាប់នៅទីនោះយូរឬឆាប់ អ្នកនឹងត្រូវ

លិចចុះទៅជ្រៅជាងផ្នូរខ្មោចទៅកាន់កន្លែងមួយដែលឆេះដោយភ្លើងនិងស្ពាន់ធ័រ។ ចូរចេះឆ្អែតចិត្តឡើងអ្នកជិតខាងអើយ ហើយមកជាមួយខ្ញុំមក។"

លោកមាន:៖ "យ៉ាងម៉េច?" ហើយគាត់និយាយថា "ហើយចាកចេញពីមិត្តភក្តិនិងទីដែលស្រុកស្រួលរបស់យើងផង"

គ្រីស្ទានះគ្រីស្ទានបាននិយាយថា "មែនហើយ" ដោយសារវាជាឈ្មោះរបស់គាត់ "ដោយការនោះជាអ្វីដែលអ្នកត្រូវតែបោះបង់ចោល ហើយវាមិនមានតម្លៃស្មើនឹងរបស់បន្តិចបន្តួចដែលកំពុងតែស្វែងរកនោះផង។"

**"ដោយយើងខ្ញុំមិនរាប់អានរបស់ដែលមើលឃើញឡើយ គឺរាប់អានតែរបស់ដែលមើលមិនឃើញវិញ ដ្បិតរបស់ដែលមើលឃើញ នោះស្ថិតស្ថេរមិនយូរប៉ុន្មានទេ តែឯរបស់ដែលមើលមិនឃើញ នោះស្ថិតស្ថេរអស់កល្បជានិច្ចវិញ។" កូរិនថូស ទី២ 4:18**

ហើយប្រសិនបើអ្នកមកជាមួយខ្ញុំ ហើយកាន់តាមវា អ្នកនឹងត្រូវបង់ថ្លៃដូចជាខ្ញុំដែរ ដោយសារកន្លែងដែលខ្ញុំទៅគឺគ្រប់គ្រាន់និងបរិបូរ។

**"កាលវាភ្ញាក់ដឹងខ្លួន នោះក៏គិតថាឪពុកអញ មានជើងឈ្នួលប៉ុន្មានៗ សុទ្ធតែមានអាហារបរិបូរគ្រប់គ្នា តែនៅទីនេះអញជិតដាច់ពោះស្លាប់ហើយ។" លូកា 15:17**

ចូរមក ហើយបញ្ជាក់ពីពាក្យរបស់ខ្ញុំចុះ"

លោកមាន:៖ តើអ្វីទៅជាការដែលអ្នកស្វែងរក ក្នុងកាលដែលអ្នកលះចោលលោកិយនេះទៅដើម្បីស្វែងរកវា?

គ្រីស្ទាន៖ ខ្ញុំស្វែងរកមរតកដែលមិនចេះពុករលួយ មិនខូចបង់ ហើយមិនរលោយសាបសូនទៅទេ។

**"ហើយឱ្យយើងបានមរតក ដែលមិនចេះពុករលួយ ក៏ឥតសៅហ្មង ហើយមិនដែលស្រពោនឡើយ ជាមរតកដែលបម្រុងទុកឱ្យយើងរាល់គ្នានៅស្ថានសួគ៌។" ពេត្រុស ទី១ 1:4**

ហើយវាបានដាក់នៅស្ថានសួគ៌ ហើយមានសុវត្ថិភាពនៅទីនោះ ដើម្បីនឹងផ្តល់ឱ្យ នៅពេលកំណត់ទៅអ្នកដែលស្វែងរកវាដោយឧស្សាហ៍។

**"តែឥឡូវនេះ គេសង្វាតចង់បានស្រុកមួយដែលប្រសើរជាង គឺខាងស្ថានសួគ៌វិញ បានជាព្រះទ្រង់គ្មានសេចក្តីខ្មាស ដោយគេហៅទ្រង់ជាព្រះនៃគេនោះឡើយ ដ្បិតទ្រង់បានរៀបចំទីក្រុងមួយឱ្យគេហើយ។" ហេព្រើរ 11:16**

ចូរអានការនេះនៅក្នុងសៀវភៅរបស់ខ្ញុំទៅ

លោកមាន:៖ លោកមាន:បាននិយាយថា "នៅស្ងៀម" "ហើយយកសៀវភៅរបស់អ្នកចេញទៅ តើអ្នកនឹងត្រឡប់ទៅវិញជាមួយពួកយើងដែរទេ?"

គ្រីស្ទាន៖ គាត់និយាយថែមទៀតថា "ទេ ខ្ញុំមិនទៅទេ" "ពីព្រោះខ្ញុំបានដាក់ដៃរបស់ខ្ញុំកាន់នង្គ័លហើយ។"

**"ទ្រង់មានបន្ទូលទៅអ្នកនោះថា អ្នកណាដែលដាក់ដៃកាន់នង្គ័ល ហើយងាកបែរទៅមើលក្រោយ អ្នកនោះមិនគួរនឹងនគរព្រះទេ។" លូកា 9:62**

លោកមានះ៖ តោះមកអ្នកជិតខាងងាយបត់បែន ចូរយើងត្រឡប់ទៅវិញ ហើយទៅផ្ទះតែយើងបានហើយ។ មានអ្នកទៅជាមួយមនុស្សឆ្កួតឥតប្រយោជន៍ ដែលនៅពេលដែលពួកគេទទួលរបស់មានតម្លៃនៅគ្រាចុងក្រោយ នោះពួកគេឆ្លាតជាងនៅក្នុងក្រសែភ្នែករបស់ពួកគេ ជាជាងបុរសប្រាំពីរនាក់ដែលចេះផ្តល់ហេតុផលទៅទៀត។

លោកងាយនឹងបត់បែន៖ នោះលោកងាយបត់បែនបាននិយាយថា "ចូរកុំប្រមាថឡើយ ប្រសិនបើអ្វីដែលគ្រីស្ទានល្អបាននិយាយពិតមែននោះ នោះការដែលគាត់ស្វែងរកនោះពិតជាប្រសើរជាងរបស់ពួកយើងផង។ ចិត្តរបស់ខ្ញុំទោរទៅជាមួយអ្នកជិតខាងរបស់ខ្ញុំហើយ។"

លោកមានះ៖ យ៉ាងម៉េចហ្នឹង? កាន់តែល្ងង់ហើយមែនទេ? ចូរមកតាមខ្ញុំហើយត្រឡប់ទៅវិញ។ តើអ្នកណាអាចដឹងបាន ថាមនុស្សមានបញ្ហាខួរក្បាលនេះនឹងនាំអ្នកទៅណា? ចូរត្រឡប់ទៅវិញ ត្រឡប់ទៅវិញ ហើយចូរមានប្រាជ្ញាឡើង!

គ្រីស្ទាន៖ អត់ទេ។ តែអ្នកមកជាមួយអ្នកជិតខាងលោកងាយបត់បែន។ ការដែលខ្ញុំបាននិយាយពិតជាមានមែន ហើយមានទាំងសិរីល្អនៅជុំវិញផង។ ប្រសិនបើអ្នកមិនជឿខ្ញុំទេ ចូរអាននៅក្នុងសៀវភៅនេះចុះ ដើម្បីឪ្យបានដឹងពី

សេចក្តីពិតដែលចែងនៅក្នុងសៀវភៅនេះ។ មើលគ្រប់ការទាំងអស់ត្រូវបានអះអាងដោយឈាមរបស់ព្រះអង្គដែលធ្វើសម្រេចនូវការនោះផង។

“ដូច្នេះ សេចក្តីសញ្ញាចាស់ក៏មិនបានតាំងឡើង ដោយឥតឈាមដែរ ពីព្រោះកាលលោកម៉ូសេបានមានប្រសាសន៍ ប្រាប់ពីបញ្ញត្តទាំងប៉ុន្មាន តាមក្រឹត្យវិន័យ ដល់ប្រជាជនទាំងឡាយហើយ នោះលោកក៏យកឈាមកូនគោ និងឈាមពពែ ព្រមទាំងទឹក និងរោមចៀមជ្រលក់ក្រហម ហើយនិងមែកហ៊ីសុបមកប្រោះលើគម្ពីរនោះឯង ព្រមទាំងលើប្រជាជនទាំងអស់ដែរ។ ដោយមានប្រសាសន៍ថា «នេះជាឈាមនៃសញ្ញា ដែលព្រះទ្រង់បង្គាប់មកអ្នករាល់គ្នា»។ លោកក៏ប្រោះឈាមទៅលើរោងឧបោសថ និងគ្រឿងប្រដាប់ដែលសម្រាប់ការងារទាំងប៉ុន្មានបែបដូច្នោះដែរ។ ហើយតាមក្រឹត្យវិន័យ សឹងតែគ្រប់របស់ទាំងអស់បានស្អាត ដោយសារឈាម បើគ្មានខ្ចាយឈាមទេ នោះគ្មានផ្លូវណាឲ្យបានរួចពីបាបឡើយ។ ដូច្នេះ អស់ទាំងគំរូពីរបស់នៅស្ថានសួគ៌បានត្រូវសម្អាត ដោយសាររបស់ទាំងនោះ តែរបស់នៅស្ថានសួគ៌វិញ នោះត្រូវសម្អាតដោយយញ្ញបូជាប្រសើរជាងទៅទៀត។ ដ្បិតព្រះគ្រីស្ទទ្រង់មិនបានយាងចូលទៅក្នុងទីបរិសុទ្ធធ្វើដោយដៃ ដែលជាគំរូពីទីបរិសុទ្ធពិតនោះទេ គឺបានចូលទៅក្នុងស្ថានសួគ៌នោះឯង ដើម្បីនឹងលេចមកក្នុងពេលឥឡូវនេះ នៅចំពោះព្រះភ័ក្ត្រនៃព្រះ ជំណាងយើងរាល់គ្នា។ ក៏មិនមែននឹងថ្វាយព្រះអង្គទ្រង់ជាញឹកញយ ដូចជាសម្តេចសង្ឃ ដែលចូលទៅក្នុងទីបរិសុទ្ធរាល់តែឆ្នាំ ទាំងយកឈាមដទៃនោះដែរ។ ដ្បិតបើយ៉ាងដូច្នោះ នោះត្រូវឲ្យទ្រង់រងទុក្ខជាច្រើនដងតាំងពីកំណើតលោកីយ៍មក តែជាន់ឥឡូវនេះ ដែលជាចុងបំផុតអស់ទាំងកល្បនោះទ្រង់បានលេចមក១ដង ដើម្បីនឹងលើកអំពើបាបចោល ដោយថ្វាយព្រះ

**អង្គទ្រង់វិញ ទុកជាយញ្ញបូជា។ ហើយដោយព្រោះបានតម្រូវឲ្យមនុស្សទាំងអស់ស្លាប់១ដង រួចសឹមជាប់សេចក្ដីជំនុំជម្រះ។ ដូច្នេះ ព្រះគ្រីស្ទក៏បែបយ៉ាងនោះដែរ ដែលទ្រង់បានថ្វាយព្រះអង្គទ្រង់១ដងហើយ ដោយព្រោះបាបរបស់មនុស្សជាច្រើន នោះទ្រង់នឹងលេចមកម្ដងទៀត ក្រៅពីរឿងអំពើបាប គឺសម្រាប់នឹងជួយសង្គ្រោះដល់អស់អ្នកដែលរង់ចាំទ្រង់។" ហេព្រើរ 9:18-28**

លោកងាយបត់បែនបាននិយាយថា "ពិតណាស់ អ្នកជិតខាងមានៈអើយ ខ្ញុំបានមកដល់ចំណុចមួយ ដែលខ្ញុំមានបំណងទៅជាមួយនឹងបុរសល្អនេះ ហើយដើម្បីនឹងបានរង្វាន់ជាមួយនឹងគាត់ តែសំឡាញដ៏ល្អរបស់ខ្ញុំអើយ តើអ្នកស្គាល់ផ្លូវទៅកាន់កន្លែងដែលអ្នកប្រាថ្នាចង់ទៅដែរទេ?"

គ្រីស្ទាន៖ ខ្ញុំមានម្នាក់ដែលចង្អុលបង្ហាញផ្លូវដល់ខ្ញុំ ដែលមានឈ្មោះថា អ្នកផ្សាយដំណឹងល្អ ដើម្បីនឹងជម្រុញខ្ញុំឱ្យទៅដល់ឃ្លោងទ្វារតូចមួយដែលនៅខាងមុខយើងនេះ ជាកន្លែងដែលយើងនឹងទទួលបានការណែនាំអំពីផ្លូវទៅ។

លោកងាយបត់បែន៖ អីចឹងអ្នកជិតខាងល្អអើយ ចូរយើងចេញទៅ។

បន្ទាប់មកពួកគេទាំងពីរបានចេញទៅជាមួយគ្នា

លោកមានៈ៖ លោកមានៈបាននិយាយថា "ហើយខ្ញុំនឹងត្រឡប់ទៅកន្លែងរបស់ខ្ញុំវិញ ខ្ញុំនឹងមិនមានអ្នកមកជាមួយដែលនាំទៅផ្លូវខុស ជាសំឡាញ់ដ៏អស្ចារ្យអីនោះទេ។"

## អ្វីដែលត្រូវសម្លឹងមើល

ឥលូវខ្ញុំបានឃើញនៅក្នុងសុបិន្តរបស់ខ្ញុំ ថានៅពេលដែលលោកមានៈបានត្រឡប់ទៅវិញ គ្រីស្ទាននិងលោកងាយនឹងបត់បែនបានធ្វើដំណើរទៅដោយជជែកគ្នានៅតាមវាលផង។ ហើយពួកគេក៏បានចាប់ផ្តើមការជជែកវែកញែកគ្នា។

គ្រីស្ទានៈ ចូរមកអ្នកជិតខាងងាយនឹងបត់បែនអើយ តើអ្នកយ៉ាងម៉េចហើយ? ខ្ញុំអរណាស់ដែលអ្នកចាប់អារម្មណ៍នឹងមកជាមួយខ្ញុំ។ ប្រសិនបើលោកមានៈអាចដឹងនូវអារម្មណ៍ដែលខ្ញុំទទួលបាននូវអំណាចនិងការភ័យខ្លាចនៅអ្វីដែលមើលមិនឃើញនោះ នោះគាត់នឹងមិនបានបែរខ្នងដាក់យើងដូច្នេះទេ។

លោកងាយនឹងអូសទាញៈ ចូរមកអ្នកជិតខាងគ្រីស្ទានអើយ ក្នុងកាលដែលមានតែយើងពីនាក់នៅទីនេះ សូមអ្នកប្រាប់ខ្ញុំពីរឿងនោះថែមទៀត ហើយពីវិធីដែលអាចនឹងធ្វើឱ្យយើងមានអំណរចំពោះការនោះ គឺពីកន្លែងដែលយើងកំពុងទៅនេះផង។

គ្រីស្ទានៈ ខ្ញុំអាចយល់ឃើញពីការទាំងនោះជាមួយនឹងគំនិតរបស់ខ្ញុំ ជាងការដែលនិយាយដោយអណ្តាតរបស់ខ្ញុំ តែបើអ្នកចង់ដឹងទៅហើយនោះ ខ្ញុំនឹងអានពីការទាំងនោះនៅក្នុងសៀវភៅរបស់ខ្ញុំ។

អ្នកងាយអូសទាញៈ តើអ្នកគិតថាពាក្យនៅក្នុងសៀវភៅរបស់អ្នកប្រាកដជាពិតដែរទេ?

គ្រីស្ទាន៖ បាទពិតណាស់។ ដោយសារសៀវភៅនេះបានបង្កើតឡើងមក ដោយទ្រង់ដែលមិនចេះកុហកសោះ។

**"ដោយសេចក្ដីសង្ឃឹមដល់ជីវិតដ៏នៅអស់កល្បជានិច្ច ដែលព្រះដ៏មិនចេះភូត ទ្រង់បានសន្យាមុនអស់ទាំងកល្ប។" ទីតុស 1:2**

លោកងាយអូសទាញ៖ និយាយបានល្អណាស់។ តើការទាំងនោះជាអ្វីខ្លះទៅ?

គ្រីស្ទាន៖ មាននគរដែលមិនចេះចប់មួយ ដែលនឹងត្រូវក្លាយទៅជាមរតក។ ហើយជីវិតអស់កល្បជានិច្ចនឹងត្រូវផ្ដល់មកយើង ដែលយើងនឹងគ្រងមរតកនៅនគរនោះអស់កល្បជានិច្ច។

**"ដ្បិតមើលអញនឹងបង្កើតផ្ទៃមេឃថ្មី ហើយនឹងផែនដីថ្មី ឯរបស់ពីមុនៗ នោះនឹងគ្មានអ្នកណានឹកចាំទៀត ក៏មិនដែលចូលក្នុងគំនិតឡើយ។" អេសាយ 65:17**

**"ចៀមខ្ញុំទាំងប៉ុន្មានវាស្ដាប់ខ្ញុំ ហើយមកតាមខ្ញុំ ខ្ញុំក៏ស្គាល់វាដែរ ខ្ញុំឱ្យជីវិតអស់កល្បជានិច្ចដល់វា វាមិនត្រូវវិនាសនៅអស់កល្បរៀងទៅ ក៏គ្មានអ្នកណាឆក់យកវាពីដៃខ្ញុំបានទេ។ ព្រះវរបិតានៃខ្ញុំ ដែលប្រទានវាមកខ្ញុំ ទ្រង់ធំលើសជាងទាំងអស់ គ្មានអ្នកណាអាចនឹងឆក់យកវាចេញពីព្រះហស្តរបស់ព្រះវរបិតាខ្ញុំបានឡើយ។" យ៉ូហាន 10:27, 29**

លោកងាយអូសទាញ៖ និយាយបានល្អ។ ហើយមានអ្វីទៀតដែរទេ?

គ្រីស្ទាន៖ មានមកុដនៃសិរីល្អដែលនឹងត្រូវផ្ដល់ដល់យើង។ ហើយនឹងសំលៀកបំពាក់ដែលធ្វើឲ្យយើងចែងចាំងដូចព្រះអាទិត្យនៅលើគ្រឹះនៃស្ថានសួគ៌។

**"គ្រានោះ ពួកសុចរិតនឹងភ្លឺដូចជាថ្ងៃនៅក្នុងនគររបស់ព្រះវរបិតានៃគេ អ្នកណាមានត្រចៀកសំរាប់ស្តាប់ ឪ្យស្តាប់ចុះ។" ម៉ាថាយ 13:43**

**"ពីនេះទៅមុននឹងមានមកុដនៃសេចក្ដីសុចរិត បម្រុងទុកឱ្យខ្ញុំ ដែលព្រះអម្ចាស់ដ៏ជាចៅក្រមសុចរិត ទ្រង់នឹងប្រទានមកខ្ញុំនៅថ្ងៃនោះ មិនមែនដល់តែខ្ញុំម្នាក់ប៉ុណ្ណោះ គឺដល់អស់អ្នកណា ដែលចូលចិត្តនឹងដំណើរទ្រង់យាងមកវិញនោះដែរ។" ធីម៉ូថេ ទី២ 4:8**

**"ប៉ុន្តែនៅក្រុងសើដេស ឯងក៏មានអ្នកខ្លះដែលមិនបានធ្វើឲ្យសំលៀកបំពាក់ខ្លួនស្មោកគ្រោកដែរ អ្នកទាំងនោះនឹងស្លៀកពាក់ស ដើរជាមួយនឹងអញ ដ្បិតគេបានគួរហើយ។" វិវរណៈ 3:4**

លោកងាយនឹងទាក់ទាញ៖ នេះគួរឱ្យពេញចិត្តណាស់។ មានអ្វីទៀតទេ?

គ្រីស្ទាន៖ នឹងមិនមានការទួញសោកសង្រេងទៀតឡើយ ដោយសារទ្រង់ជាម្ចាស់នៅទីនោះនឹងជូតទឹកភ្នែកទាំងអស់ចេញពីភ្នែករបស់យើង។

**"ទ្រង់នឹងបំផ្លាញសេចក្ដីស្លាប់ឱ្យសូន្យបាត់បង់ទៅជាដរាប នោះព្រះអម្ចាស់យេហូវ៉ា ទ្រង់នឹងជូតទាំងទឹកភ្នែកពីមុខមនុស្សទាំងអស់ ហើយទ្រង់នឹងសេច**

**ក្តីត្មះតិះដៀលចំពោះរាស្ត្រទ្រង់ ពីផែនដីទាំងមូលចេញ ដ្បិតព្រះយេហូវ៉ាទ្រង់បានមានបន្ទូលដូច្នេះហើយ។" អេសាយ 25:8**

"គេនឹងមិនឃ្លាន ឬស្រេកទៀត ក៏មិនត្រូវថ្ងៃថាំងមកលើគេ ឬចំហាយណាទៀតឡើយ។ ពីព្រោះកូនចៀមដែលនៅកណ្តាលបល្ល័ង្ក ទ្រង់នឹងឃ្វាល ហើយនាំគេ ទោដល់រន្ធទឹកនៃជីវិត ហើយព្រះទ្រង់នឹងជូតអស់ទាំងភ្នែកពីភ្នែកគេចេញ។"

**"ព្រះទ្រង់នឹងជូតអស់ទាំងទឹកភ្នែក ពីភ្នែកគេចេញ និងគ្មានសេចក្តីស្លាប់ ឬសេចក្តីសោកសង្រេង ឬសេចក្តីយំទូញ ឬទុក្ខលំបាកណាទៀតឡើយ ដ្បិតសេចក្តីមុនទាំងប៉ុន្មាន បានកន្លងបាត់ទៅហើយ។" វិវរណៈ 21:4**

លោកងាយអូសទាញ៖ តើយើងនឹងមានសំឡាញ់អ្វីនៅទីនោះ?

គ្រីស្ទាន៖ នៅទីនោះយើងនឹងទៅជាមួយនឹង សេរ៉ាផឹម និងចេរ៉ូបឹម ជាសត្វដែលនឹងធ្វើឲ្យភ្នែករបស់អ្នកសម្លឹងទៅមើលពួកគេ។

**"នៅឆ្នាំដែលស្តេចអ៊ូសៀសទ្រង់បានសុគត នោះខ្ញុំឃើញព្រះអម្ចាស់ទ្រង់គង់លើបល្ល័ង្កនៅទីខ្ពស់ ហើយបានដំកើងឡើង ឯរំភាយព្រះពស្ត្រទ្រង់សាយមកពេញក្នុងព្រះវិហារ។" អេសាយ 6:1**

**"ព្រះអម្ចាស់ទ្រង់នឹងយាងចុះពីស្ថានសួគ៌មក ដោយស្រែកបង្គាប់មួយព្រះឱស្ឋទាំងមានឮសម្លេងមហាទេវតា និងត្រែរបស់ព្រះផង នោះពួកស្លាប់ក្នុងព្រះគ្រីស្ទនឹងរស់ឡើងវិញជាមុនបង្អស់។ រួចយើងរាល់គ្នាដែល កំពុងតែរស់នៅ ក៏**

**នឹងបានលើកឡើងទៅក្នុងពពកជាមួយគ្នាទាំងអស់ ដើម្បីឱ្យបានជួបជុំនឹងព្រះអម្ចាស់នៅនាអាកាស យ៉ាងនោះ យើងនឹងនៅជាមួយនឹងព្រះអម្ចាស់ជាដរាបទៅ។" ថែស្សាឡូនិច ទី១ 4:16-17**

**"នោះខ្ញុំឃើញ ហើយក៏ឮសម្លេងទេវតាជាច្រើននៅជុំវិញបល្ល័ង្ក ព្រមទាំងតួមានជីវិត និងពួកចាស់ទុំផង ឯចំនួននៃទេវតានោះ មានទាំងម៉ឺនទាំងសែន ហើយទាំងពាន់រាប់ជាពាន់។" វិវរណៈ 5:11**

នៅទីនោះអ្នកនឹងជួបមនុស្សរាប់ពាន់ រាប់ម៉ឺនដែលបានទៅដល់មុនយើងនៅទីនោះ។ ហើយមិនមាននរណាម្នាក់នឹងត្រូវរងគ្រោះ តែពេញដោយការស្រឡាញ់និងបរិសុទ្ធ។ គ្រប់គ្នានឹងដើរនៅមុខព្រះអម្ចាស់ ហើយឈរនៅក្នុងព្រះវត្តមានទ្រង់ដោយមានការទទួលជានិច្ច។ និយាយទៅ យើងនឹងមើលឃើញពួកចាស់ទុំដែលមានមកុដមាស។

**"នៅព័ទ្ធជុំវិញបល្ល័ង្កនោះ ក៏មានបល្ល័ង្ក២៤ទៀត ហើយខ្ញុំឃើញអ្នកចាស់ទុំ២៤នាក់ អង្គុយលើបល្ល័ង្កទាំងនោះ ទាំងស្លៀកពាក់ស ហើយមានមកុដមាសនៅលើក្បាល។" វិវរណៈ 4:4**

នៅទីនោះយើងនឹងឃើញក្រមុំបរិសុទ្ធដែលមានកាន់ចាប់ស៊ុង

"ខ្ញុំក្រឡេកទៅឃើញកូនចៀម ឈរនៅលើភ្នំស៊ីយ៉ូន ហើយមានមនុស្ស១សែន៤ម៉ឺន៤ពាន់នាក់ ដែលមានព្រះនាមទ្រង់ និងព្រះនាមព្រះវរបិតាទ្រង់កត់លើថ្ងាស គេបានឈរជាមួយដែរ។ រួចខ្ញុំឮសំឡេងមកពីលើមេឃ ដូចជាសូរទឹកច្រើន ហើយដូចផ្គរលាន់យ៉ាងខ្លាំង រីឯសំឡេងដែលខ្ញុំឮនោះ ក៏ដូចជាសូរ

សព្វរបស់ពួកតន្ត្រីដែលកំពុងតែចាប់ស៊ុង។គេច្រៀងបទ១ថ្មី នៅមុខបល្ល័ង្ក ហើយមុខតួមានជីវិតទាំង៤ និងពួកចាស់ទុំដែរ គ្មានអ្នកណាអាចនឹងរៀនបទនោះបានទេ មានតែមនុស្ស១សែន៤ម៉ឺន៤ពាន់នាក់ ដែលទ្រង់លោះពីផែនដីចេញប៉ុណ្ណោះ។នោះជាពួកព្រហ្មចារី ដែលមិនបានបង្ខូចខ្លួននឹងស្រី ឡើយ គេតាមកូនចៀមទៅគ្រប់កន្លែងដែលទ្រង់យាងទៅ ទ្រង់បានលោះគេចេញពីពួកមនុស្សលោក ទុកជាផ្លែដំបូងថ្វាយដល់ព្រះ ហើយនិងកូនចៀម។មិនឃើញមានសេចក្ដីភូតភរ នៅក្នុងមាត់គេឡើយ ដ្បិតគេឥតសៅហ្មង។” **វិវរណៈ 14:1-5**

នៅទីនោះយើងនឹងឃើញមនុស្សដែលត្រូវគេកាត់ជាចំណែកៗដោយសារព្រះបន្ទូល ត្រូវដុតនៅក្នុងអណ្ដាតភ្លើង ត្រូវសត្វសាហាវស៊ី ត្រូវលង់នៅក្នុងសមុទ្រ ដោយសារសេចក្ដីស្រឡាញ់របស់គេមានចំពោះព្រះអម្ចាស់ដែលនៅទីនោះ ជាកន្លែងដែលល្អហើយមានគ្រងដោយភាពមិនចេះសាបសូន្យប្រៀបដូចជាសំលៀកបំពាក់។

“អ្នកណាដែលស្រឡាញ់ជីវិតខ្លួន នោះនឹងបាត់ជីវិតទៅ តែអ្នកណាដែលស្អប់ជីវិតខ្លួន នៅលោកីយ៍នេះវិញ នោះនឹងរក្សាជីវិតទុក ដរាបដល់អស់កល្បរៀងទៅ” **យ៉ូហាន 12:25**

“ដ្បិតនៅក្នុងត្រសាលនេះ យើងខ្ញុំតែងតែថ្ងូរ ដោយសង្វាតនឹងចង់ប្រដាប់ខ្លួនដោយទីលំនៅរបស់យើងខ្ញុំ ជាទីលំនៅដែលមកពីស្ថានសួគ៌ណាស់។ ឲ្យតែយើងខ្ញុំបានប្រដាប់ខ្លួនចុះ ដើម្បីកុំឲ្យមានឃើញយើងខ្ញុំនៅអាក្រាតឡើយ។ ដ្បិតយើងខ្ញុំដែលនៅក្នុងត្រសាលនេះ យើងថ្ងូរមែន ដោយមានបន្ទុក

យ៉ាងធ្ងន់ ពីព្រោះយើងមិនចង់ដោះសម្លៀកបំពាក់នេះចេញទេ គឺចង់តែស្លៀកពាក់វិញ ដើម្បីឲ្យជីវិតបានលេបរបស់ ដែលតែងតែស្លាប់ ឲ្យបាត់ទៅនោះ” កូរិនថូស ទី២ 5:2-4

លោកងាយអូសទាញ៖ គ្រាន់តែស្តាប់ពីការនេះ គ្រប់គ្រាន់នឹងចាប់យកចិត្តរបស់មនុស្សទៅហើយ។ តែតើការទាំងនោះសុទ្ធតែអាចឲ្យមនុស្សរីករាយទេ? តើយើងអាចមានចំណែកនោះបានដោយរបៀបណា?

គ្រីស្ទាន៖ ព្រះអម្ចាស់ ដែលជាអ្នកគ្រប់គ្រងលើប្រទេសបានកត់ត្រានៅក្នុងសៀវភៅនេះ។ ជាធាតុដែលយើងនឹងចង់មានចង់បាន ដែលទ្រង់នឹងផ្តល់មកកាន់យើងដោយឥតបង់ថ្លៃ។

**“ហឺស អស់អ្នកដែលស្រេកអើយ ចូរមកឯទីទឹកចុះ ឯអ្នកដែលគ្មានប្រាក់អើយ ចូរមកទិញ ហើយបរិភោគទៅ អើ ចូរមកទិញស្រាទំពាំងបាយជូរ និងទឹកដោះគោឥតបង់លុយ ឥតថ្លៃទេ។ហេតុអ្វីបានជាចាយប្រាក់ឲ្យបានតែរបស់ដែលមិនមែនជាអាហារ ហើយបង់កម្លាំងឲ្យបានតែរបស់ដែលមិនស្កប់ចិត្តដូច្នេះ ចូរស្តាប់តាមអញឲ្យអស់ពីចិត្តចុះ នោះឯងនឹងបានបរិភោគយ៉ាងឆ្ងាញ់ ដើម្បីឲ្យព្រលឹងឯងបានស្កប់ស្កល់ ដោយម្ហូបយ៉ាងថ្លៃវិសេស” អេសាយ 55:1-2**

**“អស់អ្នកណាដែលព្រះវរបិតាប្រទានមកខ្ញុំ នោះនឹងមកឯខ្ញុំ ហើយអ្នកណាដែលមកឯខ្ញុំ ខ្ញុំក៏មិនដែលចោលទៅក្រៅឡើយ។” យ៉ូហាន 6:37**

“ទ្រង់ក៏មានព្រះបន្ទូលមកខ្ញុំថា ស្រេចហើយ អញជាអាលផា និងអូមេកា គឺជាដើម ហើយជាចុង បើអ្នកណាស្រេក អញនឹងឲ្យអ្នកនោះផឹកពីរន្ធទឹកនៃជីវិតឥតយកថ្លៃ” **វិវរណៈ 21:6**

“ព្រះវិញ្ញាណ និងប្រពន្ធថ្មោងថ្មីពោលថា អញ្ជើញមក ហើយអ្នកណាដែលឮក៏ថា អញ្ជើញមកដែរ អ្នកណាដែលស្រេក នោះមានតែមក ហើយអ្នកណាដែលចង់បាន មានតែយកទឹកជីវិតនោះចុះ ឥតចេញថ្លៃទេ។” **វិវរណៈ 22:17**

លោកងាយអូសទាញ៖ ពិតជាល្អណាស់ សំលាញ់ល្អរបស់ខ្ញុំ ខ្ញុំរីករាយណាស់ដែលបានស្តាប់ការទាំងអស់នេះ។ មកយើងប្រញាប់ដើរលឿនឡើង។

គ្រីស្ទាន៖ ខ្ញុំមិនអានទៅឆ្ងាយបានតាមដែលខ្ញុំចង់នោះទេ ដោយហេតុថាខ្ញុំមិនបន្ទុកនៅលើខ្នងរបស់ខ្ញុំ។

## លោកអ្នកប្រាជ្ញខាងលោកិយ

នៅពេលនេះ កាលដែលគ្រីស្ទានកំពុងតែដើរតែម្នាក់ឯង គាត់បានសម្លឹងឃើញមានម្នាក់កំពុងតែឆ្លងកាត់ផ្លូវវាលនោះមកជួបគាត់ ហើយពួកគេបានប្រទះឃើញគ្នានៅពេលដែលកំពុងឆ្លងកាត់ផ្លូវ។ ឈ្មោះរបស់សុភាពបុរសដែលបានជួបគាត់នោះគឺ អ្នកប្រាជ្ញខាងលោកិយ។ គាត់រស់នៅក្នុងទីក្រុងគោលការណ៍ខាងសាច់ឈាម ជាទីក្រុងមួយយ៉ាងធំអស្ចារ្យ ហើយវាក៏ពិបាកដែរនៅពេលដែលគ្រីស្ទានចេញមក។ បុរសម្នាក់នេះបានជួបជាមួយគ្រីស្ទាន ហើយមានការសង្ស័យទៅលើគាត់ ដោយសារគ្រីស្ទានបានចាកចេញពីទីក្រុងនៃសេចក្តីវិនាសអន្តរាយដែលបង្ករឱ្យមានសម្លេងលេចឮទៅខាងក្រៅយ៉ាងខ្លាំង មិនមែនតែនៅក្នុងក្រុងដែលគាត់នៅប៉ុណ្ណោះ តែគេចាប់ផ្តើមនិយាយប្រាប់ទៅកាន់តំបន់ផ្សេងៗទៀត។ ហេតុនេះហើយបានជាលោកម្ចាស់អ្នកប្រាជ្ញនៃលោកិយបានប៉ាន់ស្មានពីគាត់ ដោយក្រលេកទៅមើលការខិតខំធ្វើដំណើររបស់គាត់ ដោយពិនិត្យមើលការដកដង្ហើមធំនិងការត្អូញត្អែររបស់គាត់ និងការស្រដៀងនោះ គាត់ក៏ចាប់ផ្តើមជជែកគ្នាជាមួយគ្រីស្ទាន។

អ្នកប្រាជ្ញនៃលោកិយ៖ យ៉ាងម៉េចហើយពេលនេះសំឡាញ់អើយ? ហេតុអ្វីបានជាទៅដោយមានបន្ទុកបែបនេះ?

គ្រីស្ទាន៖ គឺជាផ្លូវដែលមានបន្ទុកពិតមែន ដែលខ្ញុំតែងតែគិតថាគ្រប់ទាំងភារៈទាំងអស់ត្រូវតែមាន។ ហើយហេតុអ្វីបានជាអ្នកសួរមកខ្ញុំបែបនៀក? ខ្ញុំប្រាប់អ្នកទៅចុះ ខ្ញុំកំពុងតែសំដៅទៅកាន់ឃ្លោងទ្វារទុច្ចរិតដែលនៅខាងមុខខ្ញុំនោះ ដោយនៅទីនោះដូចដែលគេបានប្រាប់ខ្ញុំមក ថាខ្ញុំនឹងត្រូវទៅកាន់ផ្លូវមួយដែលនឹងដកបន្ទុកដ៏ធ្ងន់ចេញពីខ្នងរបស់ខ្ញុំបាន។

អ្នកប្រាជ្ញខាងលោកិយ៖ តើអ្នកមានប្រពន្ធកូនទេ?

គ្រីស្ទាន៖ បាទមាន។ តែដោយសារខ្ញុំមានបន្ទុកនេះ នោះខ្ញុំមិនអាចនឹងមានការអរសប្បាយដោយប្រពន្ធនិងកូនដូចពីមុនទៀតឡើយ។ ខ្ញុំគិតមកខ្លួនថាដូចជាខ្ញុំមិនមានប្រពន្ធកូនសោះ។

**“បងប្អូនអើយ ខ្ញុំប្រាប់សេចក្តីនេះថា ពេលវេលាចង្អៀតណាស់ហើយ ពីនេះទៅមុខ គួរតែឱ្យពួកអ្នកដែលមានប្រពន្ធ បាននៅដូចជាគ្មានវិញ។” កូរិនថូសទី១ 7:29**

អ្នកប្រាជ្ញខាងលោកិយ៖ តើអ្នកនឹងស្តាប់តាមខ្ញុំទេ ប្រសិនបើខ្ញុំផ្តល់ការព្រឹក្សាដល់អ្នក?

គ្រីស្ទាន៖ បើវាល្អ នោះខ្ញុំនឹងស្តាប់ ដោយសារខ្ញុំត្រូវការយោបល់ល្អៗ។

អ្នកប្រាជ្ញាខាងលោកិយ៖ អីចឹងខ្ញុំនឹងផ្តល់យោបល់ដល់អ្នក នោះអ្នកនឹងឆាប់បានយកបន្ទុករបស់អ្នកចេញ ដ្បិតអ្នកនឹងមិនបានសម្រាកនៅក្នុងគំនិតរបស់អ្នកទាល់តែអ្នកបានយកវាចេញ ហើយអ្នកក៏មិនអាចនឹងរីករាយនឹង

ផលប្រយោជន៍ចេញពីព្រះពរដែលព្រះបានប្រទានមកអ្នកទាល់តែអ្នកយកវាចេញផងដែរ។

គ្រីស្ទាន៖ នោះជាអ្វីដែលខ្ញុំស្វែងរក គឺដើម្បីយកបន្ទុកធ្ងន់នេះចេញពីខ្ញុំ តែខ្ញុំមិនអាចយកវាចេញដោយខ្លួនខ្ញុំឡើយ។ ហើយក៏មិនមានមនុស្សណាម្នាក់នៅក្នុងប្រទេសរបស់យើងអាចយកវាចេញពីស្មារបស់ខ្ញុំបានឡើយ។ ដូច្នេះខ្ញុំកំពុងទៅតាមផ្លូវនេះដូចដែលខ្ញុំបានប្រាប់ហើយ ថាខ្ញុំអាចនឹងយកបន្ទុករបស់ខ្ញុំចេញ។

អ្នកប្រាជ្ញខាងលោកិយ៖ តើអ្នកណាប្រាប់អ្នកឲ្យទៅផ្លូវនេះដើម្បីយកបន្ទុករបស់អ្នកចេញនោះ?

គ្រីស្ទាន៖ បុរសម្នាក់ដែលមកកាន់ខ្ញុំដែលមើលទៅហាក់បីដូចជាបុគ្គលម្នាក់ដែលអស្ចារ្យនិងមានកិត្តិយសណាស់ បើតាមដែលខ្ញុំចាំគាត់មានឈ្មោះថាអ្នកផ្សាយដំណឹងល្អ។

អ្នកប្រាជ្ញខាងលោកិយ៖ ចូរគេចចេញពីយោបល់របស់គាត់ទៅ! គ្មានផ្លូវណាដែលគ្រោះថ្នាក់និងពេញដោយបញ្ហានៅលើលោកនេះជាជាងផ្លូវដែលគាត់ណែនាំដល់អ្នកនោះទេ ប្រសិនបើអ្នកស្តាប់តាមយោបល់របស់គាត់ នោះអ្នកនឹងឃើញហើយ។ អ្នកបានជួយនឹងអ្វីមួយដូចដែលខ្ញុំបានដឹងរួចទៅហើយដោយសារខ្ញុំបានឃើញភក់ល្បមកពីរណ្តៅនៃការធ្លាក់ចុះនៅលើខ្លួនរបស់អ្នកនោះ។ តែរណ្តៅនោះគ្រាន់តែជាការចាប់ផ្តើមនៃសេចក្តីទុក្ខលំបាក ដែលកើតមានដល់អស់អ្នកដែលដើរតាមផ្លូវនោះ។ ចូរស្តាប់ខ្ញុំវិញ ដោយសារខ្ញុំ

ចាស់ជាងអ្នក។ អ្នកនឹងត្រូវជួបភាពនឿយណាយ ការឈឺចាប់ សេចក្តីស្រេកឃ្លាន គ្រោះថ្នាក់ សេចក្តីអាក្រាត ដាវ សត្វតោ សត្វនាគ សេចក្តីងងឹត ហើយនិយាយឱ្យខ្លីទៅ ជាសេចក្តីស្លាប់។ ការទាំងនេះសុទ្ធតែជាការពិត ដោយសារត្រូវបានបញ្ជាក់អះអាងដោយទីបន្ទាល់ជាច្រើន។ ហេតុដូចម្តេចបានជាគេត្រូវបោះបង់ខ្លួនរបស់គេទៅស្តាប់មនុស្សចម្លែកបែបហ្នឹងនោះ?

គ្រីស្ទាន៖ ឱលោក ហេតុអ្វីបានជាបន្ទុកនៅខ្នងរបស់ខ្ញុំវាពិបាកជាងការទាំងប៉ុន្មានដែលលោកបានរៀបរាប់នេះម្ល៉េះ? ខ្ញុំមិនខ្វល់ពីអ្វីដែលខ្ញុំនឹងជួបនៅតាមផ្លូវនោះទេ បើមានក៏មានចុះ នោះខ្ញុំនឹងបានជួបនឹងការរំដោះឱ្យរួចពីបន្ទុករបស់ខ្ញុំនេះ។

អ្នកប្រាជ្ញខាងលោកិយ៖ អ្នកមកជាមួយបន្ទុកនេះទាំងពីដំបូងមកបានយ៉ាងដូចម្តេច?

គ្រីស្ទាន៖ ដោយបានអានសៀវភៅដែលនៅក្នុងដៃរបស់ខ្ញុំនេះ។

អ្នកប្រាជ្ញខាងលោកិយ៖ ខ្ញុំក៏គិតអីចឹងដែរ។ វាបានកើតឡើងទៅកាន់អ្នកដូចដែលបានកើតឡើងទៅកាន់អ្នកខ្សោយៗផ្សេងទៀតផងដែរ សុទ្ធតែជាអ្នកដែលយករឿងដែលខ្ពស់ហួសកម្លាំងមកដាក់ខ្លួន ហើយពួកគេនឹងធ្លាក់ចូលសេចក្តីអន្តរាយមួយរំពេច ជាសេចក្តីរំខានដល់មនុស្ស (ដូចជារូបអ្នកដែលខ្ញុំបានដឹង) តែពួកគេបានធ្លាក់ចូលទៅក្នុងការបោកបញ្ឆោត ដើម្បីទទួលបានអ្វីដែលគេមិនដែលស្គាល់សោះ។

គ្រីស្ទាន៖ ខ្ញុំស្គាល់ពីអ្វីដែលខ្ញុំនឹងទទួលបាន ហើយវាជួយសម្រាលដល់បន្ទុកដ៏ធ្ងន់របស់ខ្ញុំនេះ។

អ្នកប្រាជ្ញខាងលោកិយ៖ តែហេតុអ្វីបានជាអ្នកស្វែងរកដើម្បីសម្រាលដល់បន្ទុកតាមរបៀបនេះ ទាំងជួបជាមួយគ្រោះថ្នាក់ជាច្រើនដូចនេះ? ជាពិសេសពេលដែលអ្នកអត់ធ្មត់នឹងស្តាប់មកខ្ញុំ ខ្ញុំអាចនាំអ្នកទៅកាន់អ្វីដែលអ្នកប្រាថ្នាចង់បាន ដោយមិនមានគ្រោះថ្នាក់ដូចដែលអ្នកនឹងជួបនៅតាមផ្លូវនេះនោះឡើយ។ ហើយវិធីសាស្រ្តនោះក៏នៅមិនឆ្ងាយ។ លើសពីនោះទៀត ខ្ញុំនឹងបន្ថែមទៀតថា ជំនួសឱ្យសេចក្តីគ្រោះថ្នាក់ទាំងនោះ នោះអ្នកនឹងជួបនឹងសុវត្ថិភាព មិត្តភាព និងភាពស្កប់ស្កល់វិញ។

គ្រីស្ទាន៖ ឱលោក! សូមលោកបើកបង្ហាញការសំងាត់នេះដល់ខ្ញុំផង!

អ្នកប្រាជ្ញខាងលោកិយ៖ ហេតុអ្វី នៅភូមិខាងមុខ (ភូមិដែលហៅថាសីលធម៌) មានបុរសម្នាក់រស់នៅទីនោះឈ្មោះលោក ស្របច្បាប់ ជាមនុស្សធ្វើដោយស្របច្បាប់ម្នាក់ ហើយជាមនុស្សដែលមានឈ្មោះល្អ ដែលមានជំនាញជួយដល់មនុស្សដែលមានបន្ទុកដូចដែលនៅលើស្មារបស់អ្នកនេះឯង។ ចំពោះខ្ញុំ គាត់បានធ្វើការល្អយ៉ាងខ្លាំង ក្រៅពីនោះគាត់មានជំនាញក្នុងការព្យាបាលអ្នកដែលឆ្កួតនៅក្នុងគំនិតរបស់គេដោយសារបន្ទុករបស់ពួកគេ។ សម្រាប់គាត់ដូចដែលខ្ញុំបាននិយាយហើយ អ្នកអាចទៅកាន់គាត់បានហើយទទួលជំនួយក្នុងពេលនេះ។ ផ្ទះរបស់គាត់នៅមិនដល់មួយយោជពីនេះផង។ ហើយប្រសិនបើគាត់ផ្ទាល់មិនបាននៅផ្ទះទេ នោះគាត់មានបុរសក្មេងម្នាក់ជាកូនរបស់គាត់ឈ្មោះថា ថ្លៃថ្នូរ ដែលគាត់ក៏អាចធ្វើបានដូចគ្នាទៅ

នឹងបុរសចាស់ផងដែរ។ នៅទីនោះដូចដែលខ្ញុំនិយាយហើយថា អ្នកនឹងបាន សម្រាលពីបន្ទុករបស់អ្នក ហើយប្រសិនបើអ្នកមិនមានគំនិតនឹងត្រឡប់ទៅ រកមុខរបស់ពីមុនរបស់អ្នកទេនោះ ហើយខ្ញុំក៏មិនប្រាថ្នាដូចនោះដែរ។ អ្នក អាចផ្តាំប្រាប់ប្រពន្ធកូនរបស់អ្នកឲ្យមកកាន់អ្នកនៅភូមិនេះ ជាទីដែលមានផ្ទះ ដែលមិនទំនេរច្រើន ដែលអ្នកអាចនឹងមានផ្ទះមួយនៅក្នុងតម្លៃសមរម្យ ការ ផ្គត់ផ្គង់នៅទីនោះក៏ថោកហើយល្អដែរ ហើយវានឹងធ្វើឲ្យជីវិតអ្នកសប្បាយ ជាងមុនជាប្រាកដ ដោយសារអ្នកនឹងរស់នៅក្បែរអ្នកជិតខាងដែលស្មោះ ត្រង់ មានមុខមាត់ និងឥរិយាបថល្អ។

គ្រីស្ទាន៖ ឱលោក! តើផ្លូវមួយណាដែលទៅកាន់ផ្ទះរបស់មនុស្សស្មោះត្រង់ នោះ?

អ្នកប្រាជ្ញខាងលោកិយ៖ តើអ្នកឃើញភ្នំដែលនៅពីចម្ងាយនោះទេ? (ភ្នំស៊ីយ៉ូ ន)

គ្រីស្ទាន៖ បាទ មើលឃើញច្បាស់ណាស់។

អ្នកប្រាជ្ញាខាងលោកិយ៖ អ្នកត្រូវតែទៅក្បែរភ្នំនោះ ហើយផ្ទះទីមួយដែល អ្នកទៅដល់នោះជាផ្ទះរបស់គាត់ហើយ។

ដូច្នេះគ្រីស្ទានបានបែរចេញពីផ្លូវរបស់គាត់ដើរទៅកាន់ផ្ទះរបស់លោកស្រប ច្បាប់ដើម្បីសុំជំនួយ។ តែមើល នៅពេលដែលគាត់មានការលំបាក់នៅក្បែរ ភ្នំនោះ ដោយវាហាក់បីដូចជាខ្ពស់ខ្លាំង ហើយចំហៀងរបស់វាដែលនៅក្បែរ ផ្លូវនោះឡើងទៅកាន់តែខ្ពស់ វាបានធ្វើឲ្យគ្រីស្ទានភិតភ័យនៅក្នុងការបន្ត

ដំណើរទៅមុខ មិនដូច្នោះកំពូលភ្នំអាចនឹងធ្លាក់កិនក្បាលរបស់គាត់។ ដូច្នេះគាត់បានឈរស្ងៀមនៅទីនោះ ហើយមិនដឹងថាត្រូវធ្វើយ៉ាងណាទេ។ ពេលនេះបន្ទុករបស់គាត់ក៏ដូចជាកាន់តែធ្ងន់ឡើងសម្រាប់គាត់ ជាជាងកាលដែលគាត់ដើរតាមផ្លូវរបស់គាត់ទៅទៀត។ នៅទីនោះក៏មានភ្លើងចាំងចេញពីកំពូលភ្នំមកដែលធ្វើឱ្យគ្រីស្ទានខ្លាចថានឹងដុតបញ្ឆេះគាត់ទៅ។

**"លុះដល់ព្រឹកឡើងថ្ងៃទីបី នោះក៏មានឮសូរផ្គរមានផ្លេកបន្ទោរ និងពពកយ៉ាងក្រាស់នៅលើភ្នំ ព្រមទាំងឮសូរផ្លុំស្នែងយ៉ាងខ្លាំងក្រៃលែង រួចបណ្ដាជនទាំងឡាយដែលនៅក្នុងទីដំឡើងត្រសាល ក៏ញ័ររន្ធត់ទាំងអស់គ្នា។ នោះម៉ូសេលោកនាំគេចេញពីទីតំឡើងត្រសាលទៅជួបនឹងព្រះ គេឈរតំរៀបគ្នានៅទីជើងភ្នំ។ ឯភ្នំស៊ីណាយក៏ហុយផ្សែងឡើងពេញទាំងអស់ ដ្បិតព្រះយេហូវ៉ាទ្រង់យាងចុះមកពីលើភ្នំគង់ក្នុងភ្លើង ផ្សែងនោះហុយឡើងដូចជាផ្សែងនៃគុកភ្លើង តួភ្នំទាំងមូលក៏កក្រើករំពើកយ៉ាងខ្លាំង។" និក្ខមនំ 19:16-18**

ម្ល៉ោះហើយនៅទីនេះគាត់បានបែកញើសហើយញ័យដោយភិតភ័យ

**"ហើយការដែលគេឃើញនោះ ក៏គួរស្ញែងខ្លាចណាស់ ដល់ម្ល៉េះបានជាម៉ូសេលោកមានប្រសាសន៍ថា ខ្ញុំភ័យញ័រជាខ្លាំង។" ហេព្រើរ 12:21**

ឥលូវនេះគាត់ចាប់ផ្ដើមស្ដាយក្រោយដែលគាត់បានស្ដាប់តាមការព្រឹក្សារបស់អ្នកប្រាជ្ញខាងលោកិយ។ នោះគាត់ក៏ឃើញអ្នកផ្សាយដំណឹងល្អដើរមកជួបគាត់ ដោយឃើញដូចនោះគាត់ក៏ឡើងទឹកមុខក្របាមដោយអាម៉ាស។ ដូច្នេះអ្នកផ្សាយដំណឹងល្អបានចូលកាន់តែជិត ហើយមកកាន់កាត់ ទាំងមើល

មកគាត់ដោយទឹកមុខស្មើហើយគួរឱ្យខ្លាច ហើយគាត់បានចាប់ផ្តើមនិយាយហេតុផលជាមួយគ្រីស្ទាន។

## ផ្លូវតែមួយ

អ្នកផ្សាយដំណឹងល្អ៖ គាត់បាននិយាយថា "តើអ្នកធ្វើអ្វីនៅទីនេះ គ្រីស្ទាន? ហើយគ្រីស្ទានមិនមានពាក្យអ្វីនឹងតបនោះទេ ដូច្នេះក៏ឈរស្ងៀមនៅមុខគាត់ទៅ។ បន្ទាប់មកអ្នកផ្សាយដំណឹងល្អនិយាយថែមទៀតថា "តើអ្នកមិនមែនជាបុរសម្នាក់ដែលខ្ញុំបានឃើញយំនៅក្រៅជញ្ជាំងនៃទីក្រុងដែលត្រូវវិនាសទេឬអី?"

គ្រីស្ទាន៖ បាទ មែនហើយលោក! ខ្ញុំជាបុរសម្នាក់នោះ។

អ្នកផ្សាយដំណឹងល្អ៖ តើខ្ញុំមិនបានប្រាប់អ្នកឱ្យទៅកាន់ឃ្លោងទ្វារទុច្ចរិតតូចនោះទេឬអី? ដោយសារពេលនេះអ្នកកំពុងចេញខុសពីផ្លូវហើយ។

គ្រីស្ទាន៖ ខ្ញុំបានជួបជាមួយនឹងសុភាពបុរសម្នាក់នៅរំពេចដែលខ្ញុំបានចេញរួចពីរណ្ដៅនៃការធ្លាក់ចុះនោះ គាត់បានញុះញង់ខ្ញុំ ឱ្យទៅរកបុរសម្នាក់ដែលនៅភូមិខាងមុខខ្ញុំ ដើម្បីនឹងដកបន្ទុករបស់ខ្ញុំចេញ។

អ្នកផ្សាយដំណឹងល្អ៖ តើគាត់ជាអ្វីដែរ?

គ្រីស្ទាន៖ គាត់មើលទៅដូចជាសុភាពបុរសម្នាក់ ហើយគាត់និយាយជាច្រើនមកកាន់ខ្ញុំ ហើយចុងក្រោយខ្ញុំក៏ធ្វើតាម។ ដូច្នេះខ្ញុំក៏បានមកទីនេះ តែនៅពេលដែលខ្ញុំមើលទៅកាន់ភ្នំនេះ ហើយកាលដែលវានៅព្យួរលើផ្លូវដើរ ភ្លាមនោះខ្ញុំក៏ឈរស្ងៀម ពុំនោះវានឹងធ្លាក់សង្កត់ក្បាលខ្ញុំ។

អ្នកផ្សាយដំណឹងល្អ៖ តើសុភាពបុរសនោះនិយាយអ្វីមកអ្នក?

គ្រីស្ទាន៖ គាត់បានសួរខ្ញុំថាទៅណា ហើយខ្ញុំក៏បានប្រាប់គាត់។

អ្នកផ្សាយដំណឹងល្អ៖ ហើយបន្ទាប់មកគាត់និយាយយ៉ាងម៉េចដែរ?

គ្រីស្ទាន៖ គាត់បានសួរថាខ្ញុំមានគ្រួសារដែរទេ ហើយខ្ញុំបានប្រាប់គាត់ទៅ។ តែខ្ញុំនិយាយថាខ្ញុំមិនបន្ទុកដែលនៅលើខ្នងរបស់ខ្ញុំយ៉ាងខ្លាំង ដែលខ្ញុំមិនអាចនឹងសប្បាយនឹងការពីមុនទៀតនោះទេ។

អ្នកផ្សាយដំណឹងល្អ៖ ហើយបន្ទាប់មកតើគាត់និយាយអ្វី?

គ្រីស្ទាន៖ គាត់បានបង្ខំខ្ញុំឱ្យដើរលឿនដើម្បីនឹងដល់បន្ទុករបស់ខ្ញុំចេញ ហើយខ្ញុំបានប្រាប់គាត់ថាស្រួលហើយដែលខ្ញុំរកវាឃើញនោះ។ ខ្ញុំនិយាយថា ដូច្នេះខ្ញុំនឹងទៅកានឃ្លោងទ្វារខាងមុខដើម្បីទទួលបានការណែនាំបន្ថែមទៀតដើម្បីរកវិធីឱ្យបានទៅដល់កន្លែងដែលដោះឱ្យរួច។ ដូច្នេះគាត់បាននិយាយថា គាត់នឹងបង្ហាញផ្លូវដែលប្រសើរជាង និងខ្លីជាងដល់ខ្ញុំ ហើយជាផ្លូវដែលមិនសូវមានការលំបាកដូចដែលផ្លូវដែលលោកប្រាប់ឱ្យខ្ញុំដើរនោះទេ។ គាត់និយាយថាផ្លូវខ្លីនេះនឹងនាំខ្ញុំទៅកាន់ផ្ទះរបស់សុភាពបុរសម្នាក់ ដែលគាត់មានជំនាញក្នុងការដកយកបន្ទុកចេញ។ ខ្ញុំក៏បានជឿតាមគាត់ ហើយបានងាយចេញពីផ្លូវមកកាន់ទីនេះ ដោយគិតថាខ្ញុំអាចនឹងសម្រាលបន្ទុករបស់ខ្ញុំបានរហ័ស។ ប៉ុន្តែនៅពេលដែលខ្ញុំមកទីកន្លែងនេះ ហើយមើលឃើញសភាពជាក់ស្តែង ខ្ញុំបានឈប់នឹងថ្កល់ដោយផិតភ័យនូវគ្រោះថ្នាក់ដូចដែលខ្ញុំបាននិយាយនោះ តែពេលនេះខ្ញុំមិនដឹងថាត្រូវធ្វើអ្វីទេ។

អ្នកផ្សាយដំណឹងល្អ៖ បន្ទាប់មកអ្នកផ្សាយដំណឹងល្អបាននិយាយថា "សូមឈរនៅស្ងៀមមួយភ្លែត នោះខ្ញុំនឹងបង្ហាញព្រះបន្ទូលរបស់ព្រះ។" ដូច្នេះគាត់បានឈរដោយញាប់ញ័រ។ បន្ទាប់មកអ្នកផ្សាយដំណឹងល្អនិយាយថា "មើលទៅ ថាអ្នកនឹងមិនបដិសេធម្នាក់ដែលនិយាយនេះ។ ដ្បិតប្រសិនបើពួកគេមិនអាចគេចរួចបាន គឺអ្នកដែលបដិសេធម្នាក់ដែលនិយាយនៅលើផែនដី នោះគេកាន់តែមិនអាចគេចរួចបានឡើយ ប្រសិនបើយើងបែរចេញពីម្នាក់ដែលមានបន្ទូលមកពីស្ថានសួរ។"

**"ចូរប្រយ័ត្ន កុំឱ្យប្រកែកមិនព្រមស្តាប់តាមព្រះអង្គ ដែលទ្រង់មានបន្ទូលឡើយ ដ្បិតបើសិនជាអ្នកទាំងនោះ ដែលមិនព្រមស្តាប់តាមលោកម៉ូសេ ក្នុងកាលដែលលោកសម្តែងព្រះបន្ទូល ឱ្យស្តាប់នៅលើផែនដី គេមិនបានរួចទោសទៅហើយ នោះចំណង់បើយើងរាល់គ្នាដែលងាកបែរចេញពីព្រះ ដែលមានបន្ទូលពីស្ថានសួគ៌មក តើតឹងជាងយ៉ាងណាទៅ?" ហេព្រើរ 12:25**

គាត់បាននិយាយទៀតថា "ឥលូវនេះអ្នកសុចរិតនឹងរស់នៅដោយសេចក្តីជំនឿ ប៉ុន្តែបើអ្នកណាដែលថយក្រោយវិញ នោះព្រលឹងរបស់ខ្ញុំនឹងមិនអរសប្បាយឡើយ។"

**"តែពួកមនុស្សសុចរិតនឹងរស់នៅ ដោយអាងសេចក្តីជំនឿ បើអ្នកណាថយទៅវិញ នោះចិត្តអញគ្មានសេចក្តីអំណរចំពោះអ្នកនោះទេ។" ហេព្រើរ 10:38**

គាត់ក៏យកពាក្យទាំងនោះមកប្រើ "អ្នកជាមនុស្សដែលកំពុងរត់ទៅក្នុងសេច

ក្ដីអាក្រក់នេះ។ អ្នកចាប់ផ្ដើមបដិសេធក្រឹត្យវិន័យរបស់ព្រះដ៏ខ្ពស់បំផុត ហើយបានដកជើងរបស់អ្នកចេញពីផ្លូវនៃសេចក្ដីសុខសាន្ត ហើយស្ទើរតែប្រថុយនឹងស្ថាននរកផង។"

បន្ទាប់មកគ្រីស្ទានបានដួលចុះនៅបាតជើងរបស់គាត់ដូចស្លាប់ហើយយំស្រែកថា "ខ្ញុំត្រូវបណ្ដាសាហើយដ្បិតខ្ញុំមិនទាន់ធ្វើសម្រេចនូវឡើយ!" ដោយឃើញដូច្នោះអ្នកផ្សាយដំណឹងល្អបានចាប់ដៃស្ដាំរបស់គាត់ហើយនិយាយថា "គ្រប់ទាំងអំពើបាបនិងការប្រមាថ ត្រូវបានអត់ទោសឱ្យដល់មនុស្ស សូមកុំអត់សេចក្ដីជំនឿ តែចូរជឿវិញ។"

**"ហេតុនេះបានជាខ្ញុំប្រាប់អ្នករាល់គ្នាថា អស់ទាំងបាប ហើយពាក្យប្រមាថ និងអត់ទោសឱ្យមនុស្សលោកបាន តែពាក្យប្រមាថដល់ព្រះវិញ្ញាណវិញ នោះមិនដែលបានអត់ទោសដល់មនុស្សឡើយ។" ម៉ាថាយ 12:31**

**"រួចទ្រង់មានបន្ទូលទៅថូម៉ាស់ថា ចូរលូកម្រាមដៃអ្នកមក ស្ទាបមើលដៃខ្ញុំងណេះ ហើយលូកដៃមកចំហៀងខ្ញុំផង កុំឱ្យមានចិត្តមិនជឿឡើយ ត្រូវឱ្យជឿចុះ។" យ៉ូហាន 20:27**

បន្ទាប់មកគ្រីស្ទានក៏បានធូរស្បើយឡើង ហើយបានក្រោកឈរដោយញាប់ញ័រនៅចំពោះអ្នកផ្សាយដំណឹងល្អ។

បន្ទាប់មកអ្នកផ្សាយដំណឹងល្អបន្តនិយាយទៀត "សូមផ្ទៀងស្ដាប់ដោយយកចិត្តទុកដាក់ថែមទៀតទៅលើការដែលខ្ញុំនឹងប្រាប់ដល់អ្នក។ ពេលនេះខ្ញុំនឹងប្រាប់ដល់អ្នកថាអ្នកណាដែលបានបោកបញ្ឆោតអ្នក ហើយតើអ្នកណាជា

ម្នាក់ដែលគាត់បានបញ្ជូនអ្នកឱ្យទៅជួប។ អ្នកដែលបានជួបអ្នកនោះឈ្មោះថា អ្នកប្រាជ្ញខាងលោកិយ ហើយឈ្មោះនោះត្រូវនឹងគាត់ហើយ ដោយសារគាត់តែងតែផ្សំគ្រឿងពីគោលការណ៍ខាងលោកិយតែមួយប៉ុណ្ណោះ។″

**"ពួកនោះមកពីលោកិយទេ ដោយហេតុនោះបានគេនិយាយតាមភាពលោកិយ ហើយលោកិយក៏ស្តាប់គេដែរ។″ យ៉ូហាន ទី១ 4:5**

(ដូច្នេះគាត់តែងតែទៅទីក្រុងសីលធម៌ទៅកាន់ក្រុមជំនុំ) ហើយដោយផ្នែកគាត់ស្រឡាញ់គោលលិទ្ធិនោះណាស់ ដោយសារវាបានជួយគាត់ឱ្យរួចចេញពីឈើឆ្កាង។

**"អស់អ្នកណាដែលចង់បានឫកពាល្អខាងសាច់ឈាម នោះគេបង្ខំឱ្យអ្នករាល់គ្នាទទួលការកាត់ស្បែក ដើម្បីឱ្យតែខ្លួនគេបានរួចពីសេចក្តីបៀតបៀនដោយព្រោះឈើឆ្កាងនៃព្រះគ្រីស្ទ។″ កាឡាទី 6:12**

ហើយដោយសារតែគាត់មានចិត្តកំហឹងខាងសាច់ឈាមដូច្នេះ គាត់ក៏ស្វែងរកនឹងបង្វែរផ្លូវរបស់ខ្ញុំបើទោះជាវាត្រូវក៏ដោយ។ ពេលនេះមានការបីយ៉ាងនៅក្នុងក្រឹត្យវិន័យរបស់បុរសម្នាក់នេះ ដែលអ្នកត្រូវស្អប់ជាទីបំផុត៖

"1. គាត់បែរអ្នកឱ្យចេញពីផ្លូវ

"2. គាត់ខិតខំប្តូរឈើឆ្កាងឱ្យទៅជាគួរឱ្យស្អប់ដល់អ្នក

"3. ហើយគាត់រៀបចំជើងរបស់អ្នកទៅកាន់ផ្លូវដែលដឹកនាំទៅកាន់ទិសដៅនៃសេចក្តីស្លាប់។

"ដំបូងអ្នកគួរតែស្អប់ការដែលបែរអ្នកចេញពីផ្លូវ ពិតណាស់ចេញពីការយល់ស្របរបស់អ្នក ដោយសារវាជាការបដិសេធគំនិតដែលមកពីព្រះហើយរើសយកយោបល់របស់អ្នកប្រាជ្ញខាងលោកិយ។ ព្រះអម្ចាស់មានបន្ទូលថា ត្រូវខំចូលទៅតាមឃ្លោងទ្វារដែលនៅត្រង់។"

**"ចូរខំប្រឹងយ៉ាងអស់ពីចិត្ត ឱ្យបានចូលទៅតាមទ្វារចង្អៀត ដ្បិតខ្ញុំប្រាប់អ្នករាល់គ្នាថា នឹងមានមនុស្សជាច្រើនខំប្រឹងរកចូលដែរ តែចូលមិនបានទេ។" លូកា 13:24**

ឃ្លោងទ្វារដែលខ្ញុំប្រាប់អ្នកឱ្យទៅ ដោយសារផ្លូវដែលតូចហើយចង្អៀតនោះនាំទៅកាន់ជីវិត ហើយមានមនុស្សតិចទេដែលរកឃើញវា។

**"ចូរឱ្យចូលតាមទ្វារចង្អៀត ដ្បិតទ្វារដែលនាំទៅឯសេចក្តីហិនវិនាស នោះធំហើយទូលាយផង ក៏មានមនុស្សជាច្រើនដែលចូលតាមទ្វារនោះ។ តែឯទ្វារដែលនាំទៅឯជីវិត នោះតូច ហើយចង្អៀតវិញ ក៏មានមនុស្សតិចណាស់ដែលរកផ្លូវនោះឃើញ។" ម៉ាថាយ 7:13-14**

ចាប់ពីឃ្លោងទ្វារទុច្ចរិតតូចមួយនេះ ហើយពីផ្លូវនោះ មានមនុស្សទុច្ចរិតម្នាក់ដែលអ្នកបានបែរទៅរក ដែលស្ទើរតែទាញអ្នកទៅក្នុងសេចក្តីវិនាសអន្តរាយ។ ដូច្នេះចូរស្អប់ការដែលគាត់បង្វែអ្នកចេញពីផ្លូវ ហើយខ្ពើមខ្លួនអ្នកដែលស្តាប់ទៅកាន់គាត់។

“អ្នកត្រូវស្អប់ការខិតខំរបស់គេដែលធ្វើឱ្យឈើឆ្កាងបែរជាគួរឱ្យស្អប់ដល់អ្នក ដោយអ្នកប្រាថ្នាចង់បានសម្បត្តិនៅអេស៊ីបទៅវិញ។”

**“ដោយបានរាប់សេចក្ដីដំនៀល ដែលគេតិះដៀលដល់ព្រះគ្រីស្ទ ទុកជាទ្រព្យសម្បត្តិប្រសើរជាងអស់ទាំងថ្លៃវិសេសនៅស្រុកអេស៊ីព្ទ ដ្បិតលោកសម្លឹងចំទៅឯរង្វាន់វិញ។” ហេព្រើរ 11:26**

ក្រៅពីនោះ ស្ដេចនៃសិរីល្អបានប្រាប់អ្នកថា អ្នកដែលនឹងសង្គ្រោះជីវិតរបស់ខ្លួននឹងត្រូវបាត់បង់វាទៅ ហើយអ្នកដែលមកតាមទ្រង់ ហើយមិនស្អប់ឪពុកម្ដាយ កូន បងប្អូនប្រុសស្រីខ្លួន និងជីវិតរបស់ខ្លួនទេនោះ នោះគេមិនអាចក្លាយជាសិស្សរបស់ទ្រង់បានឡើយ។

**“អ្នកណាដែលរកបានជីវិតខ្លួន នោះនឹងត្រូវបាត់ជីវិតទៅ តែអ្នកណាដែលបាត់ជីវិតដោយយល់ដល់ខ្ញុំ អ្នកនោះនឹងបានជីវិតវិញ។” ម៉ាថាយ 10:39**

**“ដ្បិតអ្នកណាដែលចង់ឱ្យរួចជីវិត នោះនឹងបាត់ជីវិតទៅ តែអ្នកណាដែលបាត់ជីវិត ដោយព្រោះយល់ដល់ខ្ញុំ ហើយនិងដំណឹងល្អ នោះនឹងបានជីវិតវិញ។” ម៉ាកុស 8:35**

**“បើអ្នកណាមកឯខ្ញុំ ដោយមិនបានលះអាល័យពីឪពុកម្ដាយ ប្រពន្ធកូន បងប្អូនប្រុសស្រី និងជីវិតខ្លួនឯងផង អ្នកនោះនឹងធ្វើជាសិស្សខ្ញុំមិនបានទេ។” លូកា 14:26**

**"អ្នកណាដែលស្រឡាញ់ជីវិតខ្លួន នោះនឹងបាត់ជីវិតទៅ តែអ្នកណាដែលស្អប់ជីវិតខ្លួន នៅលោកិយនេះវិញ នោះនឹងរក្សាជីវិតទុកដរាបដល់អស់កល្បរៀងទៅ។" លូកា 12:25**

ដូច្នេះខ្ញុំនិយាយថា សម្រាប់មនុស្សដែលខំញុះញង់អ្នកថានឹងជាសេចក្តីស្លាប់របស់អ្នក ដែលសេចក្តីពិតមិនបាននិយាយ នោះអ្នកមិនអាចមានជីវិតអស់កល្បជានិច្ចបានឡើយ ការបង្រៀនបែបនេះអ្នកត្រូវតែស្អប់។

ទីបី អ្នកត្រូវស្អប់កាលដែលគាត់តម្រូវឱ្យជើងរបស់អ្នកនៅក្នុងផ្លូវដែលនាំទៅកាន់សេចក្តីវិនាសអន្តរាយ។ ដោយបែបនេះអ្នកត្រូវតែពិចារណាពីម្នាក់ដែលគាត់បានបញ្ជូនអ្នកទៅជួប ហើយថាបុរសម្នាក់នោះមិនមានសមត្ថភាពនឹងដោះអ្នកឱ្យរួចពីបន្ទុករបស់អ្នកបានទាល់តែសោះ។

"បុគ្គលដែលអ្នកត្រូវបានបញ្ជូនទៅជួបដើម្បីសម្រាលបន្ទុកនោះ មានឈ្មោះថា លោកស្របច្បាប់ ដែលជាកូនរបស់ស្ត្រីម្នាក់ដែលជាប់ចំណង ដែលពេលនេះនាងកំពុងនៅជាប់ចំណងជាមួយនឹងកូនៗរបស់នាង។"

**"ដ្បិតមានសេចក្តីចែងទុកមកថា លោកអ័ប្រាហាំមានកូន២ មួយកើតពីបាវស្រី ហើយមួយពីស្រីអ្នកជា។ តែកូនដែលកើតពីបាវស្រី នោះបានកើតតាមសាច់ឈាម ហើយមួយដែលកើតពីអ្នកជា បានកើតតាមសេចក្តីសន្យាវិញ។ នោះជាសេចក្តីប្រៀបធៀបគឺស្ត្រីទាំងពីរនេះជាគំរូ ពីសេចក្តីសញ្ញាពីរច្បាប់ មួយមកពីភ្នំស៊ីណាយ ក៏បង្កើតភាពជាបាវបម្រើ នោះគឺជានាងហាការ។ ដ្បិតនាងហាការទុកដូចជាភ្នំ ស៊ីណាយនៅស្រុកអារ៉ាប់ ហើយក៏ត្រូវនឹងក្រុងយេរូសាឡិម**

**សព្វថ្ងៃនេះ ជាក្រុងដែលជាប់បម្រើជាមួយនឹងកូនចៅផង។ តែក្រុងយេរូសាឡិមដែលនៅស្ថានលើ នោះជាស្រីអ្នកជាវិញ ដែលជាម្តាយយើងទាំងអស់គ្នា ។ ដ្បិតមានសេចក្តីចែងមកថា ឱនាងហាការអើយ យើងរាល់គ្នាជាកូនតាមសេចក្តីសន្យា ដូចជាលោកអ៊ីសាក់ដែរ។" ហេព្រើរ 4:22-27**

ហើយភ្នំស៊ីណាយដែលអ្នកភ័យខ្លាចនេះនឹងធ្លាក់មកកិនក្បាលរបស់អ្នក។ ឥលូវនេះ ប្រសិនបើនាងហើយនិងកូនរបស់នាងនៅក្នុងភាពជាអ្នកបម្រើ តើអ្នកអាចសង្ឃឹមថាពួកគេអាចធ្វើឱ្យមានសេរីភាពបានយ៉ាងដូចម្តេច? ដូច្នេះលោកស្របច្បាប់ម្នាក់នេះមិនអាចដោះអ្នកឱ្យមានសេរីភាពចេញពីបន្ទុករបស់អ្នកបានឡើយ។ គាត់មិនដែលដោះមនុស្សណាម្នាក់ឱ្យរួចពីបន្ទុករបស់គេបានឡើយ។ វាមិនដែលមាន ហើយក៏មិនអាចកើតមានបានដែរ។ អ្នកមិនបានទៅជាសុចរិតដោយខំធ្វើតាមក្រិត្យវិន័យនោះឡើយ ព្រោះដោយកិច្ចការខាងក្រិត្យវិន័យ គ្មានមនុស្សរស់ណាដែលអាចដល់បន្ទុករបស់ខ្លួនចេញរួចនោះឡើយ។ ដូច្នេះអ្នកប្រាជ្ញខាងលោកិយជាមនុស្សចម្លែក ហើយលោកស្របច្បាប់ជាមនុស្សបោក ហើយសម្រាប់កូនរបស់គាត់លោកថ្លៃថ្នូវិញ បើទោះជាគាត់មានមុខស្រស់ប្រិមប្រិយក៏ដោយ តែគាត់មនុស្សកំពុត ហើយមិនអាចជួយអ្នកបានឡើយ។ ចូរជឿខ្ញុំចុះថាសម្លេងដែលអ្នកបានឮពីបុរសដែលមានសម្លេងខ្សឹបខ្សៀវនេះគឺគ្មានអ្វីទាំងអស់ ប៉ុន្តែធ្វើឡើងដើម្បីនឹងល្បួងអ្នកចេញពីសេចក្តីសង្គ្រោះរបស់អ្នក ដោយបង្វែអ្នកចេញពីផ្លូវដែលខ្ញុំបានប្រាប់ឱ្យអ្នកទៅ។ បន្ទាប់ពីនេះមកអ្នកផ្សាយដំណឹងល្អបានស្រែកយំទៅកាន់ស្ថានសួគ៌ដើម្បីនឹងបញ្ជាក់អះអាងនូវអ្វីដែលគាត់បាននិយាយ នោះក៏មានព្រះបន្ទូលនិងភ្លើងចេញពីភ្នំពីខាងក្រោមកន្លែងដែលគ្រីស្ទានបានឈរ

ហើយវាបានធ្វើឱ្យភ័យបាស់រោម។ ព្រះបន្ទូលនោះត្រូវបានប្រកាសថា "មនុស្សជាច្រើនដែលនៅក្រោមកិច្ចការខាងក្រិត្យវិន័យ ក៏នៅក្រោមបណ្តាសាដែរ ដ្បិតមានចែងថា ត្រូវបណ្តាសាហើយដល់អស់អ្នកណាដែលបន្តធ្វើគ្រប់ការទាំងប៉ុន្មានដែលមានសរសេរនៅក្នុងក្រិត្យវិន័យ និងធ្វើតាមវាផង។"

**"តែអស់អ្នកដែលអាងដល់ការប្រព្រឹត្តតាមក្រឹត្យវិន័យ នោះត្រូវបណ្ដាសាវិញ ដ្បិតមានសេចក្ដីចែងទុកមកថា ត្រូវបណ្ដាសាហើយ អស់អ្នកណាដែលមិនកាន់ខ្ជាប់តាមគ្រប់ទាំងសេចក្ដី ដែលកត់ទុកក្នុងគម្ពីរក្រិត្យវិន័យ ដើម្បីនឹងប្រព្រឹត្តតាម។" កាឡាទី 3:10**

ពេលនេះគ្រីស្ទានមិនបានស្វែងរកអ្វីក្រៅពីសេចក្តីស្លាប់នោះឡើយ ហើយក៏ចាប់ផ្តើមយំទួញសោកយ៉ាងខ្លាំង ទាំងដាក់បណ្តាសាថ្ងៃដែលគាត់បានជួយជាមួយនឹងលោកប្រាជ្ញខាងលោកិយ នៅតែខ្លួនឯងថាមនុស្សល្ងង់មួយពាន់ដែលដែលស្តាប់តាមយោបល់របស់វា។ គាតមានសេចក្តីអាម៉ាស់យ៉ាងខ្លាំងនៅពេលដែលគិតពីការវែកញែករបស់សុភាពបុរសនេះ ដែលវាហូរចេញមកតែពីខាងសាច់ឈាម ហើយបានយកឈ្នះលើគាត់ ឱ្យគាត់បដិសេធផ្លូវត្រឹមត្រូវ។ បន្ទាប់មក គាត់បានដាក់ខ្លួនដើម្បីនឹងស្តាប់ ព្រមទាំងដើរតាមអ្នកផ្សាយដំណឹងល្អដូចខាងក្រោមនេះ៖

គ្រីស្ទាន៖ ឱលោកអើយ តើលោកគិតអ្វី? តើមានសង្ឃឹមអ្វីសេសសល់ដែរទេ? តើពេលនេះខ្ញុំអាចត្រលប់ទៅវិញ ហើយធ្វើដំណើរទៅកាន់ឃ្លោងទ្វារទុច្ចរិតបានដែរទេ? តើខ្ញុំមិនត្រូវបានបំបរបង់ចោល ហើយត្រូវបញ្ជូនទៅវិញ

ដោយអាម៉ាស់ដោយសារការនេះទេឬអ្វី? ខ្ញុំសោកស្តាយដែលបានស្តាប់តាមយោបល់របស់មនុស្សនេះ តែបាបរបស់ខ្ញុំអាចអត់ទោសឱ្យបានទេ?

អ្នកផ្សាយដំណឹងល្អ៖ បន្ទាប់មកអ្នកផ្សាយដំណឹងល្អបាននិយាយទៅគាត់ថា "អំពើបាបរបស់អ្នកធ្ងន់ណាស់ ដោយសារអ្នកបានប្រព្រឹត្តអំពើបាបពីរ គឺបានបដិសេធផ្លូវដែលល្អ ហើយដើរតាមផ្លូវដែលហាមឃាត់។ តែបុរសដែលនៅឃ្លោងទ្វារនឹងទទួលអ្នក ដោយសារគាត់មានតែបំណងល្អសម្រាប់មនុស្ស" គាត់និយាយថា "ចូរស្តាប់ចុះ ហើយកុំឱ្យអ្នកត្រូវបែរចេញម្តងទៀត មិនពុំនោះអ្នកនឹងវិនាសចេញពីផ្លូវនៅពេលដែលសេចក្តីក្រោធរបស់ទ្រង់ឆេះ។"

**"បានជា ឱពួកស្ងួនភ្ងាអើយ ចូរបង្ហើយសេចក្តីសង្គ្រោះរបស់អ្នករាល់គ្នា ដោយកោតខ្លាច ហើយញាប់ញ័រចុះ ដូចជាបានស្តាប់បង្គាប់ជាដរាបរៀងមកដែរ មិនមែនតែកាលខ្ញុំនៅជាមួយប៉ុណ្ណោះទេ សូម្បីឥលូវនេះដែលខ្ញុំមិននៅជាមួយនោះក៏ចូរខំប្រឹងឱ្យលើសទៅទៀតផង។" ភីលីព 2:12**

បន្ទាប់មកគ្រីស្ទានបានត្រឡប់ទៅវិញ ហើយអ្នកផ្សាយដំណឹងល្អក៏បានថើបគាត់ ញញឹមដាក់គាត់ ប្រាប់គាត់ឱ្យទៅរកព្រះ។

## បំណងល្អ៖ អ្នកយាមឃ្លោងទ្វារទុច្ចរិត

ដូច្នេះគាត់បានបន្តដំណើរដៅដោយប្រញាប់ មិននិយាយជាមួយនរណាសោះនៅតាមផ្លូវ ហើយគាត់ក៏មិនបានឆ្លើយទៅកាន់អ្នកដែលសួរផង។ គាត់ដើរទៅដូចជាម្នាក់ដែលដើរនៅលើដីដែលគេហាមឃាត់ ហើយមិនអាចគិតថាគាត់នឹងមានសុវត្ថិភាពនោះឡើយ រហូតទាល់តែគាត់បានទៅដល់ផ្លូវដែលគាត់បានបែរចេញដើម្បីដើរតាមការព្រឹក្សារបស់អ្នកប្រាជ្ញខាងលោកិយ។ ដូច្នេះ មួយរយៈក្រោយមកគ្រីស្ទានបានទៅដល់ឃ្លោងទ្វារ។ ពេលនេះនៅលើឃ្លោងទ្វារសរសេរថា "ចូរគោះ នោះនឹងបានបើកដល់អ្នក។"

**"ចូរសូម នោះនឹងឱ្យមកអ្នក ចូររក នោះតែងនឹងឃើញ ចូរគោះ នោះតែងនឹងបើកឱ្យអ្នក។" ម៉ាថាយ 7:7**

ដូច្នេះគាត់បានគោះម្តង ពីរដង ដោយនិយាយថា

"តើពេលនេះខ្ញុំអាចចូលទីនេះបានទេ?" តើអ្នកខាងក្នុងនឹងបើកទ្វារមកអាណិតខ្ញុំដែរទេ បើទោះជាខ្ញុំជាអ្នកបះបោរមិនសាកសមក៏ដោយ? បន្ទាប់មកខ្ញុំនឹងមិនខាននឹងច្រៀងបទសរសើរនៅស្ថានដ៏ខ្ពស់បំផុតឡើយ។"

ជាចុងក្រោយមានមនុស្សសំខាន់ម្នាក់មកកាន់ឃ្លោងទ្វារ ឈ្មោះលោកបំណងល្អ គាត់សួរថាតើអ្នកណានៅទីនោះ? ហើយតើគាត់មកពីពេលណា? ហើយតើគាត់ចង់បានអ្វី?

គ្រីស្ទាន៖ នេះជាមនុស្សមានបន្ទុកដោយបាបកំសត់ម្នាក់។ ខ្ញុំបានមកពីទីក្រុងនៃសេចក្តីហិនវិនាស តែខ្ញុំកំពុងទៅកាន់ភ្នំស៊ីយ៉ូន ដើម្បីឱ្យរួចពីសេចក្តីក្រោធដែលនឹងមកដល់។ ដូច្នេះ ក្នុងកាលដែលគេប្រាប់ខ្ញុំថា នៅឃ្លោងទ្វារនេះជាផ្លូវទៅទីនោះ ក៏ឱ្យដឹងថាតើអ្នកនឹងឱ្យខ្ញុំចូលទៅខាងក្រុងដែរទេ។

បំណងល្អ៖ គាត់និយាយថា ខ្ញុំមានបំណងនេះចេញពីចិត្តរបស់ខ្ញុំ។ ដោយការនោះគាត់ក៏បានបើកឃ្លោងទ្វារ។

ដូច្នេះនៅពេលដែលគ្រីស្ទានបានឈានជើងចូល ម្នាក់ទៀតបានទាញគាត់។ រួចមកគ្រីស្ទាននិយាយថា "តើវាមានន័យដូចម្តេចដែរ?" ម្នាក់ទៀតបានប្រាប់គាត់ថា "ឆ្ងាយពីនេះបន្តិចមានឃ្លោងទ្វារមួយដែលបង្កើតវិមានដ៏រឹងមាំមួយជាកន្លែងដែលបីលសេបូលធ្វើជាមេបញ្ជាការ បន្ទាប់មកទាំងគាត់និងអស់អ្នកដែលនៅជាមួយគាត់បានបាញ់ព្រួញទៅកាន់អ្នកដែលព្យាយាមឡើងមកកាន់ឃ្លោងទ្វារនោះ ដ្បិតពួកគេអាចស្លាប់បាន មុនពេលដែលគេអាចចូលទៅក្នុងបាន។" បន្ទាប់មកគ្រីស្ទាននិយាយថា "ខ្ញុំមានអំណរហើយញាប់ញ័រ។" ដូច្នេះនៅពេលដែលគាត់បានចូលខាងក្នុង អ្នកដែលនៅឃ្លោងទ្វារបានសួរគាត់ថានរណាដែលជាអ្នកដឹកនាំគាត់នៅទីនោះ។

គ្រីស្ទាន៖ អ្នកផ្សាយដំណឹងល្អបានប្រាប់ខ្ញុំឱ្យមកនេះហើយគោះទ្វារដូចដែលខ្ញុំបានធ្វើហើយ។ ហើយគាត់បាននិយាយថាលោកនឹងប្រាប់ខ្ញុំថានឹងត្រូវធ្វើអ្វី។

បំណងល្អ៖ ទ្វារដែលចំហរក៏នៅមុខអ្នកហើយ ហើយមិនមានអ្នកណាដែលអាចបិទបានឡើយ។

គ្រីស្ទាន៖ ឥលូវនេះខ្ញុំអាចប្រមូលផលនៃការប្រថុយគ្រោះថ្នាក់របស់ខ្ញុំហើយ។

បំណងល្អ៖ ហេតុអ្វីបានជាអ្នកមកតែឯងបែបនេះ?

គ្រីស្ទាន៖ ពីព្រោះគ្មានអ្នកជិតខាងណាបានមើលឃើញពីគ្រោះថ្នាក់របស់គេដូចដែលខ្ញុំឃើញគ្រោះថ្នាក់របស់ខ្ញុំឡើយ។

បំណងល្អ៖ តើមានអ្នកណាម្នាក់បានដឹងថាអ្នកមកទេ?

គ្រីស្ទាន៖ បាទ មានប្រពន្ធ និងកូនៗខ្ញុំបានឃើញខ្ញុំមកមុនគេ ហើយពួកគេបានហៅខ្ញុំឱ្យត្រឡប់ទៅវិញ។ ហើយក៏មានអ្នកជិតខាងរបស់ខ្ញុំ គេបានយំទាំងហៅខ្ញុំឱ្យត្រឡប់ទៅវិញ តែខ្ញុំបានដាក់ម្រាមដៃរបស់ខ្ញុំបិទត្រចៀក ហើយក៏មកតាមផ្លូវរបស់ខ្ញុំ។

បំណងល្អ៖ តើមិនមានអ្នកណាម្នាក់មកតាមអ្នក ដើម្បីនឹងបបួលអ្នកឱ្យត្រឡប់ទៅវិញទេឬអី?

គ្រីស្ទាន៖ បាទមាន គឺមានទាំងលោកមានៈ និងលោកងាយអូសទាញ តែនៅពេលពួកគេបានឃើញថាពួកគេមិនអាចយកឈ្នះបាន លោកមានៈបាន

ត្រឡប់ទៅវិញដោយក្រៀមក្រំ តែលោកងាយអូសទាញបានមកជាមួយខ្ញុំបានឆ្ងាយបន្តិចដែរ។

បំណងល្អ៖ តែហេតុអ្វីបានជាគាត់មកមិនរួចអីចឹង?

គ្រីស្ទាន៖ ពិតណាស់ពួកយើងបានមកជាមួយគ្នារហូតដល់រណ្ដៅនៃសេចក្ដីធ្លាក់ចុះខាងវិញ្ញាណ ដែលយើងស្រាប់តែធ្លាក់ចុះតែម្ដង។ ហើយបន្ទាប់មកអ្នកជិតខាងរបស់ខ្ញុំលោកងាយអូសទាញក៏ខកចិត្ត ហើយមិនចង់បន្តដំណើរទៅមុខទៀតឡើយ។ ដូច្នេះ គាត់ក៏បានឡើងចេញទៅត្រើយម្ខាងទៀតដែលនៅក្បែរផ្ទះរបស់គាត់ គាត់បានប្រាប់ខ្ញុំថា ខ្ញុំគួរតែកាន់កាប់ប្រទេសដែលក្លាហានម្នាក់ឯងជំនួសគាត់ទៅ ហើយគាត់ក៏ទៅតាមផ្លូវរបស់គាត់ ហើយខ្ញុំបានមកតាមផ្លូវរបស់ខ្ញុំ។ គាត់ទៅតាមលោកមានៈ ហើយខ្ញុំមកកាន់ឃ្លោងទ្វារនេះ។

បំណងល្អ៖ បន្ទាប់មកលោកបំណងល្អបាននិយាយថា "ឱ នាយកំសត់អើយ! តើសិរីល្អពីស្ថានសួគ៌មានតម្លៃតិចណាស់ឬសម្រាប់គាត់ ដែលគាត់បានរាប់ថាមិនសមនឹងប្រថុយគ្រោះថ្នាក់បន្តិចបន្តួចដើម្បីបានវាមកនោះ?"

គ្រីស្ទាន៖ គ្រីស្ទាននិយាយថា "ពិតណាស់" "ខ្ញុំបាននិយាយការពិតពីលោកងាយអូសទាញ ហើយប្រសិនបើខ្ញុំត្រូវនិយាយសេចក្ដីពិតទាំងអស់អំពីខ្លួនខ្ញុំនោះ វានឹងមិនមានភាពល្អឹងជូរចត់អ្វីរវាងគាត់និងខ្ញុំទេ។ ជាការពិតដែលគាត់បានត្រឡប់ទៅផ្ទះខ្លួនវិញ តែខ្ញុំក៏បានបែរចេញទៅរកផ្លូវនៃសេចក្ដីស្លាប់

ផងដែរ ដោយត្រូវបានអូសទាញនៅទីនោះដោយការវែកញែកខាងសាច់ឈាមរបស់លោកអ្នកប្រាជ្ញខាងលោកិយ។”

បំណងល្អ៖ អូ តើគាត់បានបំភ្លឺដល់អ្នកមែនទេ? ថាម៉េច! គាត់នឹងឱ្យអ្នកស្វែងរកដើម្បីនឹងភាពសុខស្រួលពីជំនួយរបស់លោកស្របច្បាប់ ពួកគេទាំងពីរសុទ្ធតែជាអ្នកបោកប្រាស់ តែតើអ្នកបានស្តាប់តាមការព្រិក្សារបស់គាត់ទេ?

គ្រីស្ទាន៖ បាទបាន តាមដែលខ្ញុំប្រថុយធ្វើតាម។ ខ្ញុំបានទៅរកលោកស្របច្បាប់ រហូតដល់ខ្ញុំបានគិតថាភ្នំដែលឈរនៅក្បែរផ្ទះរបស់គាត់នឹងធ្លាក់មកលើក្បាលរបស់ខ្ញុំ ដូច្នេះខ្ញុំបង្ខំឱ្យត្រូវបញ្ឈប់នៅត្រឹមនោះ។

បំណងល្អ៖ ភ្នំនោះធ្លាប់ជាសេចក្ដីស្លាប់របស់មនុស្សជាច្រើន ហើយក៏នឹងក្លាយជាសេចក្ដីស្លាប់របស់មនុស្សច្រើនទៀត ល្អហើយដែលអ្នកគិតផុតមិនត្រូវវាកំទេចអ្នកជាចំណែកៗ។

គ្រីស្ទាន៖ ខ្ញុំពិតជាមិនដឹងថាខ្ញុំនឹងក្លាយទៅជាអ្វីឡើយនៅទីនោះ អ្នកផ្សាយដំណឹងល្អបានជួបខ្ញុំម្តងទៀត ពេលដែលខ្ញុំកំពុងគិតពិចារណាក្នុងក្បាលរបស់ខ្ញុំ តែវាជាសេចក្ដីមេត្តារបស់ព្រះដែលគាត់បានមករកខ្ញុំម្តងទៀត មិនដូច្នោះទេខ្ញុំមិនបានមកដល់ទីនេះទេ។ តែពេលនេះខ្ញុំបានមកហើយ មនុស្សដូចខ្ញុំសមតែត្រូវស្លាប់ដោយសារភ្នំនោះ ជាជាងដែលឈរនិយាយជាមួយលោកម្ចាស់របស់ខ្ញុំ។ តែអូ នេះជាសេចក្ដីមេត្តាខ្លាំងណាស់ដល់ខ្ញុំ ដែលខ្ញុំបានអនុញ្ញាតឱ្យបានចូលមកទីនេះ!

បំណងល្អ៖ យើងមិនមានអ្វីជំទាស់នឹងនរណាម្នាក់ឡើយ។ ទោះជាយ៉ាងណាគ្រប់យ៉ាងដែលគេបានធ្វើមុនពេលដែលពួកគេមកទីនេះ ពួកគេមិនត្រូវបានបណ្ដេញចេញឡើយ។

**"អស់អ្នកណាដែលព្រះវរបិតាប្រទានមកខ្ញុំ នោះនឹងមកឯខ្ញុំ ហើយអ្នកណាដែលមកឯខ្ញុំ ខ្ញុំមិនដែលចោលទៅក្រៅឡើយ។" យ៉ូហាន 6:37**

ដូច្នេះគ្រីស្ទានល្អ ចូរខិតមកជិតខ្ញុំបន្តិចមក ខ្ញុំនឹងបង្រៀនអ្នកអំពីផ្លូវដែលអ្នកត្រូវទៅ។ ចូរមើលទៅខាងមុខអ្នក តើអ្នកបានឃើញផ្លូវចង្អៀតនេះទេ? នោះហើយជាផ្លូវដែលអ្នកត្រូវទៅ។ វាជាផ្លូវដែលត្រូវនាំមកពីពួកព្វយុកោ ហោរា ព្រះគ្រីស្ទ និងពួកសាវក។ ហើយវាជាផ្លូវត្រង់ដូចគូសបន្ទាត់អីចឹង នេះជាផ្លូវដែលអ្នកត្រូវទៅ។

គ្រីស្ទាន៖ គ្រីស្ទាននិយាយថា "តែវាមិនមានផ្លូវបត់ឬផ្លូវបំបែក ដែលអ្នកប្លែកមុខអាចនឹងវង្វេងផ្លូវរបស់ពួកគេ។"

បំណងល្អ៖ ពិតណាស់ មានផ្លូវជាច្រើនដែលបែកខ្នែងចេញពីផ្លូវនេះ ហើយវាវៀចវេរព្រមទាំងទូលាយផង តែអ្នកនឹងអាចបែងចែករវាងត្រូវនិងខុសបាន ផ្លូវត្រូវជាផ្លូវដែលត្រង់ភ្លឹងហើយចង្អៀតផង។

**"តែឯទ្វារដែលនាំទៅជីវិត នោះតូច ហើយចង្អៀតវិញ ក៏មានមនុស្សតូចណាស់ដែលរកផ្លូវនោះឃើញ។" ម៉ាថាយ 7:14**

បន្ទាប់មកខ្ញុំបានឃើញនៅក្នុងសុបិន្តរបស់ខ្ញុំថា គ្រីស្ទានសួរបន្ថែមទៀតថា គាត់អាចជួយដកបន្ទុករបស់គាត់ដែលនៅលើខ្នងនោះបានដែរទេ ដោយសារគាត់មិនទាន់បានដកវាចេញនៅឡើយ ហើយគាត់ក៏មិនអាចដកវាចេញដោយមិនមានជំនួយផងដែរ។

គាត់បានប្រាប់ថា "សម្រាប់បន្ទុករបស់អ្នកនោះ ចូរចេះស្កប់ចិត្តនឹងស្ពាយវារហូតទាល់តែអ្នកមកដល់កន្លែងនៃសេចក្តីប្រោសលោះ ដោយសារទីនោះវានឹងធ្លាក់ចេញពីខ្នងរបស់អ្នកដោយខ្លួនវា។"

បន្ទាប់មកគ្រីស្ទានចាប់ផ្តើមមូរដៃអាវរបស់គាត់ឡើង ហើយរៀបចំខ្លួនដើម្បីនឹងចេញដំណើរទៅ។ ដូច្នេះម្នាក់ទៀតបានប្រាប់គាត់ថា នៅពេលដែលគាត់បានទៅឆ្ងាយបន្តិចពីឃ្លោងទ្វារ គាត់នឹងទៅដល់ផ្ទះរបស់អ្នកបកប្រែ ដែលគាត់ត្រូវគោះទ្វារផ្ទះនោះ រួចគាត់នឹងបង្ហាញរបស់ល្អៗឥតខ្ចោះដល់គាត់។ បន្ទាប់មកគ្រីស្ទានបានចាកចេញពីមិត្តភក្តិរបស់គាត់ទៅ ហើយគាត់ធ្វើដំណើរសំដៅទៅរកព្រះ។

## អ្នកបកស្រាយ

បន្ទាប់មកគាត់បានដើរទៅរហូតដល់ព្រះរបស់អ្នកបកប្រែ គាត់បានគោះទ្វារ ហើយគោះទៀត ហើយទីបំផុតមានមនុស្សម្នាក់បានដើរមកទ្វារ ហើយសួរថាអ្នកណាហ្នឹង?

គ្រីស្ទាន៖ ឱលោក នេះជាអ្នកធ្វើដំណើរម្នាក់ ដែលត្រូវបានស្គាល់ដោយអ្នកជិតដិតនៅក្នុងផ្ទះឱ្យមកទីនេះទទួលប្រយោជន៍។ ដូច្នេះខ្ញុំចង់និយាយជាមួយនឹងម្ចាស់ផ្ទះ។ ដូច្នេះគាត់បានហៅរកម្ចាស់ផ្ទះ ហើយបន្តិចក្រោយមកគាត់បានចេញមករកគ្រីស្ទាន ហើយបានសួរអ្វីដែលគាត់ចង់បាន?

គ្រីស្ទាន៖ គ្រីស្ទានបាននិយាយថា "លោកម្ចាស់អើយ ខ្ញុំជាមនុស្សម្នាក់ដែលបានចាកចេញពីទីក្រុងនៃសេចក្ដីវិនាសអន្តរាយ ហើយខ្ញុំកំពុងធ្វើដំណើរទៅកាន់ភ្នំស៊ីយ៉ូន។ មានបុរសម្នាក់ដែលឈរនៅក្បែរឃ្លោងទ្វារនៅឯដើមផ្លូវនេះបានប្រាប់ខ្ញុំពីផ្លូវនេះ គាត់ថាប្រសិនបើខ្ញុំនឹងស្រែកហៅ នោះអ្នកនឹងបង្ហាញខ្ញុំពីការល្អឥតខ្ចោះជាច្រើន ដែលសុទ្ធតែជារបស់ដែលមានប្រយោជន៍សម្រាប់ខ្ញុំនៅក្នុងការធ្វើដំណើរនេះ។"

អ្នកបកប្រែ៖ បន្ទាប់មកអ្នកបកស្រាយបាននិយាយថា "ចូរមកខាងក្នុងមក ខ្ញុំនឹងបង្ហាញអ្នកពីអ្វីដែលមានប្រយោជន៍ដល់អ្នក។" គាត់ក៏ប្រាប់ដល់មនុស្សរបស់គាត់ឱ្យដុតទៀន ហើយប្រាប់គ្រីស្ទានឱ្យដើរតាមគាត់ គាត់ក៏នាំគេទៅកាន់បន្ទប់ឯកជនមួយ ហើយប្រាប់មនុស្សរបស់គាត់ឱ្យបើកទ្វារ ពេលបើករួចគ្រីស្ទានបានឃើញរូបភាពរបស់មនុស្សសំខាន់មនុស្សដែលព្យួរនៅ

ជញ្ជាំងនោះ ហើយនោះជាបែបបទរបស់វា វាមានភ្នែកមើលទៅលើមេឃ ហើយសៀវភៅដ៏ល្អបំផុតនៅក្នុងដៃរបស់គាត់ ក្រិត្យវិន័យនៃសេចក្តីពិត ដែលសរសេរនៅលើបបូរមាត់របស់គាត់ ហើយលោកិយនៅពីក្រោយគាត់ គាត់បានឈរដូចជាគាត់អង្វរមនុស្សអីចឹង ហើយមកុដមាសបានបំពាក់នៅលើក្បាលរបស់គាត់។

គ្រីស្ទាន៖ គ្រីស្ទានបាននិយាយថា "តើនេះមានន័យយ៉ាងណា?"

អ្នកបកស្រាយ៖ មនុស្សដែលនៅក្នុងរូបភាពនេះជា ម្នាក់នៅក្នុងចំណោមមនុស្ស១០០០នាក់ គាត់អាចបង្កើតកូនបាន។

**"ដ្បិតថ្វីបើអ្នករាប់គ្នាមានគ្រូរាប់ម៉ឺនក្នុងព្រះគ្រីស្ទ តែគ្មានឪពុកជាច្រើនទេ មានតែខ្ញុំមួយប៉ុណ្ណោះ ដែលបានបង្កើតអ្នករាល់គ្នាក្នុងព្រះគ្រីស្ទដោយសារដំណឹងល្អ។" កូរិនថូស ទី១ 4:15**

ដែលខំប្រឹងនៅក្នុងការផ្តល់កំណើតដល់កូនៗ

**"កូនចៅអើយ ខ្ញុំលំបាកក្នុងចិត្តជាពន់ពេក ដោយព្រោះអ្នករាល់គ្នាម្តងទៀត ទាល់តែព្រះគ្រីស្ទបានក មានរូបរាងក្នុងអ្នករាល់គ្នាឡើង។" កាឡាទី 4:19**

ហើយបំបៅពួកគេដោយផ្ទាល់នៅពេលដែលគេបានកើតមក។

**"ខ្ញុំបានឱ្យទឹកដោះមកអ្នករាល់ផឹក មិនបានឱ្យសាច់បរិភោគទេ ដ្បិតកាល នោះអ្នករាល់គ្នាពុំអាចនឹងបរិភោគបាន ហើយឥលូវនេះ ក៏មិនទាន់បានដែរ។" កូរិនថូស ទី១ 3:2**

ហើយនៅពេលដែលអ្នកឃើញគាត់សម្លឹងភ្នែកឡើងទៅលើមេឃ សៀវភៅល្អបំផុតនៅក្នុងដៃរបស់គាត់ ហើយនិងក្រឹត្យវិន័យសរសេរនៅលើបបូរមាត់របស់គាត់ គឺបង្ហាញអ្នកថាកិច្ចការរបស់គាត់នោះគឺ ដើម្បីស្គាល់និងលាតត្រដាងកិច្ចការពីការខាងសេចក្តីងងឹតដល់មនុស្សមានបាប។ អ្នកទាំងឃើញថាគាត់បានឈរដូចជាគាត់កំពុងអង្វរដល់មនុស្សផង ហើយលោកិយត្រូវបោះចោលនៅខាងក្រោយគាត់ ហើយមកុដពាក់នៅលើក្បាលរបស់គាត់ គឺដើម្បីបង្ហាញដល់អ្នកថា ការបន្ថោកនិងមើលងាយដល់កិច្ចការខាងលោកិយនាពេលបច្ចុប្បន្ន ដើម្បីសេចក្តីស្រឡាញ់ដែលគាត់មានចំពោះកិច្ចការរបស់ម្ចាស់របស់គាត់ គាត់ដឹងប្រាកដពីពិភពលោកដែលនឹងត្រូវមកដែលមានសិរីល្អជារង្វាន់ដល់គាត់។ ពេលនេះអ្នកបកស្រាយបាននិយាយថា ខ្ញុំបានបង្ហាញរូបភាពនេះដល់អ្នកជាដំបូងបង្អស់ ដោយសារមនុស្សដែលនៅក្នុងរូបភាពនេះ ជាបុរសតែម្នាក់គត់ដែលព្រះអម្ចាស់នៃកន្លែងនោះបានផ្តល់នូវឫទ្ធិអំណាច ឱ្យបានធ្វើជាអ្នកដឹកនាំរបស់អ្នកនៅទីកន្លែងដែលពិបាកៗដែលអ្នកនឹងជួបនៅតាមផ្លូវ។ ដូច្នេះ ចូរស្តាប់ឱ្យបានល្អទៅកាន់អ្វីដែលខ្ញុំបានបង្ហាញដល់អ្នក ហើយរក្សាវាទុកនៅក្នុងគំនិតរបស់អ្នកនូវអ្វីដែលអ្នកបានឃើញ បើមិនដូច្នោះទេនៅក្នុងដំណើររបស់អ្នក អ្នកនឹងជួយមនុស្សមួយចំនួនដែលនឹងធ្វើពុតដូចជាអ្នកនាំទៅកាន់ផ្លូវត្រូវ តែផ្លូវរបស់គេទៅកាន់សេចក្តីវិញ។

បន្ទាប់មកក៏ចាប់ដៃរបស់គាត់ ហើយនាំគាត់ទៅកាន់ឃ្លាំងដ៏ធំមួយដែលពេញដោយធូលី ពីព្រោះមិនដែលបោសសោះ ហើយបន្ទាប់ពីគាត់បានសង្កេតមើលបន្តិចមក អ្នកបកស្រាយបានហៅមនុស្សមកបោសសំអាត។ ឥលូវនៅពេលដែលគាត់ចាប់ផ្តើមសំអាត ធូលីចាប់ផ្តើមហើរឡើងយ៉ាងបរិបូរ ដែលគ្រីស្ទានស្ទើតែឈ្លក់។ បន្ទាប់មកអ្នកបកស្រាយបាននិយាយទៅកាន់នារីក្មេងម្នាក់ដែលឈរនៅក្បែរថា "សូមយកទឹកមកនេះ ហើយបាយនៅក្នុងបន្ទប់នេះ" ហើយបន្ទាប់ពីនាងធ្វើរួច នោះវាក៏បានបោសស្អាតដោយអំណរ។

គ្រីស្ទាន៖ គ្រីស្ទានក៏និយាយថា "តើនេះមានន័យយ៉ាងណា?"

អ្នកបកស្រាយ៖ អ្នកបកស្រាយបានឆ្លើយថា "ឃ្លាំងនេះជាចិត្តរបស់មនុស្សដែលមិនដែលបានបន្សុតដោយព្រះគុណដ៏ផ្អែមនៃដំណឹងល្អ។ ធូលីជាអំពើបាបដើម និងសេចក្តីរលួយនៅខាងក្នុង ដែលបានធ្វើឱ្យមនុស្សទាំងមូលទៅជាអាក្រក់។ អ្នកដែលមកបោសពីដំបូង នោះជាក្រឹត្យវិន័យ តែនារីដែលបានយកទឹកមក  ហើយបាយទឹកនោះ ជាដំណឹងល្អ។ ឥលូវនេះ ដូចដែលអ្នកបានឃើញថា ភ្លាមៗដែលគេចាប់ផ្តើមបោសនោះ ធូលីក៏ហោះពាសពេញទាំងអស់ ហើយបន្ទប់ក៏មិនអាចនឹងស្អាតបានដោយសារគាត់ដែរ ហើយអ្នកស្ទើតែឈ្លក់នៅទីនោះ នេះបង្ហាញមកអ្នកថា ជំនួសឱ្យការសម្អាតចិត្តពីបាបនោះក្រឹត្យវិន័យធ្វើឱ្យបាបនោះរស់ឡើងវិញ បន្ថែមកម្លាំងដល់វា ហើយវាបានចម្រើននៅក្នុងព្រលឹង ទាំងបានរកឃើញនិងហាមវាផង ដោយសារវាមិនបានផ្តល់អំណាចដើម្បីបង្រាបឡើយ។"

**“តែក្រឹត្យវិន័យបានចូលមកថែមទៀត ដើម្បីឱ្យសេចក្តីរំលងនោះបានរឹតតែធ្ងន់ឡើង ប៉ុន្តែកន្លែងណាដែលមានបាបចម្រើនជាបរិបូរឡើង នោះព្រះគុណក៏ចម្រើនជាបរិបូរលើសទៅទៀត។” រ៉ូម 5:20**

**“តែពីដើម ក្រៅពីក្រឹត្យវិន័យ នោះខ្ញុំបានរស់នៅ លុះសេចក្តីបញ្ញត្តិបានកើតមក នោះបាបក៏រស់ឡើង ឯខ្ញុំក៏ត្រូវស្លាប់វិញ។” រ៉ូម 7:9**

**“រីឯទ្រនិចនៃសេចក្តីស្លាប់ គឺជាអំពើបាប ហើយអំណាចរបស់បាប គឺជាក្រឹត្យវិន័យ។” កូរិនថូស ទី១ 15:56**

“ម្តងទៀត នៅពេលដែលអ្នកឃើញនារីក្មេងប្រោះទឹកទៅក្នុងបន្ទប់ នោះបន្ទប់ក៏បានស្អាតដោយមានអរសប្បាយ (ងាយ) នេះបង្ហាញអ្នកថា នៅពេលដែលដំណឹងល្អមកដល់ វាមានឥទ្ធិពលយ៉ាងផ្អែមល្ហែមនិងមានតម្លៃបែបនោះ ដល់ចិត្ត។ បន្ទាប់មកខ្ញុំនិយាយថានៅពេលដែលអ្នកបានឃើញ នារីក្មេងបានប្រោះទឹកទៅកាន់ធូលីដែលនៅផ្ទៃខាងក្រោមនៃបន្ទប់ នោះអំពើបាបត្រូវរលាយហើយត្រូវបង្ក្រាបបាន ហើយព្រលឹងត្រូវបានសម្អាតតាមរយៈសេចក្តីជំនឿ ហើយជាចុងក្រោយសាកសមនឹងស្តេចនៃសិរីល្អមកគង់កាន់កាប់បាន។”

**“ឯអ្នករាល់គ្នាបានស្អាតហើយ ដោយពាក្យដែលខ្ញុំបានប្រាប់។” យ៉ូហាន 15:3**

**“ទ្រង់មិនបានរាប់ពួកយើង និងពួកគេ ខុសគ្នាទេ គឺបានសម្អាតចិត្តគេដោយសារសេចក្តីជំនឿដែរ។” កិច្ចការ 15:9**

**"រីឯព្រះដែលអាចនឹងតាំងអ្នករាល់គ្នា ឱ្យខ្ជាប់ខ្ជួនតាមដំណឹងល្អខ្ញុំ និងតាមខ្លឹមនៃលិទ្ធិរបស់ព្រះយេស៊ូវគ្រីស្ទ ដែលត្រូវនឹងសេចក្ដីបើកសម្ដែង អំពីការអាថ៌កំបាំង ដែលបានលាក់ទុកនៅអស់ទាំងកល្បរៀងមក។ តែឥលូវនេះបានបើកសម្ដែងមក ឱ្យទាំងសាសន៍ដឹង ដោយសារគម្ពីរហោរា តាមបង្គាប់នៃព្រះដ៏មានព្រះជន្មរស់អស់កល្បជានិច្ច ដើម្បីឱ្យគេបានចុះចូលជឿ ដោយសារព្រះយេស៊ូវគ្រីស្ទ។" រ៉ូម 16:25, 25**

**"ដើម្បីឱ្យទ្រង់បានញែកពួកជំនុំចេញជាបរិសុទ្ធ ដោយបានលាងសម្អាតនឹងទឹក គឺជាព្រះបន្ទូល។" អេភេសូ 5:26**

ខ្ញុំបានឃើញនៅក្នុងសុបិន្តរបស់ខ្ញុំទៀតថា អ្នកបកស្រាយបានចាប់ដៃរបស់គាត់ ហើយនាំចូលទៅក្នុងបន្ទប់តូចមួយ ដែលមានក្មេងតូចពីនាក់អង្គុយនៅលើកៅអីម្នាក់មួយ។ ក្មេងបងមានឈ្មោះថាចំណង់ ហើយម្នាក់ទៀតឈ្មោះអត់ធ្មត់។ ចំណង់ហាក់បីដូចជាមិនចេះស្កប់ស្កល់សោះ តែអត់ធ្មត់នៅស្ងៀមស្ងាត់វិញ។ បន្ទាប់មកគ្រីស្ទានបានសួរថា "តើអ្វីទៅជាហេតុផលដែលចំណង់មិនចេះស្កប់ចិត្ត?" អ្នកបកស្រាយបានឆ្លើយថា "អ្នកគ្រប់គ្រងរបស់គាត់ចង់ឱ្យគាត់នៅទទួលរបស់ដ៏ល្អបំផុតរបស់គាត់រហូតដល់ដើមឆ្នាំក្រោយ តែគាត់ចង់បានវានៅពេលនេះ តែអត់ធ្មត់ស្ម័គ្រចិត្តនឹងរងចាំវិញ។"

បន្ទាប់មកខ្ញុំបានឃើញម្នាក់បានមកកាន់ចំណង់ ហើយយកកំណព្វមួយស្រោងឱ្យគាត់ ហើយក៏ចាក់វាចេញនៅក្បែរជើងគាត់ គាត់ក៏យកវាមកហើយសប្បាយជាមួយវា ហើយក៏សើចចំអកដល់អត់ធ្មត់។ ប៉ុន្តែខ្ញុំបានមើលមួយសន្ទុះមក នោះវាបានរលាយបាត់មួយរំពេច ហើយគ្មានអ្វីសល់សោះ។

គ្រីស្ទានៈ បន្ទាប់មកគ្រីស្ទាននិយាយទៅកាន់អ្នកបកស្រាយថា "ចូរបកស្រាយពន្យល់ពីការនេះឱ្យពេញលេញដល់ថែមទៀតដល់ខ្ញុំផង"

អ្នកបកស្រាយៈ ដូច្នេះគាត់បាននិយាយថា "ក្មេងទាំងពីនេះជារូបតំណាងចំណង់ ជាតំណាងនៃមនុស្សនៅក្នុងលោកិយនេះ ហើយអត់ធ្មត់ ជាតំណាងនៃមនុស្សនៃលោកិយដែលនឹងមកដល់។ ទីនេះអ្នកបានឃើញចំណង់នឹងទទួលបានរបស់ទាំងអស់នៅឆ្នាំនេះ នោះចង់និយាយថា នៅក្នុងលោកិយនេះ។ ហើយមនុស្សទាំងអស់លើលោកិយនេះសុទ្ធតែចង់បាន ពួកគេនឹងត្រូវបានរបស់ល្អៗនៅពេលនេះ ពួកគេមិនអាចចាំដល់ឆ្នាំក្រោយឡើយ ដែលជាផែនដីដែលនឹងមកសម្រាប់ចំណែកល្អរបស់ពួកគេ។ សុភាសិតដែលថា បក្សីមួយនៅក្នុងដៃមានតម្លៃជាងបក្សីពីដែលនៅក្នុងគុម្ពបន្លា។ ហើយវាមានអំណាចដល់គេជាជាងទីបន្ទាល់ទាំងប៉ុន្មានរបស់ព្រះ ដែលនិយាយពីការល្អនៃលោកិយដែលនឹងមកដល់ទៅទៀត។ តែដូចដែលអ្នកឃើញហើយថា វានឹងត្រូវហោចទៅយ៉ាងរហ័ស ហើយមិនមានអ្វីនៅសល់ជាមួយគាត់សោះ មានតែកន្ទប ដូច្នេះវាជាអ្វីដែលមនុស្សបែបដូច្នោះនឹងទទួលបាននៅទីបញ្ចប់នៃលោកិយនេះ។"

គ្រីស្ទានៈ បន្ទាប់មកគ្រីស្ទានបាននិយាយថា "ពេលនេះ ខ្ញុំដឹងថាអត់ធ្មត់មានប្រាជ្ញាប្រសើរជាង ដោយសារការជាច្រើន៖ 1. គាត់រងចាំការដ៏ល្អបំផុត។ 2. ហើយដោយសារគាត់នឹងមានសិរីល្អដែលជារបស់គាត់ផង នៅពេលដែលម្នាក់ទៀតមិនមានអ្វីសោះក្រៅពីកន្ទប។"

អ្នកបកស្រាយ៖ ទេ តែអ្នកអាចបន្ថែមការមួយទៀតទៅលើការនោះ នោះជាសិរីល្អនៃលោកិយដែលនឹងមកដល់ដែលមិនដែលខូចបង់ទៅឡើយ។ តែរបស់លោកិយនេះនឹងបាត់បង់ទៅមួយរំពេច។ ដូច្នេះចំណង់មិនមានហេតុផលច្រើនដើម្បីនឹងសើចចំអកដល់អត់ធ្មត់នោះទេ ពីព្រោះពេលនេះគាត់ទទួលបានរបស់ដែលល្អរួចហើយ សម្រាប់អត់ធ្មត់វិញនឹងត្រូវសើចដាក់ចំណង់វិញ ពីព្រោះគាត់ទទួលបានរបស់ល្អរបស់គាត់ជាចុងក្រោយដោយសារអ្នកមុននឹងត្រូវប្រគល់ដំណែងដល់អ្នកដែលមកក្រោយដោយសារអ្នកដែលមកក្រោយនឹងមានពេលដែលត្រូវមកដល់ ប៉ុន្តែអ្នកដែលមកក្រោយមិនត្រូវប្រគល់កន្លែងទៅណាទៀតនោះឡើយ ដោយសារមិនមានអ្នកណាដែលនឹងមកបន្តទៀតនោះទេ។ ដូច្នេះ អ្នកដែលទទួលបានចំណែកមុននឹងមានពេលដែលនឹងចាយវាយវាទៅអស់ តែអ្នកដែលទទួលបានចំណែកជាក្រោយ នោះនឹងនៅជាប់ជារៀងដរាបទៅ។ ដូច្នេះមាននិយាយពីអ្នកមានថា "នៅក្នុងពេញមួយជីវិតអ្នក អ្នកបានទទួលសុទ្ធតែរបស់ល្អៗ តែឡាសាបានទទួលការអាក្រក់វិញ ប៉ុន្តែពេលនេះគាត់បានទទួលការកំសាន្តវិញ ហើយអ្នកទទួលបានការទួញសោកវិញ។"

**"តែលោក អ័ប្រាហាំ ឆ្លើយថា កូនអើយ ចូរនឹងចាំថាកាលឯងនៅរស់នៅឡើយ ឯងបានទទួលសុទ្ធតែសេចក្ដីល្អ ឯឡាសារគាត់បានតែសេចក្ដីអាក្រក់ទេ ឥឡូវនេះគាត់បានសេចក្ដីកំសាន្តចិត្តវិញ ហើយឯងត្រូវវេទនា។" លូកា 16:25**

គ្រីស្ទាន៖ អីចឹង ខ្ញុំយល់ឃើញថា វាមិនសូវល្អទេដែលលោភនូវរបស់នាបច្ចុប្បន្ននេះ តែគួររងចាំការដែលនឹងមកដល់វិញ។

អ្នកបកស្រាយៈ អ្នកនិយាយត្រូវហើយ "ដោយសារការដែលមើលឃើញនោះនៅតែមួយរយៈទេ តែការដែលមើលមិនឃើញនៅអស់កល្បជានិច្ច។"

**"ដោយយើងមិនរាប់អានរបស់ដែលមើលឃើញឡើយ គឺរាប់អានតែរបស់ដែលមើលមិនឃើញវិញ ដ្បិតរបស់ដែលមើលឃើញ នោះស្ថិតស្ថេរមិនយូរប៉ុន្មានទេ តែឯរបស់ដែលមើលមិនឃើញ នោះនៅស្ថិតស្ថេរអស់កល្បជានិច្ចវិញ។" កូរិនថូស ទី២ 4:18**

ប៉ុន្តែបើទោះជាវាបែបនេះក៏ដោយ ក្នុងកាលដែលការបច្ចុប្បន្ននេះនិងសម្រេកខាងសាច់ឈាមរបស់យើង ប្រៀបដូចនឹងអ្នកជិតខាងគ្នាទៅវិញទៅមក ហើយដោយសារការដែលនឹងមកនិងញាណខាងសាច់ឈាមជាអ្នកមិនដែលស្គាល់គ្នា ដូច្នេះវាអ្នកដែលមកមុននឹងធ្លាក់ទៅក្នុងភាពជាសត្រូវ ហើយគំលាតនោះនៅតែបន្តរហូតជាមួយនឹងការដែលមកទីពីរ។

រួចខ្ញុំបានឃើញនៅក្នុងសុបិន្តរបស់ខ្ញុំថា អ្នកបកស្រាយបានចាប់ដៃរបស់គ្រីស្ទាន ហើយបាននាំគាត់ទៅកន្លែងមួយ ដែលមានភ្លើងឆេះក្បែរជញ្ជាំងហើយម្នាក់ដែលឈរនៅក្បែរនោះតែតែជះទឹកដើម្បីនឹងពន្លត់វា តែភ្លើងកាន់តែឆេះខ្លាំងទៅៗ។

គ្រីស្ទានៈ បន្ទាប់មកគ្រីស្ទានបាននិយាយថា "តើនេះមានន័យយ៉ាងណា?"

អ្នកបកស្រាយៈ អ្នកបកស្រាយបានឆ្លើយថា "ភ្លើងនេះជាកិច្ចការនៃព្រះគុណដែលមាននៅក្នុងចិត្ត អ្នកដែលជះទឹកញែកវានិងពន្លត់វានោះ ជាអារក្ស តែអ្នកឃើញថាភ្លើងមិនបានរលត់ទេ តែឆេះកាន់តែក្តៅខ្លាំងឡើងៗ អ្នកក៏នឹង

ដឹងពីហេតុផលនោះដែរ។ រួចគាត់បាននាំគាត់ទៅក្បែរជញ្ជាំងដែលនៅខាងក្រោយជញ្ជាំង ដែលគាត់បានឃើញបុរសម្នាក់មានភាជនៈដាក់ប្រេងនៅក្នុងដៃរបស់គាត់ ដែលគាត់តែងតែចាក់បន្តបន្ទាប់ តែចាក់ដោយសម្ងាត់ទៅក្នុងភ្លើង។"

គ្រីស្ទាន៖ រួចគ្រីស្ទាននិយាយថា "តើនេះមានន័យយ៉ាងណា?"

អ្នកបកស្រាយ៖ អ្នកបកស្រាយបានឆ្លើយថា "នេះជាព្រះគ្រីស្ទ ជាអ្នកដែលបន្តចាក់ប្រេងនាំព្រះគុណដើម្បីនឹងពង្រឹងដល់កិច្ចការដែលបានចាប់ផ្តើមរួចនៅក្នុងចិត្ត ដោយមិនត្រូវបំផ្លាញដោយការដែលអារក្សអាចធ្វើបាននោះឡើយ ហើយព្រលឹងរបស់រាស្ត្រទ្រង់នឹងមានពេញដោយព្រះគុណដដែល។"

**"តែទ្រង់មានបន្ទូលមកខ្ញុំថា គុណរបស់អញល្មមដល់ឯងហើយ ដ្បិតកំលាំងអញបានពេញខ្នាត ដោយសេចក្តីកំសោយ ដូច្នេះខ្ញុំនឹងស៊ូអួតពីសេចក្តីកំសោយរបស់ខ្ញុំ ដោយអំណរជាខ្លាំង ដើម្បីឲ្យចេស្តានៃព្រះគ្រីស្ទ បានសណ្ឋិតនៅនឹងខ្ញុំ។" កូរិនថូស ទី២ 12:9**

ហើយកាលដែលអ្នកបានឃើញបុរសម្នាក់នៅខាងក្រោយជញ្ជាំងដែលនៅរក្សាភ្លើង នេះចង់បង្រៀនអ្នកថា វាពិបាកណាស់សម្រាប់នឹងឱ្យអ្នកដែលត្រូវល្បួងដឹងពីរបៀបដែលកិច្ចការនៃព្រះគុណធ្វើការរក្សាព្រលឹងនោះ។"

ខ្ញុំបានឃើញផងដែរថាអ្នកបកស្រាយ បានចាប់ដៃគាត់ម្តងទៀត ហើយបាននាំគាត់ទៅកាន់កន្លែងដែលល្អ ដែលមានរាជវាំងដែលត្រូវបានសង់នៅទីនោះយ៉ាងមាំ ដែលស្រស់ស្អាតគួរឱ្យគួយគន់ ដោយទស្សនិយភាពនោះបានធ្វើឱ្យគ្រីស្ទានមានអំណរយ៉ាងខ្លាំង។ គាត់ក៏ឃើញនៅលើកំពូលមានមនុស្សម្នាក់កំពុងដើរ ដែលមានស្លៀកពាក់មាស។

គ្រីស្ទានៈ បន្ទាប់មកគ្រីស្ទានបាននិយាយថា "តើយើងអាចទៅទីនោះទេ?"

បន្ទាប់មកអ្នកបកស្រាយបានយកគាត់ ហើយនាំទៅកាន់ទ្វារនៃបរមរាជវាំងហើយមើល មានមនុស្សមួយក្រុមធំឈរនៅមាត់ទ្វារ ដែលពួកគេប្រថ្នាចង់ចូលទៅខាងក្នុង តែចូលមិនបាន។ មានបុរសម្នាក់អង្គុយនៅឆ្ងាយបន្តិចពីទ្វារ នៅក្បែរតុ មានសៀវភៅមួយនិងជក់នៅខាងមុខគាត់ ដើម្បីនឹងសរសេរឈ្មោះអ្នកដែលនឹងចូលក្នុងបាន។ គាត់ក៏បានឃើញនៅចន្លោះផ្លូវចូលទ្វារមានមនុស្សជាច្រើនមានអាវុធ នៅរក្សាទ្វារ ដើម្បីដោះស្រាយជាមួយនឹងអ្នកដែលចូលធ្វើឱ្យមានការឈឺចាប់និងការបោកបន្លំ គ្រីស្ទានមានអារម្មណ៍កោតសរសើរ។ ចុងក្រោយមនុស្សម្នាក់ៗចាប់ផ្តើមថយទៅវិញ ដោយសារខ្លាចអ្នកយាម គ្រីស្ទានបានឃើញមនុស្សម្នាក់ដែលមានទឹកមុខក្លាហានចេញមកកាន់បុរសម្នាក់ដែលអង្គុយសរសេរនោះ ដោយនិយាយថា "សូមបញ្ចូលឈ្មោះខ្ញុំផង លោក" បន្ទាប់ពីចប់នោះ គាត់ឃើញមនុស្សម្នាក់បានហូតដាវរបស់គាត់ចេញមក ហើយពាក់ពួកការពារនៅលើក្បាលរបស់គាត់ហើយប្រញាប់រត់ទៅកាន់ទ្វារទៅកាន់អ្នកការពារ នោះគេបានប្រើកម្លាំងខ្លាំងដល់ពួកគេ ប៉ុន្តែបុរសនោះមិនបាក់ទឹកចិត្តឡើយ បានដួលដោយសារត្រូវបានកាត់និងភ្លាសសាច់យ៉ាងខ្លាំង។ ដូច្នេះ បន្ទាប់ពីគាត់បានទទួលបាន

របួសយ៉ាងច្រើនពីអ្នកដែលព្យាយាមឃាត់មិនឱ្យចូលទៅក្នុង គាត់បានច្រាន ពួកគេផុតទៅ ហើយបានសម្រុកទៅកាន់វាំង។

**"ព្រមទាំងចម្រើនកម្លាំងដល់ពួកសិស្ស ឱ្យមានចិត្តរឹងប៉ឹងឡើង ហើយទូន្មាន ឱ្យនៅស្ថិតស្ថេរក្នុងសេចក្តីជំនឿ ដោយពាក្យថា ត្រូវតែទ្រាំរងវេទនាជាច្រើន ទើបនឹងចូលទៅក្នុងនគរព្រះបាន។" កិច្ចការ 14:22**

ទីនោះមានសម្លេងយ៉ាងពីរោះឮចេញពីអ្នកដែលនៅខាងក្នុង ទាំងអ្នកដែល ដើរលើកំពូលនៃវាំង និយាយថា "ចូលមក! ចូរមក!" "អ្នកនឹងឈ្នះសិរីល្អនៅ អស់កល្ប"

ដូច្នេះគាត់បានចូលទៅខាងក្នុង ហើយត្រូវបានស្លៀកពាក់សំលៀកបំពាក់ ដូចពួកគេដែរ។ បន្ទាប់មកគ្រីស្ទានបានញញឹម ហើយនិយាយថា "ពិត ណាស់ខ្ញុំគិតថា ខ្ញុំយល់អត្ថន័យនៃការនេះ។"

គ្រីស្ទាននិយាយថា "ឥលូវ" "សូមឱ្យខ្ញុំទៅទីនោះ"

អ្នកបកស្រាយបាននិយាយថា "ទេ ចូរស្នាក់នៅចុះ" "រហូតដល់ខ្ញុំបានបង្ហាញ អ្នកបន្តិចទៀត ហើយបន្ទាប់មកអាចនឹងទៅតាមផ្លូវរបស់អ្នកបាន។" រួចក៏ ចាប់ដៃរបស់គាត់ម្តងទៀត ហើយនាំគាត់ទៅបន្ទប់ងងឹតមួយ ដែលមាន បុរសម្នាក់អង្គុយនៅក្នុងទ្រុងដែកមួយ។

ឥលូវពេលមើលទៅ បុរសនោះហាក់បីដូចជាក្រៀមក្រំខ្លាំងណាស់។ គាត់ អង្គុយដោយភ្នែកសម្លឹងមើលចុះទៅដី ហើយគាត់ដាក់ដៃរបស់គាត់ជាមួយ

គ្នា ហើយគាត់ដកដង្ហើមធំហាក់ដូចជាបំបែកចិត្តរបស់គាត់អីចឹង។ បន្ទាប់មកគ្រីស្ទានបាននិយាយថា "តើនេះមានន័យយ៉ាងណា?" នោះអ្នកបកស្រាយក៏ប្រាប់គាត់ឱ្យទៅនិយាយជាមួយបុរសនោះតែម្តង។

គ្រីស្ទាន៖ បន្ទាប់មកគ្រីស្ទានបាននិយាយទៅកាន់បុរសនោះថា "តើអ្នកជាអ្វី?"

អ្នកបែរថយក្រោយ៖ បុរសនោះក៏ឆ្លើយថា "ខ្ញុំជាអ្វី ដែលពីមុនខ្ញុំមិនមែននោះឡើយ។"

គ្រីស្ទាន៖ តើម្តងនោះអ្នកជាអ្វី?

អ្នកបែរថយក្រោយ៖បុរសនោះនិយាយថា "ម្តងនោះខ្ញុំជាសាស្ត្រាចារ្យយ៉ាងត្រឹមត្រូវហើយសមប្រកបម្នាក់ ទាំងនៅក្នុងភ្នែករបស់ខ្ញុំនិងអ្នកដទៃ។ ពីមុនខ្ញុំបើតាមខ្ញុំគិតថាខ្ញុំសាកសមនឹងទីក្រុងស្ថានសួគ៌ ហើយខ្ញុំថែមទាំងមានអំណរដោយគ្រាន់តែគិតថាខ្ញុំនឹងទៅដល់ទីនោះ។"

**"ឯពួកអ្នកដែលទទួលនៅលើថ្ម គឺអស់អ្នកដែលកាលណាឮព្រះបន្ទូលហើយនោះក៏ទទួលដោយអំណរ តែគ្មានចាក់ឫសសោះ គេជឿនៅតែមួយស្របក់ប៉ុណ្ណោះ លុះកើតមានសេចក្តីល្បួង នោះគេរសាយចិត្តទៅវិញ។" លូកា 8:13**

គ្រីស្ទាន៖ អីចឹង តើឥលូវអ្នកជាអ្វីដែរ?

អ្នកបែរថយក្រោយ៖ ពេលនេះខ្ញុំជាមនុស្សម្នាក់ដែលវេទនាម្នាក់ ខ្ញុំត្រូវបានឃុំឃាំងនៅក្នុងវា ប្រៀបដូចជាទ្រុងដែកនេះ។ ខ្ញុំមិនអាចចេញក្រៅបានទេ។ ពេលនេះ ខ្ញុំមិនអាចចេញរួចឡើយ!”

គ្រីស្ទាន៖ តែតើអ្នកស្ថិតនៅក្នុងស្ថានភាពបែបនេះបានយ៉ាងដូចម្ដេច?

អ្នកបែរថយក្រោយ៖ ខ្ញុំបានចាកចេញទៅដើម្បីនឹងមើលហើយបានសម្រាក។ ខ្ញុំបានដាក់ការសោយរាជ្យនៅលើកនៃសេចក្តីតណ្ហារបស់ខ្ញុំ។ ខ្ញុំបានធ្វើបាបទាស់នឹងពន្លឺនៃលោកិយ និងសេចក្តីសប្បុរសរបស់ព្រះ។ ខ្ញុំបានធ្វើឱ្យព្រះវិញ្ញាណព្រួយ ហើយទ្រង់ក៏បានចាកចេញទៅ។ ខ្ញុំបានល្បួងដល់អារក្ស ហើយវាបានមកឯខ្ញុំ។ ខ្ញុំបានធ្វើឱ្យព្រះខ្ញាល់ ហើយទ្រង់បានចាកចោលខ្ញុំ។ ខ្ញុំបានធ្វើចិត្តរឹងយ៉ាងខ្លាំង រហូតដល់ខ្ញុំមិនអាចនឹងប្រែចិត្តបាន។

បន្ទាប់មកគ្រីស្ទានបាននិយាយទៅកាន់អ្នកបកស្រាយថា “ប៉ុន្តែតើមិនមានសេចក្តីសង្ឃឹមសម្រាប់មនុស្សដូចនេះទេឬយ៉ាងណា?” អ្នកបកស្រាយនិយាយថា “ចូរសួរគាត់ទៅ”

អ្នកបែរថយក្រោយ៖ ទេ គ្មានសោះឡើយ។

គ្រីស្ទាន៖ ហេតុអ្វីទៅ? បុត្ររបស់អ្នកមានពរគួរឱ្យអាណិតណាស់។

អ្នកបែរថយក្រោយ៖ ខ្ញុំបានឆ្កាងទ្រង់ទៅកាន់ខ្លួនខ្ញុំជាថ្មីម្តងទៀត។

"រួចធ្លាក់ទៅវិញ នោះគ្មានផ្លូវណានឹងនាំឱ្យគេប្រែចិត្តម្តងទៀតទេ ដោយព្រោះគេបានឆ្កាងព្រះរាជ្យបុត្រានៃព្រះ ខាងឯខ្លួនគេរួចទៅហើយ ព្រមទាំងធ្វើឱ្យទ្រង់ហាលមុខនៅកណ្តាលជំនុំផង។" ហេព្រើរ 6:6

ខ្ញុំបានមើលថោកដល់រូបអង្គទ្រង់

"ប៉ុន្តែពួកអ្នកស្រុករបស់លោក គេស្អប់លោកណាស់ ក៏ចាត់សារឱ្យទៅតាមក្រោយលោក ទូលថា យើងរាល់គ្នាមិនចង់ឱ្យមនុស្សនេះសោយរាជ្យលើយើងទេ។" លូកា 19:14

ខ្ញុំបានមើលថោកដល់សេចក្តីសុចរិតរបស់ទ្រង់។ ខ្ញុំបានរាប់ព្រះលោហិតទ្រង់ជារបស់ដែលមិនបរិសុទ្ធ។ ខ្ញុំបានធ្វើការជំនួសឱ្យព្រះគុណរបស់ព្រះវិញ្ញាណ។

"ដ្បិតក្រោយដែលយើងបានទទួលស្គាល់សេចក្តីពិតហើយ បើយើងធ្វើបាបស្ម័គ្រពីចិត្តទៀត នោះគ្មានយញ្ញបូជាណាសម្រាប់នឹងលោះបាបទៀតទេ។ មានតែរង់ចាំ ដោយស្ញែងខ្លាចចំពោះសេចក្តីជំនុំជម្រះ និងសេចក្តីសហ័សនៃភ្លើង ដែលរៀបនឹងឆេះដល់អស់ទាំងពួកទាស់ទទឹងផងប៉ុណ្ណោះ។ ឯអ្នកណាដែលក្បត់ក្រឹត្យវិន័យលោកម៉ូសេ នោះបានត្រូវស្លាប់ឥតប្រណី ដោយសេចក្តីបន្ទាល់របស់មនុស្ស២ឬ៣នាក់ ចុះតើអ្នករាល់គ្នាស្មានថាគេគួរមានទោសជាធ្ងន់ជាងយ៉ាងណាទៅ ដែលគេជាន់ឈ្លីព្រះរាជបុត្រានៃព្រះ ទាំងរាប់ព្រះលោហិតនៃសេចក្តីសញ្ញា ដែលបានញែកគេចេញជាបរិសុទ្ធ

**ទុកដូចជារបស់ប្រើធម្មតា ហើយត្មះតិះដៀលដល់ព្រះវិញ្ញាណដ៏មានព្រះគុណផងនោះ” ហេព្រើរ 10:26-29**

ដូច្នេះខ្ញុំបានបាំងខ្លួនខ្ញុំចេញពីគ្រប់ទាំងសេចក្តីសន្យាទាំងអស់ ហើយឥឡូវមិនមានអ្វីដែលសល់សម្រាប់ខ្ញុំឡើយក្រៅពីសេចក្តីគម្រាមកំហែង ដែលគួរភ័យខ្លាច ការព្រមានដែលគួរឱ្យខ្លាចពីសេចក្តីជំនុំជំរះនិងសេចក្តីក្រោធយ៉ាងខ្លាំង ដែលនឹងត្របាក់លេបខ្ញុំដូចជាសត្រូវ។

គ្រីស្ទាន៖ តើអ្នកយកខ្លួនមកដល់សភាពបែបនេះសម្រាប់អ្វីទៅ?

អ្នកបែរថយក្រោយ៖ សម្រាប់តណ្ហា ការសប្បាយ និងផលប្រយោជន៍នៅក្នុងលោកិយនេះ នៅក្នុងការសប្បាយនឹងអ្វីដែលធ្វើឱ្យខ្ញុំមានអំណរយ៉ាងខ្លាំង តែពេលនេះការនីមួយៗទាំងនោះបានខាំខ្ញុំ ទាំងគ្របហឹមដាក់ខ្ញុំដូចជាដង្កូវដែលឆេះអីចឹង។

គ្រីស្ទាន៖ តើពេលនេះអ្នកមិនអាចប្រែចិត្តហើយវិលត្រឡប់វិញទេឬយ៉ាងណា?

អ្នកបែរថយក្រោយ៖ ព្រះបានបដិសេធការប្រែចិត្តរបស់ខ្ញុំហើយ។ ព្រះបន្ទូលរបស់ទ្រង់មិនបានលើកទឹកចិត្តឱ្យបានជឿឡើយ។ ពិតណាស់ ទ្រង់បានឃុំខ្ញុំនៅក្នុងទ្រុងដែកនេះ ក៏គ្មានមនុស្សនៅក្នុងលោកិយណាដែលអាចឱ្យខ្ញុំចេញបានឡើយ។ អូ ភាពអស់កល្បជានិច្ចអើយ! ភាពអស់កល្បអើយ! តើខ្ញុំដោះស្រាយយ៉ាងណាជាមួយនឹងសេចក្តីលំបាកវេទនា ដែលខ្ញុំនឹងត្រូវជួបនៅអស់កល្បជានិច្ចនោះ?

អ្នកបកស្រាយ៖ បន្ទាប់មកអ្នកបកស្រាយបាននិយាយទៅកាន់គ្រីស្ទានថា "សូមអ្នកចាំពីសេចក្តីវេទនារបស់បុរសនេះ ហើយតែងតែប្រយ័ត្នជារហូតទៅ។"

គ្រីស្ទាន៖ គ្រីស្ទាននិយាយថា "ពិតណាស់" "វាគួរឱ្យខ្លាចណាស់! ព្រះបានឱ្យខ្ញុំឃើញហើយបានធូរស្បើយ ហើយអធិស្ឋានថាខ្ញុំនឹងមិនជួបនឹងសេចក្តីវេទនាដូចជាបុរសនេះឡើយ។ លោកម្ចាស់អើយ តើមិនទាន់ដល់ពេលដែលខ្ញុំត្រូវទៅតាមផ្លូវទេឬពេលនេះ?"

អ្នកបកស្រាយ៖ ចាំរហូតដល់ខ្ញុំនឹងបង្ហាញការមួយទៀតដល់អ្នក ហើយបន្ទាប់មកអ្នកនឹងទៅតាមផ្លូវរបស់អ្នកបាន។

ដូច្នេះចាប់ដៃរបស់គ្រីស្ទានម្តងទៀត ហើយនាំគាត់ទៅក្នុងបន្ទប់ ដែលមានមនុស្សម្នាក់កំពុងងើបពីលើគ្រែ ហើយនៅពេលដែលគាត់ពាក់សំលៀកបំពាក់របស់គាត់ គាត់ញ័រញ័រ។ បន្ទាប់មកគ្រីស្ទាននិយាយថា "ហេតុអ្វីបានជាបុរសនោះញ័រញ័របែបនេះ?" អ្នកបកប្រែបានប្រាប់បុរសនោះឱ្យប្រាប់ដល់គ្រីស្ទានពីហេតុផលដែលគាត់ធ្វើបែបនោះ។ ដូច្នេះគាត់ក៏ចាប់ផ្តើមប្រាប់ "យប់នេះ កាលដែលខ្ញុំកំពុងដេក ខ្ញុំសុបិន្តឃើញ មេឃក្លាយទៅជាខ្មៅយ៉ាងខ្លាំង ហើយមានរន្ទះ និងផ្លេកបន្ទោរដែលគួរឱ្យភ័យខ្លាច ដែលវាបានធ្វើឱ្យខ្ញុំមានសេចក្តីវេទនាយ៉ាងខ្លាំង។ ដូច្នេះខ្ញុំបានមើលនៅក្នុងសុបិន្តរបស់ខ្ញុំ ឃើញសសរពពកនៅក្នុងកម្រិតមួយដែលមិនធម្មតា នៅខាងវាមានសម្លេងត្រែយ៉ាងអស្ចារ្យមួយ ហើយបានឃើញបុរសដែលអង្គុយនៅលើពពក មានអ្នកហែរហមរាប់ពាន់ពីស្ថានសួគ៌។ ពួកគេទាំងអស់នៅក្នុងភ្លើងដែលកំពុងឆេះ

ហើយស្ថានសួគ៌កំពុងនៅលើភ្លើងឆេះដែរ។ ហើយខ្ញុំឮសម្លេងមួយនិយាយថា "ចូរក្រោកឡើង ឱមនុស្សស្លាប់អើយ ហើយមកកាន់សេចក្តីជំនុំជំរះ" ហើយថ្មក៏រមៀលចេញ ហើយផ្នូរក៏បើកឡើង ហើយមនុស្សស្លាប់បានចេញមក។"

"កុំឲ្យឆ្ងល់ពីសេចក្តីនេះឡើយ ដ្បិតមានពេលវេលាមក ដែលអស់ទាំងខ្មោចនៅក្នុងផ្នូរនឹងឮសំឡេងទ្រង់ ហើយនិងចេញមក" យ៉ូហាន 5:28

"បើសិនជាបានផ្សាយដំណឹងល្អពីព្រះគ្រីស្ទថា ទ្រង់មានព្រះជន្មរស់ពីស្លាប់ឡើងវិញហើយ នោះធ្វើដូចម្តេចឲ្យពួកអ្នករាល់គ្នាខ្លះ និយាយបាន ថាពួកស្លាប់មិនរស់ឡើងវិញទេ។ បើសិនជាពួកស្លាប់មិនរស់ឡើងវិញមែន នោះព្រះគ្រីស្ទក៏មិនបានរស់ឡើងវិញដែរ។ ហើយបើព្រះគ្រីស្ទមិនបានរស់ឡើងវិញ នោះដំណឹងដែលយើងខ្ញុំផ្សាយនេះ ជាការឥតប្រយោជន៍ទទេ ហើយសេចក្តីជំនឿរបស់អ្នករាល់គ្នា ក៏ឥតអំពើដែរ។ ឈ្មោះថាយើងខ្ញុំជាស្មរបន្ទាល់ក្លែងក្លាយពីព្រះវិញ ដ្បិតយើងខ្ញុំបានធ្វើបន្ទាល់ពីព្រះថា ទ្រង់បានប្រោសឲ្យព្រះគ្រីស្ទរស់ឡើងវិញហើយ តែបើពួកស្លាប់មិនរស់ឡើងវិញមែន នោះប្រាកដជាទ្រង់មិនបានប្រោសឲ្យព្រះគ្រីស្ទរស់ឡើងវិញពិត។ ដ្បិតបើសិនជាពួកស្លាប់មិនរស់ឡើងទេ នោះព្រះគ្រីស្ទក៏មិនបានរស់ឡើងដែរ។ ហើយបើព្រះគ្រីស្ទមិនបានរស់ឡើងវិញមែន នោះសេចក្តីជំនឿរបស់អ្នករាល់គ្នាក៏ជាការឥតអំពើ អ្នករាល់គ្នានៅក្នុងអំពើបាបនៅឡើយ។ ហើយអស់អ្នកដែលបានដេកលក់ទៅក្នុងព្រះគ្រីស្ទ គេបានត្រូវវិនាសហើយ។ បើសិនជាយើងមានទីសង្ឃឹមក្នុងព្រះគ្រីស្ទ នៅតែក្នុងជីវិតនេះប៉ុណ្ណោះ នោះយើងវេទនា លើសជាងមនុស្សទាំងអស់ទៅទៀត។" កូរិនថូស ទី១ 15:12-19

“ដ្បិតព្រះបន្ទូលនៃព្រះអម្ចាស់បានផ្សាយចេញពីអ្នករាល់គ្នា មិនមែនតែក្នុងស្រុកម៉ាសេដូន និងស្រុកអាខៃប៉ុណ្ណោះទេ គឺរហូតដល់គ្រប់ទាំងកន្លែង ដែលឮនិយាយពីសេចក្ដីជំនឿរបស់អ្នករាល់គ្នាចំពោះព្រះថែមទៀតផង បានជាមិនចាំបាច់ឲ្យយើងខ្ញុំនិយាយអ្វីទៀតទេ” **ថែស្សាឡូនិច ទី១ 1:8**

“ដើម្បីនឹងកាត់ទោសដល់គ្រប់មនុស្សទាំងឡាយ ហើយនិងរំឭកពួកទមិឡល្មើសទាំងអម្បាលម៉ាន ឲ្យដឹងខ្លួនពីគ្រប់ទាំងការទមិឡល្មើស ដែលគេបានប្រព្រឹត្តធ្វើ ដោយចិត្តល្មើស ហើយពីអស់ទាំងសេចក្ដីរឹងទទឹងទាំងប៉ុន្មាន ដែលអស់ពួកទមិឡល្មើសដ៏មានបាបទាំងនោះ បានពោលទាស់នឹងទ្រង់” **យូដាស 15**

“ខ្ញុំក៏ឃើញបល្ល័ង្កស១យ៉ាងធំ និងព្រះអង្គដែលគង់លើ ឯផែនដី និងផ្ទៃមេឃក៏រត់ពីចំពោះទ្រង់ចេញ ឥតឃើញមានកន្លែងណាឲ្យនៅទៀតឡើយ។ នោះខ្ញុំឃើញមនុស្សស្លាប់ ទាំងអ្នកធំ ទាំងអ្នកតូច គេឈរនៅចំពោះព្រះ បញ្ជីក៏បានបើកឡើង ហើយបញ្ជី១ទៀត គឺជាបញ្ជីជីវិតបានបើកឡើងដែរ រួចមនុស្សស្លាប់ទាំងអស់ត្រូវជំនុំជម្រះ ពីសេចក្ដីដែលកត់ទុកក្នុងបញ្ជីទាំងនោះ តាមអំពើដែលគេបានប្រព្រឹត្តរៀងខ្លួន។ ឯសមុទ្រ នោះបានប្រគល់ពួកមនុស្សស្លាប់ ដែលនៅក្នុងទឹកមកវិញ ហើយសេចក្ដីស្លាប់ និងស្ថានឃុំព្រលឹងមនុស្សស្លាប់ ក៏ប្រគល់ពួកមនុស្សស្លាប់ ដែលនៅឯណោះមកវិញដែរ រួចគេត្រូវជំនុំជម្រះ តាមអំពើដែលគេបានប្រព្រឹត្តរៀងខ្លួន។ ចំណែកសេចក្ដីស្លាប់ និងស្ថានឃុំព្រលឹងមនុស្សស្លាប់ នោះត្រូវបោះទៅក្នុងបឹងភ្លើងដែរ នេះជាសេចក្ដីស្លាប់ទី២” **វិវរណៈ 20:11-14**

មួយចំនួននៅក្នុងពួកគេមានសេចក្តីអំណរខ្លាំងណាស់ ហើយបានមើលទៅលើ។ ហើយអ្នកខ្លះទៀតបានពួននៅខាងក្រោមភ្នំ។ បន្ទាប់មកខ្ញុំបានឃើញបុរសដែលបានអង្គុយនៅលើពពកបើកសៀវភៅ ហើយប្រាប់លោកិយឱ្យខិតមកជិត។

"ព្រះ គឺជាព្រះដ៏មានឥទ្ធិឫទ្ធិ ព្រះនាមជាព្រះយេហូវ៉ា ទ្រង់បានមានព្រះបន្ទូលហើយ ទ្រង់បានកោះហៅទាំងអស់ដែលនៅលើផែនដី ចាប់តាំងពីទិសខាងថ្ងៃរះទៅដល់ទិសថ្ងៃលិច។ ព្រះទ្រង់បានភ្លឺមកពីក្រុងស៊ីយ៉ូន ដែលជាទីក្រុងមានលំអដ៏គ្រប់លក្ខណ៍។ ព្រះនៃយើងខ្ញុំទ្រង់យាងមក ហើយមិននៅស្ងៀមទេ មានភ្លើងឆេះនៅចំពោះទ្រង់ ហើយនៅព័ទ្ធជុំវិញទ្រង់មានព្យុះសង្ឃរា" ទំនុកដំកើង 50:1-3

"ដ្បិតមើល ព្រះយេហូវ៉ាទ្រង់យាងចេញពីស្ថានរបស់ទ្រង់មក ដើម្បីនឹងសម្រេចទោសដល់មនុស្សនៅផែនដី ដោយព្រោះអំពើទុច្ចរិតរបស់គេ ឯដីនឹងបើកបង្ហាញឈាមគេឲ្យឃើញ ឥតគ្របបាំងមនុស្សដែលត្រូវគេសម្លាប់ទៀតឡើយ។" អេសាយ 26:21

"អស់ទាំងសាសន៍នឹងឃើញ ហើយនិងឡើងមុខស្លាំង ដោយព្រោះឥទ្ធិឫទ្ធិរបស់គេ ពួកទាំងនោះនឹងដាក់ដៃខ្ទប់មាត់ ហើយត្រចៀកគេនឹងត្រូវថ្លង់ទៅដែរ។ គេនឹងលិទ្ធធូលីដីដូចជាពស់ គេនឹងញាប់ញ័រចេញពីទីមាំមួនរបស់គេ គឺដូចជាសត្វលូនវារនៅផែនដីចេញពីរន្ធ គេនឹងមកឯព្រះយេហូវ៉ាជាព្រះនៃយើង ដោយកោតខ្លាច ហើយនិងភិតភ័យដោយព្រោះឯង។" មីកា 7:16, 17

ដោយមានអណ្ដាតភ្លើងខ្លាំងដែលចេញមកនៅចំពោះទ្រង់ ដែលនៅចន្លោះ ល្មងរវាងទ្រង់នឹងពួកគេ ដូចជាចន្លោះរវាងចៅក្រមនិងអ្នកទោសនៅក្នុងគុក។

"ខ្ញុំក៏គន់មើល ទាល់តែមានគេយកបល្ល័ង្កមកតាំង ហើយព្រះដ៏មានព្រះជន្មពីចាស់បុរាណ ទ្រង់ក៏គង់លើ ព្រះពស្ត្រទ្រង់សស្គុសដូចហិមៈ ហើយព្រះកេសនៅព្រះសិរទ្រង់ ក៏សដូចរោមចៀមយ៉ាងស្អាត ឯបល្ល័ង្កទ្រង់ នោះសុទ្ធតែជាអណ្ដាតភ្លើង ហើយកង់នៃបល្ល័ង្កនោះ ក៏ជាភ្លើងឆេះដែរ។ មានដូចជាភ្លើងហូរចេញពីចំពោះទ្រង់មក មានទាំងពាន់ទាំងពាន់ដែលគោរពដល់ទ្រង់ ហើយទាំង ម៉ឺនទាំងសែនក៏ឈរនៅចំពោះទ្រង់ នោះការវិនិច្ឆ័យបានរៀបចំជាស្រេច ឯបញ្ជីទាំងប៉ុន្មានបានបើកឡើងហើយ" ដានីយ៉ែល 7:9-10

"តែមានអ្នកឯណាធន់នៅបាន ក្នុងកាលដែលទ្រង់យាងមកនោះ តើអ្នកណានឹងឈរនៅ ក្នុងកាលដែលទ្រង់លេចមក ដ្បិតទ្រង់ប្រៀបដូចជាភ្លើងរបស់ជាងសំរង ហើយដូចជាក្បុងរបស់ជាងប្រមោក។ ទ្រង់នឹងគង់ចុះ ដូចជាជាងសំរង ហើយនិងដេញអាចម៍ប្រាក់ ទ្រង់នឹងសម្អាតពួកកូនចៅលេវី ហើយសំរងគេដូចជាមាស ហើយនិងប្រាក់ នោះគេនឹងថ្វាយតង្វាយដល់ព្រះយេហូវ៉ា ដោយសេចក្ដីសុចរិត" ម៉ាឡាគី 3:2, 3

ខ្ញុំបានឮប្រកាសទៅកាន់ពួកគេដែលមកកាន់បុរសដែលអង្គុយនៅលើពពកថា "ចូរប្រមូលអង្កាម និងចំបើងមក ហើយទម្លាក់ពួកគេទោក្នុងបឹងភ្លើងទៅ។"

“ទ្រង់កាន់ចង្អេរនៅព្រះហស្ត ទ្រង់នឹងបោសរំលីងទីលានទ្រង់ ហើយនិងប្រមូលស្រូវទ្រង់ មកដាក់ក្នុងជង្រុក តែអង្កាម ទ្រង់នឹងដុតក្នុងភ្លើងដែលពន្លត់មិនបានវិញ។” **ម៉ាថាយ 3:12**

“ទុកឲ្យវាដុះជាមួយគ្នា ដរាបដល់ពេលច្រូតចុះ ចាំដល់រដូវចម្រូត នោះអញនឹងប្រាប់ពួកចម្រូតថា ចូរច្រូតស្រងែសិន ហើយចងជាកណ្តាប់ ទុកសម្រាប់ដុត ឯស្រូវសាលី ឲ្យប្រមូលដាក់ក្នុងជង្រុកអញវិញ។” **ម៉ាថាយ 13:30**

“ដ្បិតមើល ថ្ងៃនោះកំពុងតែមកដល់ ថ្ងៃនោះឆេះឆ្អៅ ដូចជាគុកភ្លើង នោះអស់ពួកអ្នកឆ្មើងឆ្មៃ ហើយនិងអស់ពួកអ្នកដែលប្រព្រឹត្តអំពើអាក្រក់ គេនឹងដូចជាជញ្ជ្រាំង ហើយថ្ងៃដែលត្រូវមកដល់នោះ នឹងឆេះបន្សុសគេទាំងអស់ទៅ ឥតទុកឲ្យគេមានឫស ឬមែកនៅសល់ឡើយ នេះហើយ ជាព្រះបន្ទូលរបស់ព្រះយេហូវ៉ានៃពួកពលបរិវារ” **ម៉ាឡាគី 4:1**

ហើយជង្ហុកដែលគ្មានបាតនោះក៏បានបើកឡើងក្បែរកន្លែងដែលខ្ញុំឈរ នៅមាត់ជង្ហុកនោះមានចេញមក ដូចជា ផ្សែង ធ្យូងថ្មជាភ្លើង ជាមួយនឹងសម្លេងដ៏គួរឪ្យខ្លាច។ ក៏បាននិយាយទៅកាន់មនុស្សដដែលនោះថា “ចូរប្រមូលស្រូវសាឡីរបស់អញដាក់ទៅក្នុងជង្រុកនោះទៅ។”

“ទ្រង់កាន់ចង្អេរនៅព្រះហស្ត ទ្រង់នឹងបោសរំលីងទីលានទ្រង់ ហើយនិងប្រមូលស្រូវមកដាក់ក្នុងជង្រុកទ្រង់ តែអង្កាម ទ្រង់នឹងដុតក្នុងភ្លើងដែលពន្លត់មិនបាន” **លូកា 3:17**

ដោយឮដូច្នោះ នោះខ្ញុំបានឃើញមនុស្សជាច្រើនត្រូវបានលើកឡើងទៅក្នុងពពក។

"ព្រោះព្រះអម្ចាស់ទ្រង់នឹងយាងចុះពីស្ថានសួគ៌មក ដោយស្រែកបង្គាប់១ព្រះឱស្ឋ ទាំងមានឮសំឡេងមហាទេវតា និងត្រែរបស់ព្រះផង នោះពួកស្លាប់ក្នុងព្រះគ្រីស្ទនឹងរស់ឡើងវិញជាមុនបង្អស់។ រួចយើងរាល់គ្នាដែលកំពុងតែរស់នៅ ក៏នឹងបានលើកឡើង ទៅក្នុងពពកជាមួយគ្នាទាំងអស់ ដើម្បីឲ្យបានជួបជុំនឹងព្រះអម្ចាស់នៅនាអាកាស យ៉ាងនោះ យើងនឹងនៅជាមួយនឹងព្រះអម្ចាស់ជាដរាបទៅ" **ថែស្សាឡូនិច ទី១ 4:16, 17**

តែខ្ញុំត្រូវទុកឱ្យនៅវិញ។ ខ្ញុំក៏បានរកនឹងលាក់ខ្លួន តែខ្ញុំមិនអាចពួនបានឡើយ ដោយបុរសដែលអង្គុយនៅលើពពកនៅតែដាក់ភ្នែករបស់ទ្រង់សម្លឹងមកខ្ញុំ។ អំពើបាបរបស់ខ្ញុំបានចូលមកក្នុងគំនិតរបស់ខ្ញុំ ហើយសតិបញ្ញារបស់ខ្ញុំបានចោទប្រកាន់ខ្ញុំគ្រប់ជ្រុង។

"ពីព្រោះកាលណាពួកសាសន៍ដទៃ ដែលគ្មានក្រឹត្យវិន័យ គេបានប្រព្រឹត្តតាមក្រឹត្យវិន័យពីបវេណី នោះពួកដែលគ្មានក្រឹត្យវិន័យនោះឯង គេជាក្រឹត្យវិន័យដល់ខ្លួនគេវិញ។ ដោយសម្តែងថា របៀបក្រឹត្យវិន័យបានកត់ទុកក្នុងចិត្តគេហើយ បញ្ញាចិត្តគេក៏ធ្វើបន្ទាល់ឲ្យ ហើយគំនិតគេជួនកាលប្រកាន់ទោស ជួនកាលដោះសាគ្នាទៅវិញទៅមក)" **រ៉ូម 2:14, 15**

ដោយហេតុនោះខ្ញុំក៏បានភ្ញាក់ពីដេកទៅ។"

គ្រីស្ទាន៖ ប៉ុន្តែតើអ្វីទៅដែលធ្វើឱ្យអ្នកភ័យខ្លាចនឹងរូបភាពនោះខ្លាំងម្ល៉េះ?

មិនទាន់រួចរាល់៖ ហេតុនោះគឺ ខ្ញុំបានគិតថាថ្ងៃនៃការជំនុំជំរះត្រូវបានមកដល់ ហើយថាខ្ញុំមិនទាន់រួចរាល់នូវឡើយ។ ប៉ុន្តែវាបានបន្លាចខ្ញុំយ៉ាងខ្លាំង ដែលពួកទេវតាបានប្រមូលគ្នាមួយចំនួន ហើយបានចាកចោលខ្ញុំទៅ ហើយជង្ហុកនៃស្ថាននរកបានបើកមាត់របស់វានៅត្រង់កន្លែងដែលខ្ញុំឈរ។ សតិរបស់ខ្ញុំផង បានធ្វើទុកដល់ខ្ញុំ ហើយកាលដែលខ្ញុំគិត ចៅក្រមតែងតែចោលភ្នែកមកលើខ្ញុំ ដែលបង្ហាញពីទឹកមុខពេញដោយកំហឹងរបស់ទ្រង់។

បន្ទាប់មកអ្នកបកប្រែបាននិយាយទៅកាន់គ្រីស្ទានថា "តើអ្នកដែលគិតពិចារណាពីការទាំងនេះដែរទេ?"

គ្រីស្ទាន៖ បាទបាន ការនេះធ្វើឱ្យខ្ញុំមានសង្ឃឹមនិងសេចក្តីភ័យខ្លាចផង។

អ្នកបកស្រាយ៖ អីចឹង ចូររក្សាការទាំងនេះនៅក្នុងគំនិតរបស់អ្នកទៅ នោះនឹងបានធ្វើជាកន្លួសនៅក្បែរអ្នក ដើម្បីនឹងទាញអ្នកទៅមុខត្រង់តាមផ្លូវដែលអ្នកត្រូវទៅ។ បន្ទាប់មកគ្រីស្ទានចាប់ផ្តើមមូរដៃអាវរបស់គាត់ ដើម្បីរៀបចំខ្លួនធ្វើដំណើរទៅ។ អ្នកបកស្រាយបាននិយាយថា "អ្នកកំសាន្តចិត្តនឹងនៅជាមួយអ្នកជានិច្ច អ្នកគ្រីស្ទានល្អអើយ គេនឹងដឹកនាំអ្នកតាមផ្លូវទៅកាន់ទីក្រុងនោះ។"

ដូច្នេះគ្រីស្ទានបានទៅតាមរបស់គាត់ និយាយថា

"នៅទីនេះ ខ្ញុំបានឃើញការដែលកម្រនិងមានប្រយោជន៍ ការដែលអរសប្បាយ ការដែលគួរឱ្យភ័យខ្លាច ដែលធ្វើឱ្យខ្ញុំនៅនឹងនរក្នុងការអ្វីដែលខ្ញុំបានចាប់ផ្តើមចាប់មកក្នុងដៃ។ អីចឹងចូរឱ្យខ្ញុំគិតពីការទាំងនោះ ហើយយល់

ពីអ្វីដែលគេបានបង្ហាញដល់ខ្ញុំផង។ ហើយសូមឱ្យខ្ញុំចេះដឹងគុណផង ឱអ្នកបកស្រាយល្អអើយ!”

# ឈើឆ្កាង

ឥឡូវខ្ញុំបានឃើញនៅក្នុងសុបិន្តរបស់ខ្ញុំថា ផ្លូវធំដែលគ្រីស្ទានកំពុងដើរទៅត្រូវបានដាក់របងដោយជញ្ជាំងទាំងសងខាង ហើយរបងនោះត្រូវបានហៅថា "សេចក្តីសង្គ្រោះ។"

"នៅគ្រានោះគេនឹងច្រៀងបទនេះ នៅក្នុងស្រុកយូដា យើងមានទីក្រុងមួយដ៏មាំមួន ទ្រង់នឹងតម្រូវឱ្យមានសេចក្តីសង្គ្រោះ ទុកជាកំផែង ហើយជាទីការពារយើង។" អេសាយ 26:1

ដូច្នេះគ្រីស្ទានបានរត់តាមផ្លូវនោះដោយមានបន្ទុក ហើយការលំបាកយ៉ាងខ្លាំងដោយសារបន្ទុកនៅលើខ្នងរបស់គាត់។

គាត់បានរត់រហូតដល់គាត់បានមកដល់កន្លែងមួយដែលឡើងទៅលើ ហើយនៅលើនោះមានឈើឆ្កាងបញ្ឈរនៅទីនោះ ហើយនៅទាបបន្តិច នៅបាតមានផ្នូរមួយ។ ដូច្នេះខ្ញុំបានឃើញនៅក្នុងសុបិន្តរបស់ខ្ញុំថា គ្រាន់តែគ្រីស្ទានបានទៅដល់ឈើឆ្កាង បន្ទុករបស់គាត់បានរលាចេញពីស្មារបស់គាត់ ហើយធ្លាក់ចេញពីខ្នងរបស់គាត់ ហើយចាប់ផ្តើមដួលចុះ។ ហើយនៅតែធ្វើដូច្នេះរហូតទៅដល់មាត់ផ្នូរ នោះវាក៏បានធ្លាក់ចូលទៅខាងក្នុង ហើយខ្ញុំក៏លែងឃើញវាទៀតទៅ។

បន្ទាប់មកគ្រីស្ទានបានរីករាយ ហើយបានធូរស្រាល ក៏និយាយដោយចិត្តសប្បាយថា

"ទ្រង់បានប្រទានសេចក្តីសម្រាកដល់ខ្ញុំដោយសារសេចក្តីទុក្ខសោករបស់ទ្រង់ ហើយផ្តល់ជីវិតមកដោយសារការសុគតរបស់ទ្រង់។

បន្ទាប់មកគាត់បានឈរស្ងៀមមួយរយៈដើម្បីនឹងមើលនិងគិត ដោយសារវាគួរឱ្យភ្ញាក់ផ្អើលណាស់ដល់គាត់ ដែលរូបភាពនៃឈើឆ្កាងបានសម្រាលដល់បន្ទុករបស់គាត់។ ដូច្នេះគាត់បានសម្លឹងមើល ហើយមើលទៀត រហូតទាល់តែមានប្រភពទឹកដែលចេញពីក្បាលរបស់គាត់ហូរចុះរហូតដល់ថ្ពាល់របស់គាត់។

**"អញនឹងចាក់និស្ស័យមកលើពួកវង្សដាវីឌ និងពួកអ្នកនៅក្រុងយេរូសាឡិម ឱ្យគេមានចិត្តប្រកបដោយគុណ និងសេចក្តីទូលអង្វរ នោះគេនឹងគន់មើលអ្នកដែលគេបានចាក់ ហើយគេនឹងយំសោកនឹងអ្នកនោះ ដូចជាយំសោកនឹងកូនខ្លួនតែមួយ គេនឹងយំខ្សឹកខ្សួលនឹងអ្នកនោះ ដូចជាយំនឹងកូនច្បងរបស់ខ្លួន។" សាការី 12:10**

ពេលនេះ ពេលគាត់ឈរមើលហើយយំ មើលមនុស្សចែងចាំងបីនាក់បានមកកាន់គាត់ ហើយរាក់ទាក់គាត់ថា "សូមឱ្យសេចក្តីសុខសាន្តនៅជាមួយអ្នក!" អ្នកទីមួយក៏និយាយទៅគាត់ថា "អំពើបាបរបស់អ្នកត្រូវបានអត់ទោសឱ្យអ្នកហើយ។"

**"ព្រះយេស៊ូវក៏ឃើញសេចក្តីជំនឿរបស់អ្នកទាំងនោះ ហើយទ្រង់ក៏មានបន្ទូលទៅអ្នកស្លាប់ដៃស្លាប់ជើងថា កូនអើយ បាបរបស់ឯងបានអត់ទោសឱ្យឯងហើយ។" ម៉ាកុស 2:5**

អ្នកទីពីរបានសម្រាតកន្ទបរបស់គាត់ចេញ ហើយបំពាក់គាត់ដោយសំលៀក បំពាក់ផ្សេង

**"ទ្រង់ក៏បង្គាប់ដល់ពួកដែលឈរនៅចំពោះទ្រង់ថា ចូរដោះសំលៀកបំពាក់កខ្វក់ពីលោកចេញ រួចទ្រង់មានបន្ទូលដល់លោកថា មើលអញបានលើកចោលអំពើទុច្ចរិតពីឯងចេញហើយ អញនឹងប្រដាប់ខ្លួនឯងដោយសំលៀកបំពាក់ដ៏រុងរឿងវិញ។" សាការី 3:4**

អ្នកទីបីក៏បានដាក់សញ្ញានៅលើថ្ងាស់របស់គាត់ ហើយបានឱ្យផ្ទាំងមូរមួយដែលមានត្រានៅលើវា

**"ឯអ្នករាល់គ្នាក៏បានឮព្រះបន្ទូលនៃសេចក្តីពិត គឺជាដំណឹងល្អពីសេចក្តីសង្គ្រោះរបស់អ្នករាល់គ្នាដោយសារទ្រង់ដែរ នោះទ្រង់ក៏ដៅចំណាំដោយព្រះវិញ្ញាណបរិសុទ្ធដែលបានសន្យា។" អេភេសូ 1:3**

ដែលគាត់បានប្រាប់គាត់ឱ្យមើលទៅមុខពេលដែលគាត់រត់ទៅ ហើយថាគាត់គួរតែលះបង់ខ្លួននៅឃ្លោងទ្វារស្ថានសួគ៌។ ដូច្នេះពួកគេបានទៅតាមផ្លូវរបស់ពួកគេ។ រួចមកគ្រីស្ទានបានលោតដោយអំណរបីដង ហើយដើរទៅទាំងច្រៀងបណ្តើរផង។

"តាំងពីខ្ញុំចេញមក ខ្ញុំបានមកជាមួយនឹងអំពើបាបរបស់ខ្ញុំ ហើយក៏មិនអាចនឹងសម្រាលដល់សេចក្តីព្រួយដែលខ្ញុំមានដែរ រហូតទាល់តែខ្ញុំបានមកដល់ទីនេះ។ តើនេះជាកន្លែងដ៏អស្ចារ្យយ៉ាងហ្ន៎! នេះគួរតែជាការចាប់ផ្តើមនៃសេចក្តីអំណររបស់ខ្ញុំ! ទីនេះជាទីដែលបន្ទុកត្រូវធ្លាក់ចេញពីខ្នងរបស់ខ្ញុំ! ទីនេះជា

ខ្សែរដែលចងការបាក់បែករបស់ខ្ញុំ! សូមថ្វាយព្រះពរដល់ឈើឆ្កាង! សូមសរសើរដល់ផ្នូរ! សូមថ្វាយពរដល់មនុស្សម្នាក់ដែលនៅទីនោះ ដែលត្រូវអាម៉ាស់ជំនួសខ្ញុំ!"

## មនុស្សល្ងង់ មនុស្សខ្ជិល និងមនុស្សសន្មត់

ខ្ញុំបានឃើញនៅក្នុងសុបិន្តរបស់ខ្ញុំ ថាគាត់បានដើរទៅរហូតដល់បាត ជាកន្លែងដែលគាត់បានឃើញ ដូចជារាងចេញពីផ្លូវបន្តិច មានមនុស្សបីនាក់បានឆាប់ដេកលក់ មានច្រវ៉ាក់នៅជាប់កែងជើងរបស់ពួកគេ។ ម្នាក់ឈ្មោះលោកល្ងង់ ម្នាក់ទៀតឈ្មោះកំជិល និងម្នាក់ទៀត លោកសម្មត់។

កាលដែលគ្រីស្ទានឃើញពួកគេដេកបែបនេះ ក៏ទៅរកពួកគេ ប្រហែលជាគាត់អាចនឹងដាស់ពួកគេឱ្យភ្ញាក់ ហើយក៏ស្រែកថា "អ្នកដូចជាពួកគេដែលដេកនៅលើសសរមួយអីចឹង ដោយសារសមុទ្រក្រហមនៅខាងក្រោមអ្នកជាជង្ហុកដែលគ្មានបាត។"

**"អើ ឯងនឹងបានដូចជាមនុស្សដែលដេកនៅកណ្ដាលសមុទ្រ ឬដូចជាមនុស្សដែលដេកនៅលើចុងដងក្ដោង។" សុភាសិត 23:34**

ចូរភ្ញាក់ឡើងហើយចេញមក ហើយឱ្យបានស្ម័គ្រចិត្តផង នោះខ្ញុំនឹងជួយអ្នកឱ្យរួចពីដែករបស់អ្នក។ គាត់ក៏បានប្រាប់ដល់ពួកគេថា "ប្រសិនបើម្នាក់ដែលដើរក្រវែលទាំងគ្រហឹមដូចសត្វសិង្ហមកក្បែរ នោះអ្នកនឹងក្លាយទៅជាចំណីដល់ធ្មេញរបស់វាមិនខាន។"

**"ចូរឱ្យដឹងខ្លួន ហើយចាំយាមចុះ ព្រោះអារក្ស ដែលជាខ្មាំងសត្រូវរបស់អ្នករាល់គ្នា វាតែងដើរក្រវែល ទាំងគ្រហឹមដូចជាសិង្ហ ដើម្បីនឹងរកអ្នកណាដែលវានឹងត្របាក់លេបបាន។" ពេត្រុស ទី១ 5:8**

នោះពួកគេបានសម្លឹងមកមើលគាត់ ហើយបានឆ្លើយបែបនេះ

មនុស្សល្ងង់បាននិយាយថា "ខ្ញុំមើលមិនឃើញគ្រោះថ្នាក់សោះ។"

មនុស្សកំជិលនិយាយថា "មិនទាន់នៅឡើយ ដេកបន្តិចទៀតសិន។"

និង មនុស្សដែលសន្មត់បាននិយាយថា "ធុងទឹកនីមួយៗត្រូវតែឈរនៅលើបាតរបស់វា។"

ហើយពួកគេក៏ផ្តេកខ្លួនដេកម្តងទៀតទៅ ហើយគ្រីស្ទានក៏ទៅតាមផ្លូវរបស់គាត់ទៅ។

## អ្នកផ្លូវការ និង សេចក្ដីកំពុត

តែគាត់មានការលំបាកដែលគិតថា មនុស្សដែលមានគ្រោះថ្នាក់គួរតែឱ្យតម្លៃដល់អ្នកដែលផ្ដល់ជំនួយដល់គាត់ដោយឥតគិតថ្លៃ ទាំងដាល់ពួកគេឱ្យភ្ញាក់ និងផ្ដល់ការព្រឹក្សាដល់ពួកគេ ហើយបានជួយយកដែករបស់គេចេញថែមទៀត។ ហើយនៅពេលដែលគាត់កំពុងតែពិបាកដោយការនោះ គាត់បានឃើញបុរសពីរនាក់ដែលបានមក បានដួលទៅលើជញ្ជាំង នៅខាងស្ដាំដៃនៃផ្លូវចង្អៀតនោះ ហើយពួកគេបានផ្សះផ្សាជាមួយគាត់យ៉ាងរហ័ស។ មានម្នាក់ឈ្មោះអ្នកផ្លូវការ ហើយម្នាក់ទៀតឈ្មោះថា សេចក្ដីកំពុត។ ដូច្នេះ ក្នុងកាលដែលខ្ញុំបាននិយាយនោះ ពួកគេបានខិតមកជិតគាត់ ជាអ្នកដែលបានចូលជជែកជាមួយនឹងពួកគេ។

គ្រីស្ទាន៖ សុភាពបុរសទាំងពីរអើយ តើអ្នកមកពីពេលណា ហើយតើអ្នកទៅណា?

អ្នកផ្លូវការ និង សេចក្ដីកំពុត៖ យើងបានកើតនៅក្នុងទឹកដែលនៃ សិរិល្អដែលឥតប្រយោជន៍ ហើយកំពុងទៅរកសេចក្ដីកោតសរសើរនៅភ្នំស៊ីយ៉ូន។

គ្រីស្ទាន៖ ហេតុអ្វីបានជាអ្នកមិនមកតាមឃ្លោងទ្វារដែលឈរនៅដើមផ្លូវ? តើអ្នកមិនបានដឹងការដែលបានសរសេរមកថា "អ្នកដែលមិនចូលតាមទ្វារទេ តែឡើងតាមផ្លូវណាផ្សេងទៀត នោះប្រៀបដូចជាចោរលួចចោរប្លន់ដែរ"?

**"ប្រាកដមែន ខ្ញុំប្រាប់អ្នករាល់គ្នាជាប្រាកដថា អ្នកណាដែលចូលទៅក្នុងក្រោលចៀម មិនមែនតាមទ្វារ គឺឡើងចូលតាមកន្លែងណាឯទៀតវិញ អ្នកនោះឈ្មោះថាជាចោរលួច ចោរប្លន់ហើយ" យ៉ូហាន 10:1**

អ្នកផ្លូវការ និង សេចក្តីកំពុត៖ ពួកគេនិយាយថា ការដែលទៅកាន់ឃ្លោងទ្វារនៃច្រកចូលនោះ មនុស្សនានាតែងតែគិតថាវាឆ្ងាយពេក ហើយដូច្នេះផ្លូវទូទៅដែលវាខ្លីជាងនោះ គឺជាការឡើងតាមជញ្ជាំងដូចដែលពួកគេបានធ្វើនោះឯង។

គ្រីស្ទាន៖ ប៉ុន្តែតើនេះមិនបានរាប់ថាជាការរំលងទាស់នឹងព្រះអម្ចាស់នៃទីក្រុងទេឬ ដែលយើងធ្វើខុសនឹងបំណងព្រះហឫទ័យរបស់ទ្រង់ដែលបង្ហាញមកនោះ?

អ្នកផ្លូវការ និង សេចក្តីកំពុត៖ ពួកគេបានប្រាប់គាត់ថាសម្រាប់ការនោះវិញ ទ្រង់មិនចាំបាច់នឹងរំខាងនឹងគិតពីការនោះទេ ដោយសារការដែលពួកគេបានធ្វើនោះជាទំលាប់ទៅហើយ ហើយអាចបង្កើត ប្រសិនបើត្រូវការទីបន្ទាល់ដែលអាចនឹងធ្វើបន្ទាល់ពីវា នោះមានច្រើនជាងមួយពាន់ឆ្នាំទៅទៀត។

គ្រីស្ទាន៖ "ប៉ុន្តែ" គ្រីស្ទានបាននិយាយថា "តើការអនុវត្តរបស់អ្នកនឹងអាចឈរបាននៅចំពោះច្បាប់បានទេ?"

អ្នកផ្លូវការ និង សេចក្ដីកំពុត៖ ពួកគេបានប្រាប់គាត់ថា វាបានឈរដូចនេះលើសពីមួយពាន់ឆ្នាំទៅទៀត ទម្រាំមកដល់ពេលនេះនោះវានឹងត្រូវបានទទួលស្គាល់តាមច្បាប់ដោយចៅក្រមដែលមិនចេះលំអៀងរួចទៅហើយ។ ហើយក្រៅពីនោះ ពួកគេបាននិយាយថា ដូច្នេះយើងបានដើរតាមផ្លូវនេះ តើវាជាបញ្ហាអ្វីដែរ ដែលយើងចូលមកតាមផ្លូវមួយណានោះ? ប្រសិនបើយើងបានចូលខាងក្នុង នោះគឺនៅខាងក្នុងហើយ អ្នកកំពុងតែនៅលើផ្លូវហើយ ដែលយើងគិតថាអ្នកជាអ្នកដែលចូលតាមឃ្លោងទ្វារ ចំណែកពួកយើងក៏កំពុងតែនៅលើផ្លូវដែរ ដែលមកដោយធ្លាក់ពីលើជញ្ជាំងមក។ តើស្ថានភាពត្រង់ណារបស់អ្នកដែលប្រសើរជាងពួកយើងនោះ?

គ្រីស្ទាន៖ ខ្ញុំបានដើរតាមក្រិត្យក្រមរបស់ម្ចាស់របស់ខ្ញុំ ឯអ្នកដើរតាមកិច្ចការដែលឈ្លើយនៃការគិតរបស់អ្នក។ អ្នកត្រូវបានព្រះអម្ចាស់នៃផ្លូវនេះរាប់ថាជាចោររួចទៅហើយ ដូច្នេះខ្ញុំគិតជាសង្ស័យណាស់ថាអ្នកនឹងមិនត្រូវបានរកឃើញថាជាមនុស្សពិតនៅពេលដល់ទីបំផុតនៃផ្លូវនេះ។ អ្នកចូលមកដោយខ្លួនអ្នកដោយមិនមានការប្រាប់ផ្លូវពីទ្រង់ ហើយអ្នកនឹងទៅដោយខ្លួនអ្នកដោយមិនមានសេចក្ដីមេត្តារបស់ទ្រង់ដែរ។

ដោយការនេះពួកគេមិនបានឆ្លើយអ្វីច្រើនទេ តែពួកគេបានប្រាប់គាត់ឱ្យមើលខ្លួនឯងទៅ។ បន្ទាប់មកខ្ញុំឃើញថាម្នាក់ៗក៏ទៅតាមផ្លូវរបស់ខ្លួនទៅដោយមិនបាននិយាយជាមួយគ្នាទៅវិញទៅមកឡើយ ចូររក្សានូវការដែលអ្នកទាំងពីរបានប្រាប់ដល់គ្រីស្ទាន ដែលសម្រាប់ក្រឹត្យវិន័យនិងពិធីផ្សេងៗ ពួកគេមិនបានសង្ស័យអ្វីឡើយ ក្នុងកាលដែលពួកគេធ្វើការនោះដោយដឹងខ្លួនដូចជាគាត់ដែរ។ "ដូច្នេះ" ពួកគេបាននិយាយថា "យើងមិនបានឃើញថា

អ្នកបានលាក់សេចក្តីអាម៉ាស់និងសេចក្តីអាក្រាតរបស់អ្នកជាមួយនឹងអ្នកជិតខាងរបស់អ្នកឡើយ។”

គ្រីស្ទានៈ ដោយក្រឹត្យវិន័យ និងពិធីផ្សេងៗ អ្នកនឹងមិនត្រូវបានសង្គ្រោះឡើយ ក្នុងកាលដែលអ្នកមិនបានចូលមកតាមទ្វារទេ។

**“យើងដឹងថា មនុស្សមិនបានរាប់ជាសុចរិត ដោយប្រព្រឹត្តតាមក្រឹត្យវិន័យនោះឡើយ គឺដោយសេចក្តីជំនឿ ជឿដល់ព្រះយេស៊ូវគ្រីស្ទវិញ ហេតុនោះបានជាយើងជឿដល់ព្រះគ្រីស្ទយេស៊ូវ ដើម្បីឲ្យបានរាប់ជាសុចរិត ដោយសារសេចក្តីជំនឿ ជឿដល់ព្រះគ្រីស្ទ នោះ មិនមែនដោយប្រព្រឹត្តតាមក្រឹត្យវិន័យទេ ពីព្រោះគ្មានមនុស្សណាបានរាប់ជាសុចរិតដោយប្រព្រឹត្តតាមក្រឹត្យវិន័យឡើយ” កាឡាទី 2:16**

ហើយសម្រាប់អាវធំដែលនៅលើខ្នងរបស់ខ្ញុំនេះ ព្រះអម្ចាស់នៃកន្លែងដែលខ្ញុំទៅបានប្រទានមកខ្ញុំ ហើយគឺប្រើសម្រាប់នឹងគ្របបាំងសេចក្តីអាក្រាតរបស់ខ្ញុំ ដែលអ្នកបាននិយាយនោះ។ ហើយខ្ញុំបានរាប់វាថាជាចំណែកមួយនៃសេចក្តីសប្បុរសរបស់ទ្រង់មកកាន់ខ្ញុំ ដោយសារខ្ញុំមិនមានអ្វីសោះ មានតែកន្ទបកាលពីមុននោះ។ ហើយក្រៅពីនោះ ខ្ញុំបានកំសាន្តចិត្តរបស់ខ្ញុំកាលដែលខ្ញុំទៅនោះ។ ពិតណាស់ កាលមកដល់ឃ្លោងទ្វារនៃទីក្រុងខ្ញុំបានគិតថា ព្រះអម្ចាស់នឹងស្គាល់ខ្ញុំរាប់ជាការល្អ ក្នុងកាលដែលខ្ញុំមានអាវធំរបស់ទ្រង់នៅលើខ្នងរបស់ខ្ញុំ អាវធំដែលទ្រង់បានឱ្យដល់ខ្ញុំដោយឥតគិតថ្លៃនៅថ្ងៃដែលទ្រង់ដោះកន្ទបចេញពីខ្ញុំ។ ក្រៅពីនោះ ខ្ញុំមានសញ្ញានៅលើថ្ងាស់របស់ខ្ញុំដែលប្រហែលអ្នកមិនបានកត់សម្គាល់ទេ វាជាទំនាក់ទំនងមួយយ៉ាងជិត

ស្និតមួយរបស់ព្រះអម្ចាស់របស់ខ្ញុំ ដែលបានសម្រេចនៅថ្ងៃដែលបន្ទុករបស់ខ្ញុំបានធ្លាក់ចុះពីស្មាររបស់ខ្ញុំ។ បន្ថែមលើនោះ ខ្ញុំនឹងប្រាប់អ្នកទៀតថា មានគេប្រាប់ខ្ញុំថាខ្ញុំនឹងត្រូវបង្ហាញវានៅឃ្លោងទ្វារនៃទីក្រុងស្ថានសួគ៌ ជាទីសម្គាល់នៃការចូលខាងក្នុងពិតប្រាកដ ខ្ញុំឆ្ងល់ថាតើរបស់មួយណាដែលអ្នកចង់បាន ដោយសារអ្នកមិនបានចូលមកតាមឃ្លោងទ្វារទេ។

ដោយបែបនោះ ពួកគេមិនបានឆ្លើយតបទៅគាត់ទេ ពួកគេមើលមុខគ្នាទៅវិញទៅមកហើយសើច។ បន្ទាប់មកខ្ញុំឃើញថាពួកគេបន្តទៅមុខទៀត ហើយគ្រីស្ទានបានធ្វើដូចមុនដែរ គាត់មិននិយាយទៀតឡើយ តែនិយាយជាមួយខ្លួនឯង ហើយជួនកាលក៏ដល់ដង្ហើមធំ ហើយជាញឹកញាប់គាត់អានសារដែលបុរសភ្លឺថ្លៃចែងចាំងម្នាក់បានអោយគាត់ នោះគាត់ក៏បានស្រស់ស្រាយឡើយវិញ។

ខ្ញុំមើលទៅ ឃើញថាពួកគេបានមកដល់ជើងភ្នំ "សេចក្តីលំបាក" នៅបានវាមានប្រភពទឹកមួយ។ ហើយនៅកន្លែងនោះមានផ្លូវពីរទៀតនៅក្បែរផ្លូវដែលត្រង់ចេញពីឃ្លោងទ្វារ ផ្លូវមួយបត់ទៅឆ្វេងដៃ ហើយផ្លូវមួយទៀតបត់ទៅស្តាំដៃនៅបាតភ្នំនោះ តែផ្លូវចង្អៀតលាតទៅត្រង់ឡើងភ្នំ (ឈ្មោះនៃការឡើងទៅលើភ្នំត្រូវបានហៅថា សេចក្តីលំបាក)។ ពេលនេះគ្រីស្ទានបានទៅកាន់ប្រភពទឹក រួចផឹកដើម្បីនឹងជួយឱ្យបានស្រស់ស្រាយ។

**"គេនឹងមិនដែលស្រេកឃ្លានទៀត ឯចំហាយក្តៅ ឬព្រះអាទិត្យ នឹងមិនធ្វើទុក្ខគេ ដ្បិតព្រះដែលផ្តល់សេចក្តីមេត្តាដល់គេ ទ្រង់នឹងនាំគេទៅ អើ ទ្រង់នឹងដឹកដៃគេនាំទៅតាមទីមានក្បាលទឹក" អេសាយ 49:10**

ហើយក៏ចាប់ឡើងទៅលើកំពូលភ្នំដោយនិយាយថា

"ភ្នំនេះទោះជាខ្ពស់ក៏ដោយ ក៏ខ្ញុំនៅតែចង់ឡើងដែរ។ ខ្ញុំនឹងមិនរាថយដោយសារសេចក្តីលំបាកឡើយ ដោយសារខ្ញុំយល់ថា ផ្លូវនៃជីវិតស្ថិតនៅទីនេះ។ ចូរមក ចូរតាំងចិត្តឡើង ចូរកុំដួលចុះ ឬភ័យខ្លាចឡើយ! ជាការដែលល្អប្រសើរដែលទៅតាមផ្លូវត្រូវ បើទោះជាលំបាកក៏ដោយ ជាជាងទៅតាមផ្លូវស្រួល តែទីបញ្ចប់ជាសេចក្តីបណ្តាសា។"

ពីរនាក់ទៀតក៏បានមកដល់ជើងភ្នំដែរ តែនៅពេលពួកគេបានឃើញថា ភ្នំនោះចោត ហើយខ្ពស់ទៀត ហើយកាលដែលមានផ្លូវពីរផ្សេងទៀតដើម្បីនឹងដើរទៅនោះ ហើយនិយាយថាផ្លូវពីរនេះនឹងទៅជួបទាន់ជាមួយនឹងផ្លូវដែលគ្រីស្ទានដើរដែរ ដែលនៅម្ខាងទៀតនៃភ្នំ ដូច្នេះសម្រេចថានឹងទៅតាមផ្លូវទាំងនោះ (ឥឡូវឈ្មោះរបស់ផ្លូវទាំងនោះគឺ "គ្រោះថ្នាក់" និងមួយទៀត "សេចក្តីវិនាសអន្តរាយ")។ ដូចនេះម្នាក់បានជ្រើសយកផ្លូវដែលមានឈ្មោះថា "គ្រោះថ្នាក់" ដែលបានទៅកាន់ព្រៃមួយយ៉ាងធំ ហើយម្នាក់ទៀតបានដើរតាមផ្លូវនៃសេចក្តីវិនាសអន្តរាយ ដែលនាំទៅកានទីវាលមួយយ៉ាងធំពេញដោយភ្នំងងឹតៗ ដែលគាត់បានជំពប់ដួលហើយងើបមិនរួចសោះ។

## ភ័យខ្លាច និង មិនទុកចិត្ត

ខ្ញុំបានមើលទៅកាន់គ្រីស្ទានដើរឡើងលើភ្នំ នៅពេលដែលខ្ញុំឃើញថាគាត់កំពុងតែធ្លាក់ពីការរត់ឡើង ហើយពីការដែលគាត់ស្រវាឡើងដោយដៃនិងជង្គង់របស់គាត់ ដោយសារតែកន្លែងនោះវាចោតពេក។ ឥឡូវប្រហែលមកដល់ពាក់កណ្តាលផ្លូវទៅដល់កំពូលភ្នំមានកន្លែងសម្រាកមួយយ៉ាងល្អ ដែលព្រះអម្ចាស់នៃភ្នំនោះបានបង្កើតឡើង សម្រាប់ជាទ្រទ្រង់ដល់អ្នកធ្វើដំណើរដែលនឿយហត់។ ដូច្នេះគ្រីស្ទានបានទៅអង្គុយសម្រាកនៅទីនោះ។ បន្ទាប់មកគាត់បានទាញសារពីដើមទ្រូងរបស់គាត់មកអាននៅទីនោះដើម្បីជាការកំសាន្តចិត្តដល់គាត់។ ពេលនេះគាត់ក៏បានសង្កេតមើលអាវក្រៅរបស់គាត់ជាថ្មីម្តងទៀត ជាអាវដែលមួយអង្គបានឱ្យមកគាត់ពេលគាត់បានឈរក្បែរឈើឆ្កាង។ ដូច្នេះក៏បានគាប់ចិត្តដល់ខ្លួនមួយរយៈ ហើយចុងក្រោយគាត់បានងោកងុយ ហើយក៏ដេកលក់ភ្លាមរហូតដល់ជិតយប់ ហើយកាលគាត់នៅដេកនៅឡើយសារនោះបានធ្លាក់ចេញពីដៃរបស់គាត់។ ឥឡូវកាលដែលកំពុងដេក មានម្នាក់បានមកហើយដាស់គាត់ដោយនិយាយថា "ចូរទៅកាន់សត្វស្រមោច ឱមនុស្សកំជិលអើយ ចូរពិចារណាហើយចូរមានប្រាជ្ញាចុះ។"

**"ឱមនុស្សខ្ជិលច្រអូសអើយ ចូរទៅមើលស្រមោចចុះ ចូរពិចារណាផ្លូវទាំងប៉ុន្មានរបស់វា ហើយមាន ប្រាជ្ញាឡើង" សុភាសិត 6:6**

ហើយដោយដូច្នោះ គ្រីស្ទានក៏បានក្រោកភ្លាម ហើយបានទៅតាមផ្លូវរបស់គាត់យ៉ាងលឿន ហើយទៅរហូតទាល់តែគាត់បានមកដល់កំពូលភ្នំ។

ពេលនេះគាត់បានមកដល់កំពូលភ្នំ ហើយមានបុរសពីរនាក់បានរត់មកប ញ្ច្រាស់ជាមួយគាត់ដោយកំហឹង។ ម្នាក់មានឈ្មោះថាភ័យខ្លាច និងម្នាក់ទៀតឈ្មោះថា មិនទុកចិត្ត។ គ្រីស្ទានបាននិយាយទៅពួកគេថា "លោកម្ចាស់អើយ មានរឿងអ្វីដែរ? អ្នករត់ទៅខុសផ្លូវហើយ!"

ភ័យខ្លាចបានឆ្លើយថា ពួកគេកំពុងតែទៅកាន់ក្រុងស៊ីយ៉ូន ហើយបានមកដល់កន្លែងលំបាក "តែ" គាត់និយាយថា "យើងទៅកាន់តែឆ្ងាយ យើងជួបការលំបាកកាន់តែច្រើន ដូច្នេះយើងបានត្រលប់មកវិញ ហើយកំពុងដើរទៅក្រោយវិញ។"

មិនទុកចិត្ត បាននិយាយថា "បាទ" "ទៅមុខយើងបន្តិចមានសត្វតោដេកមួយចំនួននៅតាមផ្លូវ មិនដឹងថាពួកវាដេកឬអត់នោះទេ ហើយយើងគិតមិនចេញឡើយ ថាប្រសិនបើយើងមកជិតដល់ នោះពួកវានឹងហែកយើងទៅជាចំណែកៗភ្លាមៗនោះ។"

គ្រីស្ទាន៖ បន្ទាប់មកគ្រីស្ទានបាននិយាយថា "អ្នកធ្វើឱ្យខ្ញុំខ្លាចហើយ តែ តើខ្ញុំគួរតែហោះទៅទីណាទើបមានសុវត្ថិភាពនោះ? ប្រសិនបើខ្ញុំត្រឡប់ទៅប្រទេសរបស់ខ្ញុំវិញ នោះជាទីដែលទុកសម្រាប់នឹងភ្លើងឆេះនិងស្ពាន់ធ័រ ហើយខ្ញុំនឹងត្រូវវិនាសយ៉ាងពិតប្រាកដនៅទីនោះ! ប្រសិនបើខ្ញុំអាចទៅដល់ទីក្រុងស្ថានសួគ៌វិញ ខ្ញុំប្រាកដថានឹងមានសុវត្ថិភាពនៅទីនោះ។ ខ្ញុំត្រូវតែប្រថុយទៅ។ បើត្រឡប់ទៅវិញ គឺមិនមានអ្វីក្រៅពីសេចក្ដីស្លាប់ឡើយ។ ទៅមុខជាសេចក្ដីភ័យខ្លាចនៃការស្លាប់និងជីវិតអស់កល្បជានិច្ចដែលលើសលប់

! ខ្ញុំនឹងដើរទៅមុខដដែល!″

## ដេកនៅពេលថ្ងៃ

ដូច្នេះមិនទុកចិត្ត និង ភ័យខ្លាចបានរត់ចុះពីភ្នំ ហើយគ្រីស្ទានបានទៅតាមផ្លូវរបស់គាត់ទៅ។ តែបានគិតពីអ្វីដែលគាត់បានឮពីបុរសទាំងពីរ គាត់ក៏ស្ទាបដើមទ្រូងរបស់គាត់រកមើលគម្ពីររបស់គាត់ ដើម្បីយកមកអាននិងទទួលបានការកំសាន្តចិត្ត តែគាត់មិនស្ទាបមិនប៉ះទេ។ បន្ទាប់មកគ្រីស្ទានមានទុកលំបាកយ៉ាងខ្លាំង ហើយមិនដឹងថាត្រូវធ្វើអ្វីទេ ដោយសារគាត់ចង់បានរបស់ដែលជួយឱ្យគាត់បានរសាយចិត្ត ដែលជាអ្វីដែលជួយឱ្យគាត់បានឆ្លងគាត់រហូតដល់ទីក្រុងស្ថានសួគ៌។ ដូច្នេះទីនេះ គាត់ចាប់ផ្ដើមច្របូកច្របល់ ហើយមិនថាត្រូវធ្វើអ្វីទេ។ ជាចុងក្រោយគាត់បានគិតថាគាត់នឹងដេកនៅក្នុងទីសំណាក់ដែលនៅក្បែរភ្នំសិន ហើយគាត់បានលត់ជង្គង់ចុះ ហើយសុំការអត់ទោសមកពីព្រះសម្រាប់អំពើល្ងង់ខ្លៅរបស់គាត់ ហើយបន្ទាប់មកបានត្រឡប់ទៅរកសាររបស់គាត់វិញ។ តែតាមផ្លូវដែលគាត់ត្រឡប់ទៅវិញនោះ តើមានមនុស្សណាដែលអាចនឹងរៀបរាប់ឱ្យត្រឹមត្រូវពីសេចក្ដីសោកសង្រេងនៅក្នុងចិត្តរបស់គ្រីស្ទានបានដែរទេ? ពេលខ្លះគាត់ក៏ដកដង្ហើមធំ ជួនកាលគាត់ទួញយំ ហើយជាញឹកញាប់គាត់បន្ទោសខ្លួនឯងដែលល្ងង់ទៅដេកលក់នៅកន្លែងដូចនោះ ជាកន្លែងដែលបានសង់ឡើងសម្រាប់ឱ្យបានធូរស្បើយតែបន្តិចពីការនឿយហត់ប៉ុណ្ណោះ។

ដូច្នេះគាត់ក៏បានត្រឡប់ទៅវិញ ហើយសម្លឹងរកកៀននេះកៀននោះដោយប្រយត្នតាមផ្លូវដែលគាត់ត្រឡប់ទៅវិញដោយថាប្រហែលគាត់អាចនឹងរកឃើញសាររបស់គាត់ ដែលធ្លាប់តែជាសេចក្ដីកំសាន្តដល់គាត់ជាច្រើនដង

នៅក្នុងការធ្វើដំណើររបស់គាត់។ គាត់ត្រឡប់ទៅវិញរហូតដល់គាត់ទៅដល់ទីកំណាក់ម្តងទៀតជាកន្លែងដែលគាត់បានអង្គុយហើយដេកលក់។ តែទីនោះបានធ្វើឱ្យគាត់មានក្តីទុក្ខថែមទៀត ដោយបានទាញយកអំពើអាក្រក់របស់គាត់ជាថ្មីមក ដែលបានដេកលក់នៅក្នុងគំនិតរបស់គាត់។ ដូច្នេះគាត់បានបន្តទៅមុនដោយស្តាយពីបាបដែលដេកលក់របស់គាត់ ដោយនិយាយថា "ឱ តើខ្ញុំជាមនុស្សអាក្រក់យ៉ាងណាហ្ន៎ ដែលខ្ញុំដេកនៅពេលថ្ងៃទៅវិញ! ដែលខ្ញុំបានដេកនៅក្នុងពេលដែលមានទុក្ខលំបាកទៅវិញ!"

**"ដ្បិតអ្នកដេកលក់នោះគេតែងដេកលក់នៅពេលយប់ ហើយពួកអ្នកដែលស្រវឹងស្រា ក៏តែងស្រវឹងនៅពេលយប់ដែរ។ តែយើងដែលជាពួកនៃថ្ងៃ យើងត្រូវដឹងខ្លួន ទាំងប្រដាប់កាយដោយសេចក្តីជំនឿ និងសេចក្តីស្រឡាញ់ ទុកជាប្រដាប់បាំងដើមទ្រូង ហើយសេចក្តីសង្ឃឹមរបស់ផងសេចក្តីសង្គ្រោះ ទុកជាមួកសឹក។"    ថែស្សាឡូនិច ទី១ 5:7, 8**

**"តែអញប្រកាន់សេចក្តីនេះនឹងឯង គឺថាឯងបានបោះបង់ចោលសេចក្តីស្រឡាញ់ដើមចេញ។ ដូច្នេះចូរនឹកចាំ ដែលឯងបានធ្លាក់ចេញពីសណ្ឋានណានោះ ហើយប្រែចិត្តចុះ រួចប្រព្រឹត្តតាមការដើមដំបូងនោះវិញ ពុំនោះសោតអញនឹងមកឯឯង ហើយនឹងហូតយកជើងចង្កៀងឯងពីកន្លែងចេញ លើកតែឯងប្រែចិត្តឡើងវិញ។"  វិវរណៈ 2:4, 5**

ដែលខ្ញុំបានផ្តាប់ដល់សាច់ឈាម ដែលប្រើដើម្បីសំរាកដល់សាច់ឈាមរបស់ខ្ញុំ ដែលព្រះអម្ចាស់នៃភ្នំបានសង់សំរាប់ជួយសំរាលទុក្ខវិញ្ញាណរបស់អ្នកដែលធ្វើដំណើរ។ តើខ្ញុំបានបោះជំហានដោយឥតប្រយោជន៍ប៉ុន្មាន

ជំហានហើយហ្ន៎! (ការនេះក៏បានកើតឡើងដល់ពួកអ៊ីស្រាអែល ដោយសារបាបរបស់ពួកគេ ពួកគេបានវិលត្រឡប់ទៅតាមផ្លូវសមុទ្រក្រហមម្តងទៀត។ ហើយខ្ញុំបានដើរជាន់ជំហានទាំងនោះដោយទុក្ខព្រួយ ដែលខ្ញុំគួរតែដើរដោយរីករាយវិញ ប្រសិនបើមិនបានដេកលក់ជាបាបនោះទេ។ តើពេលនេះខ្ញុំអាចធ្វើដំណើរបានឆ្ងាយប៉ុណ្ណាទៅហ្ន៎! ខ្ញុំត្រូវបានដើរតាមដានជើងនោះបីដង ដែលខ្ញុំមិនចាំបាច់ដើរតាមសូមបីតែម្តងទេ។ ឥឡូវនេះខ្ញុំក៏ដូចជាល្ងង់អីចឹង ដោយព្រោះយប់ជិតមកដល់ហើយ។ អូថាបើខ្ញុំមិនបានដេកទេ!"

ឥឡូវនេះលោកបានទៅដល់កន្លែងសំណាក់ម្តងទៀត ដែលគាត់អង្គុយចុះរួចយំមួយរយៈ។ ប៉ុន្តែនៅពេលចុងក្រោយ (ដូចជាគ្រីស្តគ្រីស្ទៀនចង់បាន) ក្រលេកមើលដោយក្រៀមក្រំនៅលើទីជំរក គាត់បានមើលឃើញគម្ពីររបស់គាត់ ដែលធ្វើឱ្យគាត់រញ្ជួយញាប់ញ័រហើយស្ទុះទៅយក រួចដាក់លើទ្រូងរបស់គាត់។ ប៉ុន្តែតើនរណាអាចប្រាប់បានថាបុរសនេះសប្បាយចិត្តយ៉ាងណាពេលដែលគាត់បានគម្ពីររបស់គាត់ម្តងទៀត! សម្រាប់គម្ពីរនេះគឺជាការធានាអះអាងនៃជីវិតនិងការទទួលយករបស់គាត់នៅឯកន្លែងដែលជាស្ថានសួគ៌។ ដូច្នេះគាត់ដាក់វានៅក្នុងទ្រូងរបស់គាត់។ អរព្រះគុណព្រះដែលបាននាំភ្នែកទៅកន្លែងដែលដាក់គម្ពីរនោះ។ ហើយដោយទឹកមុខសប្បាយរីករាយនិងទឹកភ្នែក គាត់បានធ្វើដំណើររបស់គាត់តទៅទៀត។ អូប៉ុន្តែ! តើគាត់បានឡើងទៅលើភ្នំដែលនៅសល់យ៉ាងដូចម្តេចទៅ! តែមុនពេលគាត់ក្រោកពីដំណេក ព្រះអាទិត្យបានលិចទៅរំលងលើគ្រីស្ទានទៅហើយ។ ហើយនេះបានធ្វើឱ្យគាត់រំនឹកចាំពីភាពឥតប្រយោជន៍នៃការគេងរបស់គាត់ជាថ្មីម្តងទៀត ហើយដូច្នេះគាត់បានចាប់ផ្តើមសោកសៅជាមួយខ្លួនគាត់ម្តងទៀត

ដោយនិយាយថា "អូអ្នកដេកលក់ដែលមានបាបអើយ! ដោយសារតែអ្នក នោះការធ្វើដំណើររបស់ខ្ញុំត្រូវបានពន្យាពេល ខ្ញុំត្រូវដើរដោយគ្មានពន្លឺព្រះអាទិត្យ ភាពងងឹតត្រូវគ្របដណ្តប់លើផ្លូវនៃជើងខ្ញុំហើយ ខ្ញុំត្រូវស្តាប់ឮសំលេងរបស់សត្វយំ - ព្រោះតែបាបនៃការដេកលក់របស់ខ្ញុំ! ឥឡូវនេះគាត់ក៏បានចងចាំរឿងរ៉ាវដែលមិនទុកចិត្ត និងភ័យខ្លាចបានប្រាប់គាត់ ពីរបៀបដែលពួកគេភ័យខ្លាចជាមួយនឹងការជួបសត្វតោ។ បន្ទាប់មកគ្រីស្ទសាសនាបាននិយាយទៅកាន់ខ្លួនគាត់ជាថ្មីម្តងទៀតថា "សត្វទាំងនេះមាននៅពេលយប់ដើររកចំណីរបស់វា ប្រសិនបើពួកវាមកជួបខ្ញុំនៅក្នុងទីងងឹត តើខ្ញុំគួរផ្លាស់ប្តូរពួកគេយ៉ាងដូចម្តេច? តើខ្ញុំនឹងគេចឱ្យរួចកុំឱ្យត្រូវវាហែកជាចំណែកបានយ៉ាងដូចម្តេច? គាត់ក៏ចេញទៅ។ ប៉ុន្តែនៅពេលដែលគាត់កំពុងតែទួញសោកដោយសារការបរាជ័យរបស់គាត់ នោះគាត់បានងើបភ្នែកឡើងហើយឃើញមានវិមានមួយនៅពីមុខគាត់ ដែលមានឈ្មោះថាស្រស់ស្អាត ហើយវាឈរនៅក្បែរមហាវិថី។

## ការចូលទៅកាន់វិមាន "ស្រស់ស្អាត"

ដូច្នេះខ្ញុំបានឃើញក្នុងសុបិនខ្ញុំថា គាត់ប្រញាប់ហើយទៅមុខ បើអាចទៅរួច នោះគាត់អាចនឹងស្នាក់នៅទីនោះ។ មុនពេលដែលគាត់ធ្វើដំណើរទៅឆ្ងាយ គាត់បានទៅដល់ផ្លូវតូចមួយចម្ងាយប្រហែលមួយគីឡូម៉ែត្រពីផ្ទះសំណាក់របស់អ្នកយាម។ គាត់សំឡឹងមើលទៅមុខគាត់កាលដែលដើរទៅនោះ ឃើញមានសឹង្ហពីរនៅចំពោះមុខ។ ឥឡូវគាត់គិតថាខ្ញុំមើលឃើញថាគ្រោះថ្នាក់ដែលមិនទុកចិត្តនិងភ័យខ្លាចបានរត់គេចចេញនោះហើយ។ (សត្វតោត្រូវបានគេដាក់ច្រវាក់ ប៉ុន្តែគាត់មិនបានឃើញច្រវាក់ទេ)។ ពេលនោះគាត់ខ្លាច ហើយគាត់គិតថាខ្លួនត្រូវរត់តាមពួកគេហើយ។ ព្រោះគាត់មិនបានគិតអ្វីក្រៅពីសេចក្តីស្លាប់នៅមុខគាត់ទេ។ ប៉ុន្តែអ្នកយាមនៅឯផ្ទះសំណាក់ដែលមានឈ្មោះថាឃ្លាំមើល ដឹងថាគ្រីស្ទានឈប់ ហាក់ដូចជាចង់ត្រលប់ទៅវិញ ក៏បានស្រែករកគាត់ថា "តើកម្លាំងរបស់អ្នកតូចឬអី?"

### "រួចទ្រង់មានបន្ទូលថា ហេតុអ្វីបានជាអ្នករាល់គ្នាភ័យដល់ម្ល៉េះ ម្តេចក៏គ្មានសេចក្តីជំនឿ?" ម៉ាកុស 4:40

ចូរកុំខ្លាចសត្វតោធ្វើអ្វី ដោយសារពួកវានៅជាប់ច្រវាក់ទេ ហើយពួកវាត្រូវបានដាក់នៅទីនោះសម្រាប់ជាការសាកល្បងដល់ជំនឿនៅទីនោះ ហើយសម្រាប់នឹងស្វែងរកអ្នកដែលមិនមានសេចក្តីជំនឿសោះ ចូរនៅកណ្តាលផ្លូវរបស់អ្នក ហើយនឹងមិនមានការឈឺចាប់ណាមកកាន់អ្នកឡើយ!"

បន្ទាប់មកខ្ញុំបានឃើញគាត់បន្តទៅមុខទៀត ដោយញាប់ញ័រទាំងខ្លាចសត្តោ តែបានស្តាប់ទៅការណែនាំយ៉ាងល្អរបស់អ្នកយាមទ្វារ។ គាត់បានពួកវាគ្រហឹម តែពួកវាមិនបានធ្វើឱ្យគាត់មានរបួសអ្វីទាំងអស់។ បន្ទាប់មកគាត់បានទះដៃ រួចបន្តទៅមុខទៀត រហូតដល់គាត់មកដល់ឃ្លោងទ្វាររួចឈរនៅមុខអ្នកយាមទ្វារនៅទីនោះ។ បន្ទាប់មកគ្រីស្ទានបាននិយាយទៅកាន់អ្នកយាមទ្វារថា "ឱលោក តើផ្ទះនេះជាអ្វីទៅ? ហើយតើខ្ញុំអាចស្នាក់នៅទីនេះយប់នេះបានទេ?" អ្នកយាមបានឆ្លើយថា "ផ្ទះនេះត្រូវបានសង់ឡើងដោយព្រះអម្ចាស់នៃភ្នំនេះ ហើយទ្រង់បានសង់វាសម្រាប់ជាការបន្ធូរស្រាលនិងសុវត្ថិភាពរបស់អ្នកធ្វើដំណើរ។" អ្នកយាមសួរថាគាត់បានមកពីពេលណា ហើយកំពុងទៅណា?

គ្រីស្ទាន៖ ខ្ញុំមកពីទីក្រុងនៃសេចក្តីវិនាសអន្តរាយ ហើយកំពុងទៅកាន់ភ្នំស៊ីយ៉ូន តែដោយសារព្រះអាទិត្យបានលិចទៅហើយ ខ្ញុំចង់សម្រាកនៅទីនេះយប់នេះ ប្រសិនបើអាច។

អ្នកចាំយាមល្អ៖ តើអ្នកឈ្មោះអ្វីដែរ?

គ្រីស្ទាន៖ ខ្ញុំឈ្មោះគ្រីស្ទាន តែឈ្មោះរបស់ខ្ញុំដំបូងនោះគឺ គ្មានព្រះគុណ។ ខ្ញុំកើតមកពីពូជយ៉ាផែត ជាអ្នកដែលព្រះនឹងនាំឱ្យសម្រាកនៅក្នុងជំរុំរបស់សិម។

**"សូមព្រះទ្រង់វាតទីឱ្យយ៉ាផែត សូមឱ្យវាបានស្រោយនៅក្នុងទីលំនៅរបស់សិម ហើយឱ្យកាណានបានធ្វើជាបាវបំរើរបស់វាដែរ។" លោកុប្បត្តិ 9:27**

អ្នកយាមទ្វារ៖ តែតើមានអ្វីកើតឡើងបានជាអ្នកមកយឺតម្ល៉េះ? ព្រះអាទិត្យបានលិចទៅហើយ!

គ្រីស្ទាន៖ ខ្ញុំបានមកនេះដល់ឆាប់ដែរ តែដោយសារខ្ញុំជាមនុស្សអាក្រក់ ខ្ញុំបានដេកនៅទីសំណាក់ដែលនៅក្បែរភ្នំនោះ។ បើមិនដោយសារការនោះទេ នោះខ្ញុំនឹងមកដល់ឆាប់ជាងនេះ តែនៅក្នុងពេលដេកលក់ខ្ញុំបាត់ភស្តុតាងរបស់ខ្ញុំ ហើយមកដោយមិនយកវាមករហូតដល់កំពូលភ្នំ ហើយបន្ទាប់មកក៏បានស្វាបរកវាដែរ ហើយរកមិនឃើញសោះ ក៏មិនចិត្តសោកសង្រេងដែលត្រូវត្រឡប់ទៅកន្លែងដែលខ្ញុំបានដេកលក់វិញ នោះខ្ញុំក៏រកវាឃើញ ហើយឥឡូវនេះខ្ញុំបានមកដល់ហើយ។

អ្នកយាមទ្វារ៖ ល្អណាស់ ខ្ញុំនឹងហៅស្រីក្រមុំនៅទីនេះម្នាក់មក នាងនឹងនិយាយជាមួយអ្នកហើយនាំអ្នកទៅកាន់អ្នកផ្សេងទៀតនៅក្នុងគ្រួសារ ធ្វើទៅតាមច្បាប់របស់គ្រួសារ។ ដូច្នេះអ្នកយាមទ្វារបានគោះកណ្ដឹង ស្រីក្រមុំម្នាក់បានចេញពីទ្វារមកកាលដែលបានឮសម្លេងកណ្ដឹង នាងមានឈ្មោះថាការសម្រេចចិត្ត ហើយបានសួរហេតុអ្វីបានជាហៅនាងមក។

អ្នកយាមទ្វារ បានឆ្លើយថា "បុរសម្នាក់នេះធ្វើដំណើរពីទីក្រុងនៃសេចក្ដីវិនាសអន្តរាយទៅកាន់ភ្នំស៊ីយ៉ូន។ តែដោយសារតែងងឹតយប់ ហើយមិនដឹងធ្វើយ៉ាងណា គាត់បានសុំស្នាក់នៅទីនេះនៅយប់នេះ។ ដូច្នេះខ្ញុំបានប្រាប់គាត់ថាខ្ញុំនឹងហៅរកនាងមក ដែលនាងជាអ្នកដែលនឹងពិភាក្សាជាមួយគាត់ ដែលនឹងធ្វើតាមដែលល្អសម្រាប់អ្នក ទាំងធ្វើតាមច្បាប់នៃគ្រួសារផង។"

ការសម្រេចចិត្ត៖ បន្ទាប់មកនាងបានសួរគាត់ថា តើគាត់នៅឯណា ហើយគាត់កំពុងទៅទីណា។ ហើយគាត់ក៏បានប្រាប់នាង។ នាងក៏បានសួរថាគាត់បានមកតាមផ្លូវនេះដោយរបៀបណា ហើយគាត់ក៏ប្រាប់នាង។ បន្ទាប់មកនាងបានសួរថាតើគាត់បានឃើញនិងជួបអ្វីខ្លះនៅតាមផ្លូវ ហើយគាត់ក៏បានប្រាប់នាង។ ហើយចុងក្រោយ នាងបានសួរឈ្មោះរបស់គាត់ ដូច្នេះគាត់បាននិយាយថា "គឺជាគ្រីស្ទាន ហើយខ្ញុំមានបំណងចង់ស្នាក់នៅទីនេះណាស់នៅយប់នេះ ដោយសារតាមដែលខ្ញុំយល់ ទីនេះត្រូវបានសង់ឡើងដោយព្រះអម្ចាស់នៃភ្នំនេះ សម្រាប់ជាការសម្រាលនិងសុវត្ថិភាពដល់អ្នកធ្វើដំណើរ។" ដូច្នេះនាងបានញញឹម តែទឹកបានឈរនៅក្នុងភ្នែករបស់នាង ហើយបន្ទាប់ពីឈប់បន្តិចមក នាងបាននិយាយថា "ខ្ញុំនឹងហៅពីបីនាក់នៅក្នុងគ្រួសារមក" ដូច្នេះនាងបានរត់ទៅកាន់ទ្វារ ហើយបានហៅរក ប្រយត្នប្រយ៉ែង មុតមាំ និង សប្បុរស ពួកគេជាអ្នកដែលនឹងនាំគាត់ចូលទៅក្នុងគ្រួសារបន្ទាប់ពីបាននិយាយជាមួយគាត់បន្តិចមក ហើយមានមនុស្សជាច្រើនបានជួបគាត់នៅទីលានខាងមុខផ្ទះ បាននិយាយថា "ចូលមក ឱអ្នកដ៏មានពររបស់ព្រះអម្ចាស់អើយ! ផ្ទះនេះត្រូវបានសង់ឡើងដោយព្រះអម្ចាស់នៃភ្នំនេះ ដោយមានគោលបំណងនឹងកំសាន្តចិត្តដល់អ្នកដែលធ្វើដំណើរដូចនេះ។" បន្ទាប់មកគាត់បានឱនក្បាលរបស់គាត់ ហើយដើរតាមពួកគេចូលទៅក្នុងផ្ទះ។ ដូច្នេះនៅពេលដែលគាត់បានចូលក្នុង រួចបានអង្គុយចុះ ពួកគេបានឱ្យអ្វីមួយដល់គាត់ផឹក ហើយបានយល់ស្របគ្នាថា ទាល់តែអាហារពេលយប់រួចរាល់ អ្នកខ្លះនៃពួកគេនឹងត្រូវជជែកជាមួយគ្រីស្ទានខ្លះៗ ដើម្បីប្រើពេលវេលាឲ្យមានប្រយោជន៍ នោះគេបានចាត់តាំង មុតមាំ ប្រយត្នប្រយ៉ែង និង សប្បុរសមកជជែកជាមួយគាត់។ ដូច្នេះពួកគេក៏ចាប់ផ្តើមធ្វើតាម។

មុតមាំ៖ ចូរចូលមកគ្រីស្ទានល្អអើយ កាលដែលយើងស្រឡាញ់ដល់អ្នកខ្លាំងណាស់ ដែលបានទទួលអ្នកមកក្នុងផ្ទះរបស់ពួកយើងយប់នេះ។ ប្រសិនជាយើង ដែលកាន់តែប្រសើរនោះ យើងនឹងជជែកជាមួយអ្នកនូវគ្រប់រឿងដែលបានកើតឡើងមកកាន់អ្នកនៅក្នុងការធ្វើដំណើររបស់អ្នក។

គ្រីស្ទាន៖ ដោយបំណងល្អ ហើយខ្ញុំក៏រីករាយដែលអ្នកមានបំណងដ៏ល្អបែបនេះ។

មុតមាំ៖ តើអ្វីដែលបានធ្វើឱ្យអ្នកមកកាន់ជីវិតជាអ្នកធ្វើដំណើរនេះពីដំបូងមកនោះ?

គ្រីស្ទាន៖ ខ្ញុំត្រូវបានបណ្តេញចេញពីប្រទេសកំណើតរបស់ខ្ញុំ ដោយសម្លេងដែលគួរឱ្យភ័យខ្លាចនៅក្នុងត្រចៀករបស់ខ្ញុំ ឱ្យគេចចេញ ដែលសេចក្តីវិនាសដែលគេចមិនផុតនឹងមកកាន់ខ្ញុំ ប្រសិនបើខ្ញុំនឹងនៅកន្លែងដែលខ្ញុំនៅនោះ។

មុតមាំ៖ តែតើវាកើតឡើងយ៉ាងដូចម្តេចទៅ ដែលអ្នកបានចេញមកពីប្រទេសរបស់អ្នករបៀបនេះ?

គ្រីស្ទាន៖ គឺវាដូចជាអ្វីដែលព្រះបានរៀបមកនោះ។ ដោយសារ នៅពេលដែលខ្ញុំនៅក្រោមការភ័យខ្លាចពីសេចក្តីអន្តរាយ ខ្ញុំមិនដឹងថានឹងទៅទីណានោះទេ។ តែចៃដន្យមានបុរសម្នាក់បានមកកាន់ខ្ញុំ (ក្នុងកាលដែលខ្ញុំកំពុងភ័យញ័រហើយទួញយំផង) គាត់ឈ្មោះ អ្នកផ្សាយដំណឹងល្អ ហើយគាត់បានណែនាំដល់ខ្ញុំឱ្យទៅកាន់ឃ្លោងទ្វារទុច្ចរិត មិនដូច្នោះទេខ្ញុំនឹងមិនអាចរក

ឃើញឡើយ។ ដូច្នេះក៏បាននាំខ្ញុំទៅកាន់ផ្លូវនោះដែលនាំខ្ញុំតម្រង់ទៅផ្ទះនេះ។

មុតមាំ៖ តែតើអ្នកមិនបានមកដោយឆ្លងកាត់ផ្ទះរបស់អ្នកបកស្រាយទេឬអី?

គ្រីស្ទាន៖ បាទបាន។ ហើយបានឃើញរបស់ដែលនៅទីនោះ ជាការចង់ចាំដែលនឹងនៅជាប់នឹងខ្ញុំពេញមួយជីវិតដែលខ្ញុំរស់នៅ។ ជាពិសេសគឺការបីយ៉ាង របៀបដែលគ្រីស្ទានរក្សាកិច្ចការនៃព្រះនៅក្នុងចិត្តជំនួសឱ្យកិច្ចការរបស់សាតាំង របៀបដែលមនុស្សបានធ្វើបាបផ្ទាល់ប្រៀបបីដូចជាមិនមានសង្ឃឹមថានឹងបានទទួលសេចក្តីមេត្តាមកពីព្រះ ហើយពីសុបិន្តដែលបានគិតនៅក្នុងពេលដេកលក់ពីថ្ងៃជំនុំជំរះដែលនឹងត្រូវមក។

មុតមាំ៖ ហេតុអ្វីបានជាអ្នកស្តាប់គាត់ប្រាប់ពីសុបិន្តនេះ?

គ្រីស្ទាន៖ បាទ ហើយខ្ញុំបានគិតថាវាគួរឱ្យភ័យខ្លាចណាស់។ វាបានធ្វើឱ្យចិត្តរបស់ខ្ញុំឈឺកាលដែលគាត់កំពុងប្រាប់ តែខ្ញុំរីករាយដែលបានស្តាប់។

មុតមាំ៖ តើទាំងនោះជាគ្រប់យ៉ាងដែលអ្នកបានឃើញនៅផ្ទះរបស់អ្នកបកប្រែមែនទេ?

គ្រីស្ទាន៖ ទេ។ គាត់បាននាំខ្ញុំទៅ ហើយបង្ហាញខ្ញុំនូវវិមានដ៏មាំមួនមួយ។ ហើយពីរបៀបដែលមនុស្សនៅទីនោះបំពាក់ដោយមាស ហើយពីរបៀបដែលមានបុរសបណ្តាក់ទុនម្នាក់មក ហើយបានជំនះបំរះរួចពីពួកអ្នកយាមដែលបានឈរនៅទ្វារដើម្បីកុំឱ្យគាត់ចូល ហើយពីរបៀបដែលគាត់ជំនះចូល

ក្នុងដើម្បីទទួលបានសិរីល្អដ៏អស់កល្ប។ ខ្ញុំគិតថាការទាំងនោះបានធ្វើឱ្យចិត្តរបស់ខ្ញុំមិនការស្ងប់ស្ងៃង។ ខ្ញុំគួរតែសម្រាកនៅផ្ទះរបស់បុរសល្អមួយឆ្នាំ តែខ្ញុំដឹងថាខ្ញុំត្រូវដើរទៅមុខឆ្ងាយទៀត។

មុតមាំ៖ តើអ្នកបានឃើញអ្វីទៀតទេនៅតាមផ្លូវ?

គ្រីស្ទាន៖ បានឃើញ! ខ្ញុំបានទៅមុខបន្តិចទៀត ហើយបានឃើញម្នាក់ ដែលខ្ញុំបានគិតនៅក្នុងគំនិតរបស់ខ្ញុំ ថាគាត់ត្រូវបានព្យួរនៅលើដើមឈើ ហើយដោយឃើញរូបភាពរបស់គាត់ដូច្នោះ នោះបន្ទុកបានធ្លាក់ចុះពីខ្នងរបស់ខ្ញុំ (ដោយសារខ្ញុំថ្ងូរនៅក្រោមបន្ទុកដ៏លំបាក) តែបន្ទាប់មកវាបានធ្លាក់ចេញពីខ្ញុំ។ វាជាការចម្លែកមួយដល់ខ្ញុំ ដោយសារខ្ញុំមិនដែលឃើញការនោះពីមុនមកទេ។ ហើយកាលដែលខ្ញុំឈរមើលទៅលើ (ដោយបន្ទាប់មកខ្ញុំមិនអាចនឹងទ្រាំមើលបានទៀត) មនុស្សចែងចាំងបីនាក់បានមករកខ្ញុំ។ មានម្នាក់បានធ្វើបន្ទាល់ថាអំពើបាបរបស់ខ្ញុំត្រូវបានអត់ទោសឱ្យហើយ ម្នាក់ទៀតបានដោះកន្ទបចេញពីខ្ញុំ ហើយបានឱ្យអាវប៉ាក់ក្រៅដែលអ្នកឃើញនេះមកខ្ញុំ ហើយអ្នកទីបីបានដាក់សញ្ញាដែលអ្នកឃើញនេះនៅលើថ្ងាស់របស់ខ្ញុំ ហើយបានផ្តល់គម្ពីរបោះត្រានេះមកខ្ញុំ (ហើយដោយគាត់បានយកវាចេញពីដើមទ្រូងរបស់គាត់)។

មុតមាំ៖ តែអ្នកបានឃើញច្រើនជាងនេះ តើមែនទេ?

គ្រីស្ទាន៖ ការទាំងប៉ុន្មានដែលខ្ញុំបានប្រាប់អ្នកជាការដែលល្អបំផុត។ តែខ្ញុំបានឃើញតូចៗជាច្រើនទៀត និយាយទៅខ្ញុំបានឃើញមនុស្សបីនាក់

មនុស្សល្ងង់ កំជិល និងសម្មត់ ដែលដេកចេញពីផ្លូវដែលខ្ញុំមកបន្តិច ដែលមានច្រវាក់ដែកនៅកែងជើងរបស់ពួកគេ។ តែតើអ្នកគិតថាខ្ញុំអាចដាស់ពួកគេឱ្យភ្ញាក់បានទេ! ខ្ញុំក៏បានឃើញ អ្នកស្របច្បាប់ និងមនុស្សកំពុតមកដោយភ័យញ័រពីលើជញ្ជាំង ដើរទៅដោយធ្វើពុតទៅកាន់ភ្នំស៊ីយ៉ូន តែពួកគេត្រូវវង្វេងមួយរំពេច។ ទោះតែខ្ញុំបានប្រាប់ពួកគេ ពួកគេនៅតែមិនជឿ តែលើសពីនោះទៀត ខ្ញុំបានរកឃើញថាវាពិតជាលំបាកណាស់ដែលត្រូវឡើងមកលើភ្នំនេះ ហើយកាន់តែលំបាកដែលត្រូវមកក្បែរមាត់សត្វតោ។ ហើយពិតណាស់ ប្រសិនបើមិនមានមនុស្សល្អទេ គឺអ្នកយាមដែលឈរនៅឃ្លោងទ្វារនោះខ្ញុំមិនដឹងថាខ្ញុំនឹងត្រូវត្រឡប់ក្រោយឬយ៉ាងណាទេ។ ប៉ុន្តែពេលនេះខ្ញុំអរព្រះគុណដល់ព្រះដែលខ្ញុំនៅទីនេះ ហើយខ្ញុំក៏អរគុណអ្នកដែលបានទទួលខ្ញុំ។

## ភាពកម្រនៃ "ស្រស់ស្អាត"

ដូច្នេះនៅពេលព្រឹកឡើង ពួកគេក៏ក្រោកឡើង ហើយបន្ទាប់ពីពិភាក្សាគ្នាបន្តិចទៀត ពួកគេបានប្រាប់គាត់ថា គាត់នឹងចាកចេញបានរហូតទាល់តែពួកគេបានបង្ហាញគាត់នូវសេចក្តីពិតនៃកន្លែងនោះ។ ហើយដំបូងគេឱ្យគាត់ចូលទៅក្នុងការសិក្សា ជាកន្លែងដែលពួកគេបានបង្ហាញគាត់ពីកំណត់ត្រានៃរឿងពីដើមដ៏អស្ចារ្យៗបំផុត។ ហើយដែលនៅក្នុងនោះ តាមដែលខ្ញុំចាំសុបិន្តរបស់ខ្ញុំ ពួកគេបានបង្ហាញពូជពង្សដំបូងបង្អោះរបស់ព្រះអម្ចាស់នៃភ្នំនោះ ដែលថាទ្រង់ជាបុត្ររបស់សម័យបុរាណ ហើយមកពីជំនាន់ដែលនៅអស់កល្បជានិច្ច។ នៅទីនេះក៏មានការកត់ត្រាយ៉ាងពេញលេញពីសកម្មភាពដែលទ្រង់បានធ្វើ ហើយនឹងឈ្មោះរបស់មនុស្សរាប់រយនាក់ដែលទ្រង់បានយកមកបម្រើដល់ទ្រង់ ហើយពីរបៀបដែលទ្រង់បានដាក់ពួកគេនៅក្នុងកេរ្តិ៍មរតកដែលមិនរលួយតាមរយៈពេល ឬដោយធម្មជាតិ ឬត្រូវបាត់បង់នោះឡើយ។

បន្ទាប់មកពួកគេក៏បានអានពីទង្វើដ៏មានតម្លៃរបស់អ្នកបម្រើរបស់ទ្រង់ដែលបានធ្វើ។ ដូចជារបៀបដែលពួកគេ "ចុះចូលក្នុងអាណាចក្រ នាំមកនូវសេចក្តីសុចរិត សម្រេចតាមសេចក្តីសន្យា បញ្ឈប់មាត់របស់សត្វតោ បង្ក្រាបភ្លើងឆេះសន្ធោរសន្ធៅ គេចផុតពីមុខដាវ ចេញពីសេចក្តីកំសោយក៏បានធ្វើឱ្យរឹងមាំឡើង កាន់តែក្លាហាននៅក្នុងការប្រយុទ្ធ ហើយបង្វែរទៅប្រយុទ្ធជាមួយនឹងទ័ពរបស់សាសន៍ដទៃ។"

**“ដែលដោយសារសេចក្តីជំនឿ នោះគេបានឈ្នះនគរដទៃ បានសម្រេចការសុចរិត បានទទួលសេចក្តីសន្យា បានបិទមាត់សិង្ហ បានពន្លត់អំណាចភ្លើង បានរួចពីមុខដាវ បានមានកម្លាំងក្នុងកាលដែលកំពុងតែខ្សោយ ក៏ត្រឡប់ជាពូកែក្នុងចំបាំង ទាំងកំចាត់ពលទ័ពសាសន៍ដទៃផង។” ហេព្រើរ 11”33, 34**

បន្ទាប់មកពួកគេបានអានផ្នែកផ្សេងទៀតនៃកំណត់ត្រានៅផ្ទះនោះ ត្រង់កន្លែងដែលបានបង្ហាញ ថាព្រះអម្ចាស់របស់ពួកគេមានបំណងទទួលមកក្នុងសេចក្តីសប្បុរសរបស់ទ្រង់ នូវអស់អ្នកដែលទោះពីដើមបានផ្តល់ការចំអកឡកលើយយ៉ាងខ្លាំងមកដល់អង្គទ្រង់និងកិច្ចការរបស់ទ្រង់ក្តី។ នៅទីនេះក៏មានប្រវត្តិខ្លះៗទៀតនៃរឿងដែលល្បីៗជាច្រើន ដែលគ្រប់ទាំងរឿងនោះគ្រីស្ទានអាចយល់បាន។ សម្រាប់រឿងទាំងពីបុរាណនិងសម័យ ជាមួយនឹងការទស្សទាយន៍និងការប៉ាន់ស្មានដែលបានសម្រេចពិតប្រាកដ ទាំងការដែលគួរឱ្យភ័យខ្លាចនិងការដែលគួរកោតសរសើររបស់សត្រូវ និងការកំសាន្តចិត្តនិងការសម្រាលដល់អ្នកធ្វើដំណើរ។

ថ្ងៃបន្ទាប់មកពួកគេបានយកគាត់ទៅក្នុងបន្ទប់សព្វាវុធ ជាកន្លែងដែលពួកគេបង្ហាញគាត់នូវគ្រប់ប្រភេទគ្រឿងសង្ហារឹម ដែលព្រះអម្ចាស់របស់ពួកគេបានប្រគល់ឱ្យដល់អ្នកធ្វើដំណើរ មានដាវ ខែល មួកការពារ របាំងទ្រូង គ្រប់ការអធិស្ឋាន និងស្បែកជើងដែលនឹងមិនត្រូវចាស់ខូច។ ហើយមាននៅទីនេះគ្រប់គ្រាន់នឹងបំពាក់ដល់មនុស្សជាច្រើនសម្រាប់នឹងបម្រើដល់ព្រះអម្ចាស់របស់ពួកគេ ដែលច្រើនដូចជាហ្វូងផ្កាយនៅលើមេឃ។

ពួកគេក៏បង្ហាញដល់គាត់នូវសម្ភារៈមួយចំនួន ដែលអ្នកបម្រើរបស់ទ្រង់មួយចំនួនបានធ្វើការដ៏អស្ចារ្យជាមួយនឹងរបស់ទាំងនោះ។ ពួកគេបានបង្ហាញគាត់នូវ ដំបងរបស់ម៉ូសេ ញញួរ និងដេកគោលដែលនាងយ៉ាអែលបានសម្លាប់ស៊ីសេរ៉ា ក្រឡទឹក ត្រែ និងកង្កៀងផង ដែលហ្គីឌានបានប្រើរបស់ទាំងនោះបណ្ដេញនូវទ័ពរបស់ពួកមីឌានចេញអស់។ បន្ទាប់មកពួកគេបានបង្ហាញគាត់នូវ ឆ្អឹងសត្វគោឈ្មោលដែលសាំកាបានប្រើសម្រាប់សម្លាប់មនុស្ស៦០០នាក់។ ពួកគេបានបង្ហាញគាត់នុវឆ្អឹងថ្គាមដែលសាំសុនប្រើដើម្បីធ្វើកិច្ចការដ៏អស្ចារ្យ។ ពួកគេបានបង្ហាញគាត់ថែមទៀតនូវ ខ្សែរគ្រវីនិងដុះថ្មដែលដាវីឌប្រើដើម្បីសម្លាប់ហ្គូលីយ៉ាតរបស់សាសន៍ហ្គាត។ និងដាវផងដែលព្រះអម្ចាស់របស់ពួកគេប្រើសម្រាប់សម្លាប់មនុស្សមានបាប នៅក្នុងថ្ងៃដែលគេនឹងក្រោកឡើងមករកចំណី។ ក្រៅពីនោះពួកគេបានបង្ហាញដល់គាត់នូវការយ៉ាងអស្ចារ្យជាច្រើនទៀត ដែលគ្រីស្ទានបានពេញចិត្តយ៉ាងខ្លាំងជាមួយការនោះ។ រួចមកពួកគេក៏បានចូលសំរាកម្ដងទៀត។

បន្ទាប់មកខ្ញុំបានឃើញនៅក្នុងសុបិន្តរបស់ខ្ញុំថា នៅពេលព្រលឹមឡើងគាត់បានក្រោកឡើងដើម្បីនឹងទៅមុខ តែពួកគេចង់ឱ្យគាត់ស្នាក់នៅរហូតដល់ថ្ងៃបន្ទាប់ទៀតផង ហើយរួចមក ពួកគេបាននិយាយថា ប្រសិនបើថ្ងៃភ្លឺច្បាស់ឡើង នឹងបង្ហាញដល់អ្នកនូវភ្នំដែលគួរឱ្យចង់ញាំ ដែលពួកគេនិយាយថានឹងបានបន្ថែមលើសេចក្តីកំសាន្តដល់គាត់ថែមទៀត ពីព្រោះពួកគេនៅជិតកន្លែងដែលប្រាថ្នា ជាជាងកន្លែងដែលទ្រង់គង់នៅ។ ដូច្នេះគាត់ក៏យល់ព្រមហើយក៏បានសំរាកទៅ។ នៅពេលព្រឹកព្រលឹមមកដល់ ពួកគេនាំគាត់ទៅ

លើដំបូលរបស់ព្រះ ហើយប្រាប់គាត់ឱ្យមើលទៅខាងត្បូង គាត់ក៏ធ្វើតាម ហើយឃើញចម្ងាយដ៏ឆ្ងាយ។

**“អ្នកនោះនឹងបាននៅក្នុងទីខ្ពស់ ទីពំនាក់របស់អ្នកនោះនឹងនៅលើថ្មដាដ៏មាំមួន ឯអាហារនឹងប្រទានមកអ្នកនោះ ហើយទឹករបស់អ្នកនោះនឹងចេះតែមាននៅ។ ភ្នែកឯងនឹងបានឃើញមហាក្សត្រ មានទាំងសេចក្តីលំអរុងរឿងរបស់ទ្រង់ គេនឹងមើលទៅឃើញស្រុកដល់ទីឆ្ងាយបំផុត។” អេសាយ 33:16, 17**

គាត់បានឃើញប្រទេសដែលពេញដោយភ្នំដ៏គួរឱ្យគាប់ចិត្ត ស្រស់ស្អាតមានឈើ ចម្ការទំពាំងបាយជូរ ផ្លែឈើគ្រប់ប្រភេទ ទាំងផ្កាផង ដោយមានទឹកជ្រោះនិងប្រភពទឹក ដែលគួរឱ្យចង់ឃើញ។ បន្ទាប់មកគាត់បានសួរឈ្មោះនៃប្រទេសនោះ។ ពួកគេបាននិយាយថា វាជាទឹកដីរបស់អេម៉ាញូអែល ជាទីដែលពេញនិយមដូចជាភ្នំនេះដែរ គឺសម្រាប់អ្នកធ្វើដំណើរទាំងអស់។ ហើយនៅពេលដែលអ្នកដល់ទីនោះ ពួកគេនិយាយថា ពីទីនេះអ្នកនឹងមើលឃើញឃ្លោងទ្វារនៃទីក្រុងបរិសុទ្ធ ដូចជាអ្នកគង្វាលដែលរស់នៅទីនោះនឹងបង្ហាញមកដែរ។

## ចាកចេញពីភ្នំ

ពេលនេះគាត់បានគិតមកកាន់ខ្លួនពីការធ្វើដំណើរទៅមុខទៀត ហើយពួកគេមានបំណងនឹងឱ្យគាត់ទៅ តែដំបូងពួកគេនិយាយថា សុំឱ្យពួកយើងបានចូលទៅក្នុងបន្ទប់ដាក់អាវុធម្តងទៀត ពួកគេបានចូលទៅ។ ហើយនៅពេលដែលពួកគេមកដល់ទីនោះ ពួកគេបានបំពាក់គាត់ពីក្បាលដល់ចុងជើងនូវអ្វីដែលជាភស្តុតាង ក្រែងគាត់អាចនឹងជួបជាមួយការវាយប្រហារនៅតាមផ្លូវ។ ដោយគាត់ត្រូវបានបំពាក់គ្រឿងរួចមក គាត់បានដើរចេញក្រៅជាមួយនឹងមិត្តរបស់គាត់ទៅកាន់ឃ្លោងទ្វារ ហើយនៅទីនោះ គាត់បានសួរអ្នកយាមទ្វារថា គាត់បានឃើញអ្នកដំណើរណាដែលឆ្លងកាត់ដែរទេ។ បន្ទាប់មកអ្នកយាមទ្វារបានឆ្លើយថា មាន។

គ្រីស្ទាន៖ គាត់និយាយថា តើអ្នកស្គាល់គេទេ?

អ្នកយាមទ្វារ៖ ខ្ញុំបានសួរឈ្មោះរបស់គាត់ ហើយគាត់បានប្រាប់ខ្ញុំថាឈ្មោះស្មោះត្រង់។

គ្រីស្ទាន៖ គ្រីស្ទានបាននិយាយថា "អូ" "ខ្ញុំស្គាល់គាត់។ គាត់ជាអ្នកស្រុករបស់ខ្ញុំ អ្នកជិតខាងរបស់ខ្ញុំ។ គាត់មកពីកន្លែងដែលខ្ញុំកើត។ តើអ្នកគិតថាគាត់ទៅមុខចម្ងាយប៉ុន្មានដែរ?"

អ្នកយាមទ្វារ៖ ពេលនេះគាត់ប្រហែលទៅដល់ជើងភ្នំហើយ។

គ្រីស្ទានៈ គ្រីស្ទាននិយាយថា "ល្អណាស់ អ្នកយាមទ្វារល្អអើយ សូមព្រះអម្ចាស់គង់នៅជាមួយអ្នក ហើយបន្ថែមព្រះពរដល់អ្នកថែមទៀតដោយសារសេចក្ដីសប្បុរសដែលអ្នកបង្ហាញមកដល់ខ្ញុំ!"

បន្ទាប់មកគាត់បានចាប់ផ្ដើមដើរទៅមុខ តែបំណាង មុតមាំ សប្បុរស និងប្រុងប្រយ័ត្នបានជូនដំណើរគាត់ចុះទៅដល់ជើងភ្នំ។ ដូច្នេះពួកគេបានទៅជាមួយគ្នា ដោយបន្តប្រាប់រឿងពីដើមៗរបស់ពួកគេ រហូតដល់ពួកគេមកដល់ជើងភ្នំ។ បន្ទាប់មកគ្រីស្ទានបាននិយាយថា "កាលដែលពិបាកឡើងយ៉ាងណាដូច្នេះវាក៏គ្រោះថ្នាក់ដែលចុះមកក្រោមផងដែរ (តាមដែលខ្ញុំអាចមើលឃើញ)។"

ប្រុងប្រយ័ត្នបាននិយាយថា "បាទ វាអីចឹងមែន ដោយសាវាពិបាកណាស់សម្រាប់ឱ្យមនុស្សម្នាក់ចុះទៅកាន់ជ្រលងនៃសេចក្ដីអាម៉ាស ដូចជាអ្នកពេលនេះដែរ ហើយដើម្បីកុំឱ្យជំពប់ដួលនៅតាមផ្លូវ។" ដូច្នេះពួកគេបាននិយាយថា "ពួកយើងចេញមកដើម្បីនឹងជូនដំណើរអ្នកចុះភ្នំ" ដូច្នេះកាត់ក៏ចាប់ដើរចុះទៅក្រោម តែដោយមានក្ដីព្រួយបារម្ភ តែគាត់ក៏បានជំពប់ដួលម្ដងពីរដែរ។

បន្ទាប់មកខ្ញុំបានឃើញនៅក្នុងសុបិន្តរបស់ខ្ញុំថា មិនសំឡាញ់ទាំងនេះបានឱ្យនំប៉័ងមួយដុំ ទឹកមួយដង និងទំពាំងបាយជូរក្រៀមមួយចង្កោមដល់គាត់ នៅពេលគ្រីស្ទានបានទៅដល់បាតភ្នំ ហើយរួចមកគាត់ក៏ចេញទៅតាមផ្លូវរបស់គាត់ទៅ។

## អាប៉ូឡេអុង

តែពេលនេះ នៅក្នុងជ្រោះនៃសេចក្ដីអាម៉ាស គ្រីស្ទានកំសត់ពិបាកនឹងដាក់វាណាស់ ដោយសារតែគាត់បានទៅមិនឆ្ងាយប៉ុន្មាន នៅខាងមុខនោះគាត់បានសម្លឹងមើលទៅឃើញបីសាយមួយដ៏អាក្រក់មកទីវាលដើម្បីនឹងជួបជាមួយគាត់ គេមានឈ្មោះថា អាប៉ូឡេអុង។ បន្ទាប់មកគ្រីស្ទានចាប់ផ្ដើមភ័យខ្លាច ហើយដែលគិតនៅក្នុងចិត្តរបស់គាត់ថានឹងត្រូវត្រឡប់ក្រោយឬឈរនៅទីនោះទេ។ តែគាត់បានគិតពិចារណាម្ដងទៀត គាត់មិនមានអាវុធសម្រាប់នឹងត្រឡប់ទៅវិញទេ ហើយដូច្នេះបានគិតថាការត្រឡប់ទៅវិញសម្រាប់គាត់ នឹងធ្វើឱ្យគេទទួលបានប្រយោជន៍យ៉ាងច្រើនដោយងាយ នៅក្នុងការដែលបាញ់ទំលុះគាត់ជាមួយនឹងព្រួយ។ ដូច្នេះគាត់សម្រេចចិត្តថានឹងប្រថុយគ្រោះថ្នាក់ ហើយនៅឈរនៅទីនោះ។ ដោយគាត់គិតថា ខ្ញុំមានភ្នែកសម្រាប់តែនឹងសង្គ្រោះជីវិតរបស់ខ្ញុំតែប៉ុណ្ណោះ នេះជាការល្អបំផុតហើយដែលត្រូវឈរនៅទីនេះ។

ដូច្នេះគាត់បានទៅមុខទៀត ហើយអាប៉ូឡេអុងបានជួបជាមួយគាត់។ ពេលនេះបិសាយអាក្រក់មើលណាស់។ វាមានគ្របដណ្ដប់ដោយស្រកាដូចជាសត្វត្រី (ហើយទាំងនោះជាសេចក្ដីអំណួតរបស់គេ) គេមានស្លាបដូចជាសត្វនាគ ប្រអប់ជើងដូចជាសត្វខ្លាឃ្មុំ ហើយចេញពីពោះរបស់គេមានភ្លើងនិងផ្សែង ហើយមាត់របស់គាត់ដូចជាមាត់តោ។ នៅពេលដែលគេមកក្បែរគ្រីស្ទាន គេបានមើលមកគាត់ដោយទឹកមុខឡូកលើយ ហើយគេក៏ចាប់ផ្ដើមសួរគាត់

អាប៉ូឡែអុង៖ តើអ្នកមកពីណា ហើយសំដៅទៅទីណាដែរ?

គ្រីស្ទាន៖ ខ្ញុំបានមកពីក្រុងនៃសេចក្តីវិនាសអន្តរាយ ដែលជាទីកន្លែងនៃគ្រប់សេចក្តីទុច្ចរិត ហើយខ្ញុំកំពុងទៅកាន់ក្រុងស៊ីយ៉ូន។

អាប៉ូឡែអុង៖ អីចឹងខ្ញុំយល់ថាអ្នកជាបញ្ជាមួយរបស់ខ្ញុំ ដោយសារតែប្រទេសនោះទាំងមូលជារបស់ខ្ញុំ ហើយខ្ញុំធ្វើជាស្តេចនិងជាព្រះនៅទីនោះ។ តើហេតុអ្វីបានជាអ្នកបានរត់ចេញពីស្តេចរបស់អ្នកដូច្នេះ? តើខ្ញុំមិនបានប្រាថ្នាថាអ្នកនឹងបម្រើខ្ញុំទេឬយ៉ាងណា? ខ្ញុំនឹងកាប់ឯងឱ្យដួលនៅនឹងដីតែម្តង។

គ្រីស្ទាន៖ ខ្ញុំបានកើតនៅក្នុងការគ្រប់គ្រងរបស់អ្នកពិតមែន តែកិច្ចការរបស់អ្នកពិបាកខ្លាំងណាស់ ហើយថ្លៃឈ្នួលរបស់អ្នកគឺមិនអាចឱ្យមនុស្សរស់បានទេ ដោយសារឈ្នួលនៃអំពើបាបជាសេចក្តីស្លាប់។

‶ដ្បិតគ្រប់គ្នាបានធ្វើបាប ហើយខ្វះមិនដល់សិរីល្អនៃព្រះ″ រ៉ូម 3:23

ដូច្នេះ នៅពេលដែលខ្ញុំរស់នៅជាច្រើនឆ្នាំ នោះខ្ញុំបានធ្វើដូចជាមនុស្សវៃឆ្លាតផ្សេងទៀត ដោយសម្លឹងមើល ប្រហែលជាខ្ញុំអាចនឹងបំបែរខ្លួនរបស់ខ្ញុំបាន។

អាប៉ូឡែអុង៖ មិនមានស្តេចណាដែលនឹងត្រូវបាត់បង់កូនចៅរបស់ខ្លួនដោយងាយនោះទេ ហើយខ្ញុំក៏នឹងមិនត្រូវបាតបង់អ្នកដែរ។ តែដោយអ្នកបានរអ៊ូរទាំនឹងការងាររបស់អ្នកនិងថ្លៃឈ្នួលផងនោះ ចូរអ្នកត្រឡប់ទៅវិញទៅ ខ្ញុំ

នឹងសន្យានឹងអ្នកនៅទីនេះថា នឹងឱ្យដល់អ្នកនូវអ្វីដែលប្រទេសរបស់យើងអាចឱ្យបាន។

គ្រីស្នាន៖ តែខ្ញុំបានអនុញ្ញាតខ្លួនទៅដល់ស្តេចមួយអង្គផ្សេងទៀតហើយ ដែលទ្រង់ជាស្តេចលើអស់ទាំងស្តេច ហើយតើខ្ញុំនឹងត្រឡប់ទៅវិញជាមួយអ្នកដោយសេចក្តីត្រឹមត្រូវបានយ៉ាងម៉េច?

អាប៉ូឡេអុង៖ អ្នកបានធ្វើដូចនឹងសុភាសិតមួយនិយាយថា "បានប្តូរពីការអាក្រក់ជាមួយនឹងការដ៏អាក្រក់បំផុត" តែវាជាការធម្មតាសម្រាប់ពួកអ្នកដែលសារភាពថាជាអ្នកបម្រើរបស់ទ្រង់ មួយរយៈក្រោយនឹងជំពប់ដួល ហើយត្រឡប់មករកខ្ញុំម្តងទៀត។ អ្នកក៏អាចធ្វើបែបនោះបាន ហើយវាមិនមានរឿងអ្វីឡើយ។

គ្រីស្នាន៖ ខ្ញុំបានផ្តល់ដល់ទ្រង់នូវសេចក្តីជំនឿរបស់ខ្ញុំ និងស្បថនូវសេចក្តីស្មោះត្រង់របស់ខ្ញុំដល់ទ្រង់ តើខ្ញុំអាចនឹងត្រឡប់ចេញពីការនេះ ហើយមិនត្រូវរាប់ជាមនុស្សក្បត់បានយ៉ាងដូចម្តេច?

អាប៉ូឡេអុង៖ អ្នកបានធ្វើដូច្នោះមកកាន់ខ្ញុំដូចគ្នា តែខ្ញុំនឹងមិនរាប់វាឡើយ ប្រសិនបើអ្នកនឹងប្រឡប់ក្រោយម្តងទៀតនៅពេលនេះ។

គ្រីស្នាន៖ អ្វីដែលខ្ញុំបានសន្យានឹងអ្នកនោះ គឺមុនពេលដែលខ្ញុំធំនៅឡើយ ហើយក្រៅពីនោះ ខ្ញុំបានរាប់ថាស្តេចដែលខ្ញុំនៅក្រោមពេលនេះអាចនឹងជួយខ្ញុំបាន។ ហើយពិតណាស់ទ្រង់បានអត់ទោសឱ្យនូវអ្វីដែលខ្ញុំបានធ្វើដោយការឃុបឃិតរបស់ខ្ញុំជាមួយអ្នក។ ហើយក្រៅពីនោះ ឱអាប៉ូឡេអុងបំផ្លាញ

អើយ បើនិយាយការពិតទៅ ខ្ញុំចូលចិត្តកិច្ចរបស់ទ្រង់ណាស់ ទាំងថ្លៃឈ្នួលសំលៀកបំពាក់របស់ទ្រង់ បរិវាររបស់ទ្រង់ និងប្រទេសរបស់ទ្រង់ជាងប្រទេសរបស់អ្នក។ ដូច្នេះសូមឈប់បបួលខ្ញុំបន្តធ្វើអ្វី។ ខ្ញុំជាអ្នកបម្រើរបស់ទ្រង់ ហើយខ្ញុំនឹងដើរតាមទ្រង់។

អាប៉ូឡែអុង៖ ចូរពិចារណាម្តងទៀត នៅពេលដែលអ្នកនៅឈាមត្រជាក់នៅឡើយ នូវអ្វីដែលអ្នកនឹងជួបនៅតាមផ្លូវដែលអ្នកទៅ។ អ្នកបានដឹងថា ភាគច្រើនអ្នកបម្រើរបស់ទ្រង់មកដល់ទីបញ្ចប់ដ៏អាក្រក់ ដោយសារពួកគេប្រឆាំងទាស់នឹងខ្ញុំនិងផ្លូវរបស់ខ្ញុំ។ តើពួកគេប៉ុន្មានអ្នកដែលត្រូវបានស្លាប់ដោយសេចក្តីអាម៉ាស! ហើយក្រៅពីនោះអ្នកបានរាប់ថាកិច្ចការរបស់ទ្រង់ប្រសើរជាងខ្ញុំ ជាកន្លែងដែលទ្រង់មិនដែលចេញមកផង ដើម្បីនឹងរំដោះពួកអ្នកដែលបម្រើទ្រង់ពីដៃរបស់យើង។ ប៉ុន្តែសម្រាប់ខ្ញុំវិញ តើមានប៉ុន្មានដងដែរដូចដែលមនុស្សមួយពិភពលោកបានដឹងយ៉ាងច្បាស់ថា ខ្ញុំបានរំដោះ មិនថាដោយអំណាច ឬការបោកបញ្ឆោតនោះទេ អស់អ្នកដែលបានបម្រើខ្ញុំដោយស្មោះត្រង់ ចេញពីទ្រង់និងរបស់ផងទ្រង់ បើទោះជាត្រូវបានពួកគេយកមកហើយដូច្នោះខ្ញុំក៏នឹងរំដោះពួកគេ!

គ្រីស្ទាន៖ការអត់ធ្មត់របស់គាត់នៅពេលបច្ចុប្បន្ននេះគឺដើម្បីរំដោះពួកគេ ជាគោលបំណងដើម្បីសាកល្បងសេចក្តីស្រឡាញ់របស់ពួកគេ ថាពួកគេនឹងនៅជាប់ជាមួយនឹងទ្រង់ដល់ទីបញ្ចប់ដែរទេ។ ហើយមកដល់ទីបញ្ចប់ដែលអាក្រក់ដែលពួកគេមកដល់វិញ នោះជាការដែលពេញដោយសិរីរុងរឿងបំផុតរបស់ពួកគេ។ ដោយសារសេចក្តីប្រោសលោះនាពេលបច្ចុប្បន្ន ពួកគេមិនបានសង្ឃឹមអ្វីច្រើនទេ ដោយសារពួកគេរំពឹងចង់បានសិរីរុងរឿងរបស់

ពួកគេ ហើយបន្ទាប់មកនោះគេនឹងទទួលបាន នៅពេលដែលព្រះអង្គម្ចាស់របស់ពួកគេយាងមក ជាមួយនឹងសិរីល្អរបស់ពួកទេវតាផង។

អាប៉ូឡូអុង៖ អ្នកបានស្មោះត្រង់នៅក្នុងការបម្រើទៅដល់ទ្រង់រួចហើយ ហើយហេតុអ្វីបានជាអ្នកគិតថានឹងទទួលឈ្នួលរបស់ទ្រង់ដូច្នេះ?

គ្រីស្ទាន៖ ឱអាប៉ូឡូអុងអើយ តើខ្ញុំមិនបានស្មោះត្រង់នឹងទ្រង់នៅត្រង់ណា?

អាប៉ូឡូអុង៖ អ្នកបានដួលកាលពីចេញមកដំបូង នៅពេលដែលអ្នកស្ទើរតែដាច់ខ្យល់នៅឯរណ្ដៅនៃការចុះខ្សោយខាងវិញ្ញាណ។ អ្នកមានបំណងទៅតាមផ្លូវខុស ដើម្បីដោះបន្ទុករបស់អ្នកចេញ ជាកន្លែងដែលអ្នកមិនគួរស្នាក់នៅឡើយ ទាល់តែព្រះអម្ចាស់របស់អ្នកយកបន្ទុកនោះចេញ។ អ្នកបានដេកដោយធ្វើបាប ហើយបាត់បង់របស់ល្អៗរបស់អ្នក។ ហើយអ្នកស្ទើរតែត្រូវទាក់ទាញឱ្យត្រឡប់ក្រោយវិញដោយសារឃើញសត្វតោ។ ហើយនៅពេលដែលអ្នកនិយាយពីការធ្វើដំណើររបស់ព្រះ និងការដែលអ្នកបានឮនិងបានឃើញ អ្នកប៉ងប្រាថ្នាចង់បានសិរីល្អដែលឥតប្រយោជន៍នៅក្នុងការដែលអ្នកនិយាយនិងធ្វើផងនៅក្នុងចិត្ត។

គ្រីស្ទាន៖ ការទាំងនេះសុទ្ធតែត្រូវ ហើយមានការជាច្រើនទៀតដែលអ្នករំលង តែព្រះអម្ចាស់ដែលខ្ញុំបម្រើ និងគោរព ទ្រង់មានមេត្តាករុណា និងរួចរាល់ដើម្បីអត់ទោសឱ្យ។ តែក្រៅពីនោះ ជំងឺទាំងនេះបានមកលើខ្ញុំនៅក្នុងប្រទេសរបស់អ្នក។ ដោយសារនៅទីនោះខ្ញុំបានជញ្ជក់វាចូល ហើយខ្ញុំបាន

ទួញសោកដោយសារការទាំងនោះ ហើយសោកស្តាយនឹងការនោះ ហើយក៏បានទទួលការអត់ទោសពីព្រះអម្ចាស់របស់ខ្ញុំ។

អាប៉ូឡេអុង៖ បន្ទាប់មកអាប៉ូឡេអុងបានយំស្រែកយ៉ាងក្រៃលែង ដោយនិយាយថា "ខ្ញុំជាសត្រូវនឹងព្រះអម្ចាស់នេះ។ ខ្ញុំស្អប់អង្គទ្រង់ ក្រិត្យវិន័យទ្រង់ និងរាស្ត្ររបស់ទ្រង់។ ខ្ញុំបានចេញមកដោយមានបំណងដើម្បីយកឈ្នះលើអ្នក។"

គ្រីស្ទាន៖ អាប៉ូឡេអុងអើយ ចូរប្រយ័ត្ននឹងអ្វីដែលអ្នកធ្វើ ដោយសារខ្ញុំកំពុងនៅលើផ្លូវធំរបស់ស្តេច ជាផ្លូវនៃសេចក្តីបរិសុទ្ធ ដូច្នេះចូរប្រយ័ត្នខ្លួនអ្នកផង!

អាប៉ូឡេអុង៖ បន្ទាប់មកអាប៉ូឡេអុងបានដើរកាត់ទទឹងផ្លូវទាំងមូលហើយនិយាយថា "ខ្ញុំគ្មានការភ័យខ្លាចក្នុងរឿងនេះទេ សូមត្រៀមខ្លួនស្លាប់ទៅ! ដ្បិតខ្ញុំបានស្បថដោយរូងដ៏រំខាងរបស់ខ្ញុំថា អ្នកនឹងមិនទៅណាឆ្ងាយទេ! ។" នៅទីនេះ អញនឹងបង្ហូរព្រលឹងរបស់ឯង ហើយក៏បានបាញ់ព្រួញភ្លើងទៅទ្រូងរបស់គាត់។ ប៉ុន្តែគ្រីស្ទានមានខែលមួយនៅក្នុងដៃរបស់គាត់ដែលគាត់បានចាប់យក ហើយបានការពារពីគ្រោះថ្នាក់នោះ។ គ្រីស្តានបានគួរដោយសារគាត់បានមើលឃើញថា វាជាពេលវេលាដែលគាត់ត្រូវចាប់ផ្តើមធ្វើការហើយ។ នោះអាប៉ូឡេអុងចាប់ផ្តើមបាញ់ព្រួញទៅគាត់យ៉ាងលឿនដែលក្រាស់ដូចព្រិល។ ដោយអ្វីដែលគ្រីស្ទសាសនាអាចធ្វើបាន មិនអាចគេចរួចពីអាប៉ូឡេអុង។ នោះអាប៉ូឡេអុងបានធ្វើឱ្យគាត់បានរងរបួសត្រង់ក្បាលដៃនិងជើង។ នេះបានធ្វើឱ្យគ្រីស្ទានផ្តល់ឱ្យត្រឡប់មកវិញតិចតួចដៃរ។ ដូច្នេះអាប៉ូឡេអុងបានដើរតាមការងាររបស់គាត់យ៉ាងខ្លាំង ហើយគ្រីស្ទា

នក៏មានភាពក្លាហានម្តងទៀត ហើយបានតស៊ូយ៉ាងអង់អាចតាមដែលអាចធ្វើទៅបាន។ ការប្រយុទ្ធដ៏ស្វិតស្វាញនេះបានអូសបន្លាយអស់រយៈពេលជាងកន្លះថ្ងៃ ហើយរហូតដល់គ្រីស្ទានស្ទើរតែត្រូវចំណាយកម្លាំងច្រើន។ ដោយសារអ្នកដឹងថាគ្រីស្ទាន ដោយសាររបួសរបស់គាត់ ក៏ត្រូវបានចុះខ្សោយទៅៗផង។

បន្ទាប់មកអាប៉ូឡ្យុងដែលឆ្លៀតឱកាសរបស់គាត់ បានចាប់ផ្តើមប្រមូលមកជិតនឹងគ្រីស្ទាន ហើយការប្រយុទ្ធជាមួយគាត់បានធ្វើឱ្យគាត់ដួលរលំគួរឱ្យខ្លាច។ ហើយជាមួយនោះ ដាវរបស់គ្រីស្ទានបានហោះចេញពីដៃរបស់គាត់។ បន្ទាប់មក អាប៉ូឡ្យុងបាននិយាយថា"ខ្ញុំដឹងច្បាស់ពីអ្នកហើយឥឡូវនេះ" ដូចនោះគាតគាត់បានសង្កត់គាត់ស្ទើរតែដល់ស្លាប់ ដូច្នេះគ្រីស្ទានចាប់ផ្តើមអស់សង្ឃឹមនៃជីវិត។ ប៉ុន្តែដូចជាព្រះទ្រង់ចង់បានដែរខណៈពេលដែលអាប៉ូឡ្យុងបានវាយជាចុងក្រោយ ដើម្បីធ្វើឱ្យបញ្ចប់ជីវិតគ្រីស្ទានដ៏ល្អម្នាក់នេះ គ្រីស្ទានបានលូកដៃទៅដាវរបស់គាត់ហើយចាប់វាមក ដោយនិយាយថា" ឱ! កុំរីករាយនឹងខ្ញុំឡើយ! ខ្មាំងសត្រូវពេលខ្ញុំដួល ខ្ញុំនឹងក្រោកឡើង។"

"ឱខ្មាំងសត្រូវអើយ កុំឱ្យសប្បាយចិត្តពីដំណើរខ្ញុំឡើយ កាលណាខ្ញុំដួល នោះខ្ញុំនឹងក្រោកឡើងវិញ កាលណាខ្ញុំអង្គុយក្នុងទីងងឹត នោះព្រះយេហូវ៉ានឹងជាពន្លឺដល់ខ្ញុំ។" មីកា 7:8

ហើយដូចនោះក៏បានផ្តល់ការវាយប្រហារគាត់ស្ទើរស្លាប់ ដែលធ្វើឱ្យគាត់ចុះចាញ់ ដូចជាម្នាក់ដែលបានទទួលរបួសខាងលោកិយ។ គ្រីស្ទានយល់ថា វា

បានធ្វើឱ្យគាត់និយាយម្តងទៀតថា "នៅក្នុងគ្រប់ការទាំងនេះ យើងប្រសើរជាងអ្នកមានជ័យជម្នះផង តាមរយៈទ្រង់ដែលបានស្រឡាញ់ដល់យើង។"

‶ទេ គឺនៅក្នុងសេចក្តីទាំងនោះ យើងខ្ញុំវិសេសលើសជាងអ្នកដែលមានជ័យជម្នះទៅទៀត ដោយសារព្រះអង្គដែលទ្រង់ស្រឡាញ់យើង។″ រ៉ូម 8:37

ដូចនោះ អាប៉ូឡេអុងក៏បានពន្លាស្លាបនាគរបស់គេចេញមក ហើយបានហោះចេញបាត់ទៅ

‶ដូច្នេះ ត្រូវចុះចូលចំពោះព្រះ ហើយតស៊ូនឹងអារក្សវិញចុះ នោះវានឹងរត់ចេញពីអ្នកពាលគ្នាទៅ។″ យ៉ាកុប 4:7
នោះគ្រីស្ទានក៏លែងបានឃើញគាត់ទៀតទៅ។

នៅក្នុងការប្រយុទ្ធនេះ គ្មាននរណាម្នាក់អាចស្រមៃគិតដល់បានទេ លើកលែងតែគាត់បានឃើញនិងធ្វើដូចដែលខ្ញុំបានជួប។ អ្វីដែលជាសម្រែកនិងគ្រហឹមរបស់អាប៉ូឡេអុង បានធ្វើគ្រប់ពេលនៃការប្រយុទ្ធគឺ - គាត់និយាយដូចជានាគ ហើយភាគីម្ខាងទៀត អ្វីដែលស្រែកថ្ងូរនិងថ្ងូរចេញពីដួងចិត្តរបស់គ្រីស្ទាន។ ខ្ញុំមិនដែលឃើញគាត់គ្រប់ពេលវេលាមើលទៅគួរឱ្យរីករាយដូចនេះ រហូតដល់គាត់ដឹងថាគាត់បានបង្ករបួសដល់អាប៉ូឡេអុងដោយដាវមុខពីររបស់គាត់ បន្ទាប់មក គាត់បានញញឹមហើយមើលទៅខាងលើ។ ប៉ុន្តែការមើលឃើញរូបភាពដ៏គួរឱ្យខ្លាចបំផុតដែលខ្ញុំធ្លាប់បានឃើញ!

ដូច្នេះនៅពេលដែលការប្រយុទ្ធបានបញ្ចប់ គ្រីស្ទានបាននិយាយថា"ខ្ញុំនឹងអរព្រះគុណដល់ព្រះអង្គដែលបានរំដោះខ្ញុំចេញពីមាត់តោ ដល់ទ្រង់ដែលបានជួយខ្ញុំវាយប្រឆាំងនឹងអាប៉ូឡេអុង។ ដូច្នេះគាត់និយាយថា

"បីលសេប៊ុលដ៏អស្ចារ្យ ជាមេលើកូនចៅមួយនេះ បានរៀបចំសេចក្ដីវិនាសរបស់ខ្ញុំ។ ដូច្នេះមកដល់ទីបញ្ចប់នេះ គាត់បានបំពាក់គេឱ្យចេញមក ហើយដោយកំហឹងយ៉ាងអាក្រក់នោះ បានមករកខ្ញុំយ៉ាងខ្លាំង។ តែមានពរហើយមីកែលដែលបានជួយដល់ខ្ញុំ ហើយដោយមុខដាវបានធ្វើឱ្យគាត់ហោះទៅយ៉ាងលឿន។ ដូច្នេះសូមឱ្យខ្ញុំបានថ្វាយការសរសើរដល់ទ្រង់អស់កល្បជានិច្ច និងការអរគុណ ហើយនឹងសរសើរនាមបរិសុទ្ធរបស់ទ្រង់ជានិច្ច!"

បន្ទាប់មកមានដៃមួយមកកាន់គាត់ ដែលមានស្លឹកឈើនៃដើមជីវិត ដែលគ្រីស្ទានយកមក ហើយបានលាបវាទៅរបួសដែលគាត់បានទទួលនៅក្នុងសមរភូមិ ហើយត្រូវបានជាសះស្បើយភ្លាមៗ។ គាត់ក៏បានអង្គុយនៅកន្លែងនោះ រួចញ៉ាំនំប៉ុងនិងផឹកពីដបដែលត្រូវបានផ្ដល់ឱ្យគាត់ពីមុន។ ដូច្នេះលោកបានធូរស្បើយឡើងវិញ ហើយលោកក៏រៀបចំខ្លួននឹងធ្វើដំណើរដោយកាន់ដាវនៅដៃលោក។ លោកមានប្រសាសន៍ថា "ខ្ញុំមិនដឹងទេថាខ្មាំងសត្រូវខ្លះទៀតអាចជានៅជិត"។ ប៉ុន្តែគាត់មិនបានជួបអ្នកណាផ្សេងទៀត ក្រៅពីអាប៉ូឡេអុងឡើយនៅតាមជ្រលងភ្នំនេះ។

*(The End of Part I Volume I-1)*